ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សន្និបាត



## បូកសរុបលទ្ធផលការងារ

## អប់រំ យុវជន និងកីឡា

## ឆ្នាំសិក្សា២០១៣ - ២០១៤ និងទិសដៅ

## ឆ្នាំសិក្សា២០១៤ - ២០១៥

ថ្ងៃទី២៤ - ២៥ - ២៦ ខែមីនា ឆ្នាំ២០១៥

| មាតិកា | ទំព័រ |
|---|---|
| **ផ្នែកទី ១ ៖ លទ្ធផល និងទិសដៅ** | |
| **១. សេចក្តីផ្តើម** | ១ |
| **២. វឌ្ឍនភាព** | ២ |
| **២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា** | ២ |
| ២.១.១. វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយក្នុងឆ្នាំ ២០១៤ | ២ |
| ២.១.២. វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល | ៥ |
| ២.១.៣. វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ | ៧ |
| ២.១.៤. វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៣-២០១៤ | ៨ |
| ២.១.៥. វឌ្ឍនភាពនៃការគ្រប់គ្រង និងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ | ៨ |
| ២.១.៦. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ១១ |
| ២.១.៧. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារៈ | ១២ |
| ២.១.៨. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១៥ |
| ២.១.៩. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់ទាំង ៨ ចំណុច | ១៩ |
| **២.២ លទ្ធផលតាមអនុវិស័យ** | ២១ |
| ២.២.១. អនុវិស័យ ការអប់រំកុមារតូច | ២១ |
| ២.២.២. អនុវិស័យ ការអប់រំបឋមសិក្សា | ២៩ |
| ២.២.៣. អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ៣៨ |
| ២.២.៤. អនុវិស័យ ការអប់រំឧត្តមសិក្សា | ៥២ |
| ២.២.៥. អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៦៣ |
| ២.២.៦. អនុវិស័យ ការអភិវឌ្ឍយុវជន | ៧៥ |
| ២.២.៧. អនុវិស័យ ការអប់រំកាយ និងកីឡា | ៧៩ |
| **៣. ទិសដៅឆ្នាំសិក្សា ២០១៤-២០១៥** | ៨៨ |
| **៣.១. ទិសដៅកំណែទម្រង់សំខាន់ៗ** | ៨៨ |
| ៣.១.១. ការពង្រឹងប្រព័ន្ធផែនការ | ៨៨ |
| ៣.១.២. ការងារវិមជ្ឈការ និងវិសហមជ្ឈការ | ៨៨ |
| ៣.១.៣. ការគ្រប់គ្រងបុគ្គលិក | ៨៨ |
| ៣.១.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៨៩ |
| **៣.២. ទិសដៅតាមអនុវិស័យ** | ៨៩ |
| ៣.២.១. អនុវិស័យ ការអប់រំកុមារតូច | ៨៩ |
| ៣.២.២. អនុវិស័យ ការអប់រំបឋមសិក្សា | ៩០ |
| ៣.២.៣. អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ៩១ |
| ៣.២.៤. អនុវិស័យ ការអប់រំឧត្តមសិក្សា | ៩២ |
| ៣.២.៥. អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៩២ |
| ៣.២.៦. អនុវិស័យ ការអភិវឌ្ឍយុវជន | ៩៣ |
| ៣.២.៧. អនុវិស័យ ការអប់រំកាយ និងកីឡា | ៩៣ |

| | |
|---|---|
| **៣.៣ បញ្ហាប្រឈម និងទិសដៅឆ្លងអនុវិស័យ** | ៩៤ |
| ៣.៣.១. ការងារអភិវឌ្ឍកម្មវិធីសិក្សា | ៩៤ |
| ៣.៣.២. ការងាររដ្ឋបាល | ៩៥ |
| ៣.៣.៣. ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | ៩៥ |
| ៣.៣.៤. ការងារព័ត៌មាន និងកិច្ចការអាស៊ាន | ៩៥ |
| ៣.៣.៥. ការងារសំណង់សិក្សា | ៩៦ |
| ៣.៣.៦. ការងារបោះពុម្ព និងចែកផ្សាយ | ៩៦ |
| ៣.៣.៧. ការងារធានាគុណភាពអប់រំ | ៩៧ |
| **៤. សេចក្តីសន្និដ្ឋាន** | ៩៧ |
| **ផ្នែកទី២ ៖ ឧបសម្ព័ន្ធ** | |
| ឧបសម្ព័ន្ធទី១ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ | ១០៣ |
| ឧបសម្ព័ន្ធទី២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៣-២០១៤ | ១០៤ |
| ឧបសម្ព័ន្ធទី៣ ៖ វឌ្ឍនភាពតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយឆ្នាំ២០១៤ | ១០៥ |
| ឧបសម្ព័ន្ធទី៤ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ | ១១៤ |
| ឧបសម្ព័ន្ធទី៥ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៣-២០១៤ | ១៥០ |
| **ផ្នែកទី៣ ៖ ប្រធានបទពិភាក្សា** | |
| ប្រធានបទពិភាក្សា | ១៦៧ |

# ផ្នែកទី១

# លទ្ធផល និងទិសដៅ

## ១. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡាកំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលឆ្លើយតបនឹងកំណែទម្រង់ និងដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដូចមានបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។ ក្រសួងអប់រំ យុវជន និងកីឡារួមជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដទៃទៀតបានប្តេជ្ញាខិតខំពង្រឹងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រកម្មវិធីដែលបានកំណត់កន្លងមក និងបញ្ចូលនូវអាទិភាព និងសកម្មភាពការងារថ្មីៗ រួមបញ្ចូលទាំងវិធានការកំណែទម្រង់អាទិភាព ៨ ចំណុចរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបានឈរលើមូលដ្ឋាននៃការគ្រប់គ្រង និងការកសាងផែនការផ្តោតលើលទ្ធផល និងរៀបចំតាមអនុវិស័យសំខាន់ៗ។

ការពិនិត្យតាមដាន និងពិនិត្យឡើងវិញការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមដំណាក់កាល និងជាប្រចាំ ក៏ជាចំណុចសំខាន់ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវផ្តោតការយកចិត្តទុកដាក់ផងដែរ តាមរយៈការបង្កើតគណៈកម្មការបច្ចេកទេសសន្និបាតអប់រំ និងការបង្កើនប្រសិទ្ធភាពនៃលទ្ធផលរបស់សន្និបាត។ ដំណើរការសន្និបាតបានអនុលោមតាមក្របខណ្ឌការងារពេញលេញមានលក្ខណៈជាប្រព័ន្ធ និងមានវត្ថុបំណងច្បាស់លាស់។ គុណភាពរបស់សន្និបាតអប់រំក៏ត្រូវបានលើកកម្ពស់ តាមរយៈរបាយការណ៍បូកសរុបការងារដែលកាន់តែមានលក្ខណៈសាមញ្ញ វិភាគ និងផ្តោតលើលទ្ធផលជាសំខាន់។ សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៣-២០១៤ និងលើកទិសដៅឆ្នាំសិក្សា ២០១៤-២០១៥ ជាឱកាសថ្មីមួយទៀត ដើម្បីពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងពង្រឹងការទទួលខុសត្រូវរួមគ្នារវាងក្រសួង អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ។

វឌ្ឍនភាពនិងបទពិសោធនៃការអនុវត្តតាមបែបអនុវិស័យ និងការពិនិត្យតាមដានវឌ្ឍនភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤ បានឆ្លុះបញ្ចាំងនៅក្នុងខ្លឹមសារនៃរបាយការណ៍សន្និបាតអប់រំ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការពិនិត្យឡើងវិញពីសកម្មភាព និងចំណុចដៅរបស់សូចនាករ។ របាយការណ៍សន្និបាតអប់រំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍ជារួមរបស់ក្រសួង និងតាមអនុវិស័យទាំង ៧ រួមមានការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។ លទ្ធផលសន្និបាតអប់រំនឹងក្លាយជាមូលដ្ឋានដ៏មានសារៈសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦-២០១៨ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦។

ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ កន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចលទ្ធផលធំៗដូចតទៅ ៖

# ២. វឌ្ឍនភាព

## ២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

### ២.១.១ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០១៤

ក្រសួងបានគ្រោងអនុវត្តសកម្មភាពគោលនយោបាយសរុប ៧២ បានបញ្ចប់ ៣១ ស្មើនឹង ៤៣ ភាគរយ កំពុងអនុវត្ត ២៧ ស្មើនឹង ៣៧,៥ ភាគរយ និងមិនទាន់បានអនុវត្ត ១៤ ស្មើនឹង ១៩,៤ ភាគរយ។

គោលនយោបាយទី១ មាន ២៥ សកម្មភាព បានបញ្ចប់ ១២ ស្មើនឹង ៤៨ ភាគរយ កំពុងអនុវត្ត ៨ ស្មើនឹង ៣២ ភាគរយ និងមិនទាន់បានអនុវត្ត ៥ ស្មើនឹង ២០ ភាគរយ។ គោលនយោបាយទី២ មាន ១៦ សកម្មភាព បានបញ្ចប់ ៥ ស្មើនឹង ៣១,៣ ភាគរយ កំពុងអនុវត្ត ៨ ស្មើនឹង ៥០ ភាគរយ និងមិនទាន់បានអនុវត្ត ៣ ស្មើនឹង ១៨,៨ ភាគរយ។ គោលនយោបាយទី៣ មាន ៣១ សកម្មភាព បានបញ្ចប់ ១០ ស្មើនឹង ៣២,២ ភាគរយ កំពុងអនុវត្ត ១២ ស្មើនឹង ៣៨,៧ ភាគរយ និងមិនទាន់បានអនុវត្ត ៩ ស្មើនឹង ២៩,១ ភាគរយ។

ប្រការនេះ បង្ហាញអំពីការត្រូវយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការរៀបចំអន្តរាគមន៍ និងការពង្រីកវិសាលភាពកម្មវិធី ដើម្បីបង្កើនការចូលរៀន និងការទទួលសេវានៅគ្រប់អនុវិស័យ ការរៀបចំក្របខណ្ឌធានាគុណភាព និងការបង្កើនប្រសិទ្ធភាពនៃការបង្រៀននិងរៀន និងជាពិសេសការរៀបចំប្រព័ន្ធផែនការគ្រប់គ្រង ពិនិត្យតាមដាន និងវាយតម្លៃរបស់អនុវិស័យ។

រូបភាពទី១ ៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០១៤




អនុវិស័យការអប់រំកុមារតូចមាន ៩ សកម្មភាព បានបញ្ចប់ ៣ ស្មើនឹង ៣៣,៣ ភាគរយ កំពុងអនុវត្ត ៥ ស្មើនឹង ៥៥,៥ ភាគរយ និងមិនទាន់បានអនុវត្ត ១ ស្មើនឹង ១១,២ ភាគរយ។ ភាពយឺតយ៉ាវក្នុងការ

រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើនការចូលរៀន និងប្រសិទ្ធភាពរបស់កម្មវិធីអប់រំកុមារតូចគ្រប់រូបភាពបានធ្វើឱ្យចំណុចដៅនានារបស់អនុវិស័យមិនបានសម្រេច។

អនុវិស័យការអប់រំបឋមសិក្សាមាន ១៤ សកម្មភាព បានបញ្ចប់ ៨ ស្មើនឹង ៥៧,១ ភាគរយ កំពុងអនុវត្ត ៤ ស្មើនឹង ២៨,៦ ភាគរយ និងមិនទាន់បានអនុវត្ត ២ ស្មើនឹង ១៤,៣ ភាគរយ។ ការយកចិត្តទុកដាក់បង្កើនអន្តរាគមន៍ ដើម្បីប្រមូលកុមារជួបការលំបាកឱ្យបានចូលរៀននៅបឋមសិក្សា និងការបង្កើនប្រសិទ្ធភាពបំពេញការងារ និងសមត្ថភាពរបស់គ្រូបង្រៀន ជាបញ្ហាប្រឈមចំពោះមុខដែលត្រូវដោះស្រាយបន្ត។

អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេសមាន ១៣ សកម្មភាព កំពុងអនុវត្ត ៧ ស្មើនឹង ៥៣,៨ ភាគរយ និងមិនទាន់បានអនុវត្ត ៦ ស្មើនឹង ៤៦,២ ភាគរយ។ ភាពយឺតយ៉ាវក្នុងការរៀបចំផែនការគោលនិងសកម្មភាព ដើម្បីអនុវត្តគោលនយោបាយអប់រំបច្ចេកទេស ធ្វើឱ្យការពង្រីកវិសាលភាពរបស់ការអប់រំបច្ចេកទេសនៅទាបជាងការរំពឹងទុក។

អនុវិស័យការអប់រំឧត្តមសិក្សាមាន ១១ សកម្មភាព បានបញ្ចប់ ២ ស្មើនឹង ១៨,២ ភាគរយ កំពុងអនុវត្ត ៦ ស្មើនឹង ៥៤,៥ ភាគរយ និងមិនទាន់បានអនុវត្ត ៣ ស្មើនឹង ២៧,៣ ភាគរយ។ ប្រការនេះទាមទារឱ្យមានការពន្លឿនការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់គុណភាព និងការគ្រប់គ្រងនៅគ្រឹះស្ថានឧត្តមសិក្សា។

អនុវិស័យការអប់រំក្រៅប្រព័ន្ធមាន ៩ សកម្មភាព បានបញ្ចប់ ៦ ស្មើនឹង ៦៦,៦ ភាគរយ និងមិនទាន់បានអនុវត្ត ៣ ស្មើនឹង ៣៣,៤ ភាគរយ។ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីនានារបស់អបរំក្រៅប្រព័ន្ធ និងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធទាមទារការពន្លឿនថែមទៀត។

អនុវិស័យការអភិវឌ្ឍយុវជនមាន ១០ សកម្មភាព បានបញ្ចប់ ៥ ស្មើនឹង ៥០ ភាគរយ កំពុងអនុវត្ត ៣ ស្មើនឹង ៣០ ភាគរយ និងមិនទាន់អនុវត្ត ២ ស្មើនឹង ២០ ភាគរយ។ ប្រការនេះទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការជំរុញដំណើរការរបស់ក្រុមប្រឹក្សាកុមារ និងយុវជន យុវជនស្ម័គ្រចិត្ត និងយុវជនកាយឫទ្ធិ ព្រមទាំងការពង្រីកហេដ្ឋារចនាសម្ព័ន្ធយុវជន។

អនុវិស័យការអប់រំកាយ និងកីឡាមាន ៦ សកម្មភាព បានបញ្ចប់ ៣ ស្មើនឹង ៥០ ភាគរយ និងកំពុងអនុវត្ត ៣ ស្មើនឹង ៥០ ភាគរយ។ ការពង្រឹងសកម្មភាពអប់រំកាយ និងកីឡានៅក្នុង និងក្រៅម៉ោងសិក្សា និងការរៀបចំផែនការគោលស្តីពីការអភិវឌ្ឍកីឡាឆ្ពោះទៅស៊ីហ្គេម ឆ្នាំ ២០២៣ ជាកត្តាអាទិភាព ។

**រូបភាពទី២៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០១៩ (តាមអនុវិស័យ)**




សកម្មភាពគោលនយោបាយដែលបានអនុវត្តចប់សព្វគ្រប់មានដូចជា៖ ការរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ការបង្កើនក្របខណ្ឌបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ការរៀបចំគោលការណ៍អភិបាលកិច្ចល្អនៅគ្រឹះស្ថានមត្តេយ្យសិក្សា ការកែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីការប្រើប្រាស់ថវិកាដំណើរការសាលារៀនសម្រាប់បឋមសិក្សា ការរៀបចំសេចក្តីណែនាំស្តីពីការប្រើប្រាស់កម្រងសំណួរពាក់ព័ន្ធការសិក្សារបស់សិស្ស ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការបង្រៀនភាសាបរទេសសម្រាប់បឋមសិក្សាចាប់ពីថ្នាក់ទី៤ ការធ្វើវិសោធនកម្មនិយាមប្រើប្រាស់បុគ្គលិកអប់រំ ការរៀបចំលិខិតបទដ្ឋានណែនាំអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា ការរៀបចំតួនាទី ភារកិច្ច និងផែនការសកម្មភាពរបស់គណៈកម្មការគ្រប់គ្រងសាលាកុមារមេត្រី ការសាកល្បងអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិក ការរៀបចំផែនការគោលអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ការរៀបចំសេចក្តីណែនាំស្តីពីការជ្រើសរើសនិស្សិតចូលរៀននិងការបញ្ចប់ការសិក្សា ការបង្កើតមហាវិទ្យាល័យអប់រំនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការរៀបចំផែនការសកម្មភាពស្តីពីការពន្លឿនអក្ខរកម្ម ការកែសម្រួលសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ការរៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ ការកែសម្រួលសេចក្តីណែនាំស្តីពីការដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ការកែសម្រួលសេចក្តីណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ផែនការការងាររបស់អនុក្រុមការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធ ការរៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ការរៀបចំក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន និងក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន ការរៀបចំសេវាតម្រង់ទិសវិជ្ជាជីវៈ និងតម្រង់ទិសការសិក្សា ការកែសម្រួលសេចក្តី

ណែនាំស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលយុវជន ការរៀបចំសេចក្ដីណែនាំស្ដីពីការរៀបចំទីធ្លាសម្រាប់ការងារអប់រំកាយនិងកីឡា ការរៀបចំសេចក្ដីណែនាំស្ដីពីការហាត់អប់រំកាយ និងកីឡានៅក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា និងផែនការសកម្មភាពអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍគ្រូបង្រៀន។

ឆ្នាំ២០១៤ ក្រសួងបានបញ្ចប់ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រថវិកា២០១៥-២០១៧ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤។ ដោយឡែក រាជធានីខេត្តទាំង ២៥ បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៥-២០១៧ ក្នុងនោះបានបញ្ចប់រួចរាល់ ៥ ខេត្ត។

ក្រសួងបានបញ្ចប់ និងផ្សព្វផ្សាយផែនការគោលស្ដីពីអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-២០១៨ ព្រមទាំងបានផលិត និងផ្សព្វផ្សាយប្រើប្រាស់សៀវភៅស្ថិតិ និងសូចនាករអប់រំឆ្នាំសិក្សា២០១៣-២០១៤។ ក្រសួងបានរៀបចំបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅឧបករណ៍សម្រាប់ធ្វើអធិការកិច្ចតាមប្រធានបទ និងតាមកាលកំណត់ និងកំពុងសាកល្បងប្រមូលពិន្ទុសិស្សនៅបឋមសិក្សា និងមធ្យមសិក្សា។ ការប្រមូលព័ត៌មានស្ដីពីពិន្ទុសិស្សនៅបឋមសិក្សាទទួលបានកិច្ចសហការជាមួយនឹងភាគីស៊ុយអែត ដើម្បីបម្រើឱ្យតម្រូវការប្រើប្រាស់ ជាពិសេសក្នុងគោលដៅពង្រឹងគុណភាពអប់រំ។ ក្រសួងបានផ្ដួចផ្ដើមអនុវត្តការបញ្ចូលទិន្នន័យតាមប្រព័ន្ធអនឡាញ និងកំពុងធ្វើសមាហរណកម្មក្នុងចំណោមប្រព័ន្ធទិន្នន័យនានា។

សេចក្ដីលម្អិតស្ដីពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ ២០១៤ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី៣។

## ២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

### តារាងទី១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូល | ស្ថានភាព ២០១៣-១៤ | ស្ថានភាព ២០១៤-១៥ | ចំណុចដៅ ២០១៧-១៨ |
|---|---|---|---|
| **គោលនយោបាយទី១** ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | | |
| ១ - ភាគរយកុមារអាយុ ៥ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៩,៩% | ៦១,៤% | ៨០% |
| ២- ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ | ១១៩ | ១០៤ | ១៤៤ |
| ៣- ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ៧ | ៩ | ១៧ |
| **គោលនយោបាយទី២** ៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | | | |
| ៤- អត្រាអក្ខរកម្មយុវជន (អាយុ ១៥-២៤) | ៩២,១% (ឆ្នាំ២០១២) | ៩៣%* (ឆ្នាំ២០១៣) | ៩៧,៥% |

| | | | |
|---|---|---|---|
| ៥- អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥-៤៥) | ៧៧,៦% (ឆ្នាំ២០០៨) | ៨០% (ឆ្នាំ២០១៣) | ៩០,៥% |
| ៦- ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | កំពុងអនុវត្ត ថ្នាក់ទី៣ | លទ្ធផលតេស្ត ថ្នាក់ទី៦៖ ភាសាខ្មែរ ៥២,៥ គណិតវិទ្យា ៤២,៨ | អនុវត្ត ថ្នាក់ទី៨ |
| ៧- ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ | ៦៣១១ នាក់ | ៧១១៧ នាក់ | ៧៣១១ នាក់ |
| ៨- ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របណ្ឌិត | ៨០៨ នាក់ | ៨៣០ នាក់ | ១០៥៨ នាក់ |
| គោលនយោបាយទី៣ ៖ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | |
| ៩- ភាគរយថវិកាកម្មវិធីធៀបនឹងថវិកាសរុបក្រសួងអប់រំ យុវជន និងកីឡា | ១៣,៦៩% (ឆ្នាំ២០១៣) | ២១% | ១០០% |
| ១០- ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី | ៩៣,២% | ៨៦,១៦% | ១០០% |

*ប្រភព៖ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៣

កុមារអាយុ ៥ឆ្នាំបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព ៦១,៤ ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ កើន ១,៥ ភាគរយ ធៀបនឹងឆ្នាំសិក្សា ២០១៣-២០១៤ (ចំណុចដៅ ESP ៦៦ ភាគរយ)។ កត្តាមិនអំណោយផលមួយចំនួនដូចជា ការពង្រីកសេវាពុំទាន់មានវិសាលភាពទូលំទូលាយ កង្វះសាលារៀន ថ្នាក់រៀន គ្រូមត្តេយ្យសិក្សា និងការផ្តល់ធាតុចូលផ្សេងៗមិនបានតាមតម្រូវការ ជាពិសេសចំណាកស្រុកនៅតាមព្រំដែន។

ស្រុកដែលសម្រេចបានអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាយ៉ាងតិច ៨០ ភាគរយ មាន ១០៤ លើ ១៩៧ ក្រុង ស្រុក ខណ្ឌ។ ចំនួនស្រុកបានថយ ១៥ ធៀបនឹងឆ្នាំសិក្សា ២០១៣-២០១៤។

រាជធានី ខេត្តដែលបានសម្រេចអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ មាន ៩ លើ ២៥ រាជធានី ខេត្ត។ ក្នុងនោះ រាជធានីភ្នំពេញ និងខេត្តតាកែវសម្រេចបានលើសពី ៥០ ភាគរយ។ វឌ្ឍនភាពនៃសូចនាករនេះមានការកើនឡើងយឺត ដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀត ឆ្ពោះទៅសម្រេចចំណុចដៅឆ្នាំសិក្សា ២០១៧-២០១៨។

អត្រាអក្ខរកម្មយុវជន (អាយុ ១៥ ដល់ ២៤ឆ្នាំ) បានកើនឡើងពី ៩២,១ ភាគរយ នៅឆ្នាំ ២០១២ ដល់ ៩៣ ភាគរយ នៅឆ្នាំ ២០១៣។ អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ ដល់ ៤៥ឆ្នាំ) បានកើនពី ៧៧,៦ ភាគរយ នៅឆ្នាំ ២០០៨ ដល់ ៨០ ភាគរយ នៅឆ្នាំ ២០១៣។ វឌ្ឍនភាពសូចនាករទាំងពីរនេះទាមទារឱ្យមានការពង្រីកថ្នាក់អក្ខរកម្មវិជ្ជាជីវៈបន្ថែមទៀត។

វង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបានអនុវត្តក្នុងសាលាសំណាកគំរូ ២២០ សិស្ស ៦ ០០០ នាក់។ សិស្សសម្រេចបានលទ្ធផលសិក្សាធៀបនឹងស្តង់ដារមុខវិជ្ជាភាសាខ្មែរ ៥២,៥ ភាគរយ និងគណិតវិទ្យា ៩២,៨ ភាគរយ។ ក្រសួងកំពុងអនុវត្តតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ នៅសាលារៀនសំណាកគំរូ ២០០។ ក្រសួងកំពុងវិភាគលើទិន្នន័យដែលទទួលបាន និងគ្រោងផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែរ រូបវិទ្យា និងគណិតវិទ្យា។

គ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់កើន ៨០៦ នាក់ ធៀបនឹងឆ្នាំសិក្សា ២០១២-២០១៣ ក្នុងនោះគ្រូបង្រៀនឧត្តមសិក្សាសញ្ជាតិខ្មែរកើន ៦០០ នាក់ និងសញ្ជាតិបរទេស ២០៦ នាក់។ គ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របណ្ឌិតកើន ២២ នាក់ ធៀបនឹងឆ្នាំសិក្សា ២០១២-២០១៣ ក្នុងនោះគ្រូបង្រៀនឧត្តមសិក្សាសញ្ជាតិខ្មែរកើន ១៧ នាក់ និងសញ្ជាតិបរទេស ៥ នាក់។

ឆ្នាំ ២០១៤ ភាគរយថវិកាកម្មវិធីធៀបនឹងថវិកាសរុបក្រសួងអប់រំ យុវជន និងកីឡា ស្មើនឹង ២១ ភាគរយ។ ភាគរយការទូទាត់ចំណាយថវិកាកម្មវិធីឆ្នាំ ២០១៤ ស្មើនឹង ៨៦,១៦ ភាគរយ។ អង្គភាពរដ្ឋបាលកណ្តាលទូទាត់បាន ៧៥,២៨ ភាគរយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ៩២,៨៩ ភាគរយ ការងារលទ្ធកម្ម ៥៤,១៩ ភាគរយ និងបៀវត្ស ៩៧,៩២ ភាគរយ។

## ២.១.៣ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤

ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤ បានបង្ហាញពីសកម្មភាព ៥១៦ ត្រូវអនុវត្ត។ គិតត្រឹមខែធ្នូ ឆ្នាំ ២០១៤ សកម្មភាព ៣៨៦ បានបញ្ចប់ ៣៨ បន្តអនុវត្ត និង ៩២ មិនទាន់ចាប់ផ្តើមអនុវត្ត។ អង្គភាព ១៥ បានបញ្ចប់សកម្មភាពរបស់ខ្លួនបាន ១០០ ភាគរយ។ សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ សូមមើលឧបសម្ព័ន្ធទី១ និងទី៤។

**រូបភាពទី៣ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤ (អង្គភាពថ្នាក់ជាតិ)**



## ២.១.៤ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៣- ២០១៤

សន្និបាតអប់រំឆ្នាំ ២០១៤ បានលើកទិសដៅ ១៦៤។ ទិសដៅ ១០០ បានអនុវត្តចប់រួចរាល់ ៥១ កំពុងអនុវត្ត និង ១៣ មិនទាន់បានអនុវត្ត។ អង្គភាព ៧ បានសម្រេចទិសដៅរួចរាល់ ១០០ ភាគរយ។ សេចក្ដីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ ២០១៤ ឧបសម្ព័ន្ធទី២ និងទី៥។

**រូបភាពទី៤ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ ២០១៤ (អង្គភាពថ្នាក់ជាតិ)**




## ២.១.៥ វឌ្ឍនភាពនៃការគ្រប់គ្រង និងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

*កម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០១៥-២០១៧*

កម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០១៥-២០១៧ មានចំនួន ២៧ គម្រោង មានថវិកាសរុប ១៩៨ ២៩២ ០០០ដុល្លារ ក្នុងនោះគម្រោងកំពុងដំណើរការមាន ១៨ និងគម្រោងកំពុងចរចា (ស្នើសុំថ្មី) ៩។

**តារាងទី២ ៖ កម្មវិធីវិនិយោគសាធារណៈឆ្នាំ២០១២-២០១៤ ដល់ឆ្នាំ ២០១៥-២០១៧ (ឯកតាពាន់ដុល្លារ)**

| ឆ្នាំ | សរុបគម្រោងជំនួយ | | គម្រោងកំពុងដំណើរការ | | | | គម្រោងកំពុងចរចា | |
|---|---|---|---|---|---|---|---|---|
| | | | គម្រោងវិនិយោគ | | គម្រោងជំនួយបច្ចេកទេស | | | |
| | គម្រោង | ថវិកា | គម្រោង | ថវិកា | គម្រោង | ថវិកា | ចំនួនគម្រោង | ថវិកាគ្រោង |
| ២០១២-១៤ | ៣៩ | ១៨១ ៦៦៥ | ៧ | ៥៦ ៨៨២ | ១៨ | ៤៧ ៥២៣ | ១៤ | ៧៧ ២៦០ |
| ២០១៣-១៥ | ៤១ | ២៣១ ៨៣៣ | ១ | ១ ១៩០ | ២២ | ១៤១ ៩៧២ | ១៨ | ៨៨ ៦៧១ |
| ២០១៤-១៦ | ២៩ | ២៦៦ ៥៧១ | ២ | ២១ ៥០០ | ១៤ | ១១៦ ៧៩២ | ១៣ | ១២៨ ២៧៨ |
| ២០១៥-១៧ | ២៧ | ១៩៨២៩២ | ៥ | ៤៩ ៥៧០ | ១៣ | ៩៨ ១០៩ | ៩ | ៥០ ៦១៣ |

ថវិកាក្នុងកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០១៥-២០១៧ មានការថយ បើធៀបទៅនឹង ៣ ឆ្នាំកន្លងមក ជាពិសេសគម្រោងកំពុងចរចាថយពី ១៣ គម្រោងក្នុងឆ្នាំ ២០១៤-២០១៦ មកត្រឹម ៩ គម្រោងក្នុងឆ្នាំ ២០១៥-២០១៧។ គម្រោងវិនិយោគ ៥ កំពុងដំណើរការ។

## *ហិរញ្ញប្បទានសហប្រតិបត្តិការ*

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំឆ្នាំ២០១៤ មានថវិកាសរុបប្រមាណ ៨០ លានដុល្លារអាម៉េរិក។ ថវិកានេះមានការកើនឡើងបើធៀបនឹងឆ្នាំ២០១៣ ដោយសារដៃគូអភិវឌ្ឍមួយចំនួនបានបង្កើនថវិការបស់ខ្លួនសម្រាប់ដំណើរការក្នុងឆ្នាំ២០១៤ ដូចជា កម្មវិធីស្បៀងអាហារពិភពលោក និងសហភាពអឺរ៉ុបជាដើម។

**តារាងទី៣ ៖ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ (ឯកតាពាន់ដុល្លារ)**

| លរ | អ្នកផ្តល់ជំនួយ | ចំណាយ ឆ្នាំ២០១២ | ចំណាយ ឆ្នាំ២០១៣ | ចំណាយ ឆ្នាំ២០១៤ | ផែនការ ឆ្នាំ២០១៥ | ផែនការ ឆ្នាំ២០១៦ | ផែនការ ឆ្នាំ២០១៧ |
|---|---|---|---|---|---|---|---|
| ១ | អង្គការស្បៀងអាហារពិភពលោក | ៩ ៤០១ | ១០ ៨៦១ | ២៦ ៦៤៦ | ២៥ ៩២៤ | ១៥ ៧១៥ | 0 |
| ២ | ធនាគារពិភពលោក | ២ ៨៩៨ | ៤ ៧២៩ | ១៣ ២៥០ | ២៧ ៥០០ | ២៦ ២៥០ | 0 |
| ៣ | សហភាពអឺរ៉ុប | ៩ ០៦០ | ៤ ៥២១ | ១២ ៥២៥ | ១៥ ១០៩ | ៣០ ១២៧ | 0 |
| ៤ | ប្រទេសស៊ុយអែត | ៣ ៨៦០ | ១១ ៥៧៦ | ១១ ៣០៣ | ១២ ៦៥៧ | ៤ ៥៤៣ | 0 |
| ៥ | ធនាគារអភិវឌ្ឍអាស៊ី | ៣ ៥៩២ | ៨ ៨៨៤ | ៨ ៦០០ | ៥ ០០០ | ៦០០០ | |
| ៦ | អង្គការយូនីសេហ្វ | ១ ៦៥៦ | ៧ ២១៨ | ៥ ៩៣៩ | ៦៨១ | 0 | 0 |
| ៧ | សាធារណរដ្ឋកូរ៉េ | ៣ ២៦៣ | ១ ៤៥៩ | ១ ៤៥៥ | ១ ០០០ | ៤ ៥០០ | 0 |
| ៨ | ប្រទេសជប៉ុន | 0 | ១ ៦៤១ | ១ ៣៥១ | ៧២២ | 0 | 0 |
| ៩ | ប្រទេសបារាំង | ៤៤៣ | ៤៧៨ | ៣០៩ | 0 | 0 | 0 |
| ១០ | អង្គការយូណេស្កូ | ៣០២ | ២៦៨ | ៣០ | ២០ | 0 | 0 |
| សរុបភាគីផ្តល់ជំនួយចំនួន១០ | | ៣៤ ៩៧៤ | ៥១ ៦៣៤ | ៨១ ៤០៧ | ៨៨ ៦១២ | ៨៧ ១៣៥ | 0 |
| **សរុបភាគីផ្តល់ជំនួយទាំងអស់** | | **៣៨ ១៦៥** | **៥៣ ៨៩២** | **៨១ ៤០៧** | **៩៩ ៣១៣** | **៩៧ ៨៣៥** | **១០ ៧០០** |

*(ប្រភព CDC: ដកស្រង់ចេញពីទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការនៅថ្ងៃទី២៦ខែវិច្ឆិកាឆ្នាំ២០១៤)*

រដ្ឋាភិបាលជប៉ុនបានអនុម័តគម្រោងដែលកម្ពុជាបានលើកស្នើសុំនៅឆ្នាំ២០១៤ សម្រាប់អនុវត្តនៅឆ្នាំ២០១៥ ចំនួន ២ គម្រោងគឺ ១)គម្រោងសាងសង់អគារឧបសម្ព័ន្ធ ដើម្បីពង្រីកតួនាទីរបស់មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា ជប៉ុន គាំទ្រដល់បណ្តាញអាជីវកម្ម និង២)គម្រោងអភិវឌ្ឍធនធានមនុស្សសម្រាប់ធនធានរ៉ែ។ ក្រសួងបានលើកសំណើគម្រោងជំនួយពីប្រទេសចិនចំនួន ៥ គម្រោងរួមមាន ១)គម្រោងលើកកម្ពស់មុខជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅឧត្តមសិក្សា ២)គម្រោងអភិវឌ្ឍកីឡា ៣)កម្មវិធីផ្តល់

អាហារូបករណ៍កម្រិតឧត្តមសិក្សាដល់និស្សិតកម្ពុជា ៤)គម្រោងអភិវឌ្ឍការអប់រំបច្ចេកទេសនៅមធ្យមសិក្សា និង ៥)គម្រោងអភិវឌ្ឍយុវជន។

## *ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិបំពេញការងារនៅតាមអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

ឆ្នាំ ២០១៤ ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិបម្រើការងារនៅអង្គភាពក្រោមឱវាទក្រសួងមាន ១៣ នាក់ ស្មើនឹង ១០៨ នាក់-ខែ និងនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១៨ នាក់។

## *ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ*

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិបានប្រជុំទៀងទាត់តាមត្រីមាស ដើម្បីពិភាក្សាគោលនយោបាយ ការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការបង្ហាញពីវឌ្ឍនភាពសំខាន់ៗ។ ក្រសួង និងដៃគូអភិវឌ្ឍ បានរួមគ្នារៀបចំអង្គវិបស្សនាអប់រំចំនួន ២ លើក នៅខែមករា និងខែវិច្ឆិកា ដើម្បីពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ហាប្រឈមនានា ដែលក្រសួង និងដៃគូអភិវឌ្ឍត្រូវរួមដោះស្រាយ និងបានកំណត់អាទិភាពចម្បងៗសម្រាប់អនុវត្តនៅឆ្នាំ២០១៥។

## *បញ្ហាប្រឈម*

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- សមាហរណកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំទាំងក្នុង និងក្រៅក្រសួងមិនទាន់បានរលូន
- ការប្រមូលស្ថិតិផ្នែកគុណភាព មិនទាន់ឆ្លើយតបតាមតម្រូវការ
- ការកសាងផែនការ និងការគ្រប់គ្រងតាមបែបអនុវិស័យ មិនទាន់បានពេញលេញ
- ថវិកាមិនទាន់ឆ្លើយតបទៅនឹងគោលនយោបាយ
- ការគ្រប់គ្រងផ្អែកលើលទ្ធផលមិនទាន់បានគ្រប់ជ្រុងជ្រោយ
- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃមិនទាន់បានរៀបចំ
- សមត្ថភាពក្នុងការពិនិត្យតាមដាន និងវាយតម្លៃមិនទាន់ឆ្លើយតប
- សកម្មភាពស្រាវជ្រាវ អំពីការអនុវត្តកម្មវិធី និងសកម្មភាពមិនទាន់បានទូលំទូលាយ
- ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិមិនទាន់ដំណើរការបានល្អ
- ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ មិនទាន់ឆ្លើយតបនឹងគោលការណ៍របស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ។

## ២.១.៦ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### *ការលើកកម្ពស់អភិបាលកិច្ចនៅគ្រប់កម្រិត*

ក្រសួងបានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំស្តីពីអភិបាលកិច្ចល្អ សម្រាប់ពង្រឹងការផ្តល់សេវាអប់រំ មានអ្នកចូលរួម ៤១៥ នាក់ ស្រី ១១២ នាក់ និងបានចុះពិនិត្យតាមដាន និងវាយតម្លៃលើការផ្តល់សេវាអប់រំផ្អែកតាមគោលការណ៍អភិបាលកិច្ចល្អនៅក្នុងខេត្ត ១៥។ ក្រសួងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីទស្សនាទាននៃការដឹកនាំ និងគ្រប់គ្រងសាលារៀននៅខេត្តព្រះសីហនុ មានអ្នកចូលរួម ១០០ នាក់ ស្រី ១៧ នាក់។

ក្រសួងបានកែលម្អការផ្តល់សេវាសាធារណៈវិស័យអប់រំ តាមរយៈយន្តការច្រកចេញចូលតែមួយ។ ឆ្នាំ២០១៤ សាលារៀនឯកជន ៧៤ បានសុំអាជ្ញាប័ណ្ណក្នុងនោះ ៥៥ សាលាត្រូវបានក្រសួងទទួលស្គាល់ និងចេញអាជ្ញាប័ណ្ណ ១០ សាលា។ ក្រសួងបានចុះពិនិត្យតាមដានលើការផ្តល់សេវាសាធារណៈវិស័យអប់រំ តាមរយៈយន្តការច្រកចេញចូលតែមួយនៅតាមក្រុង ស្រុក ខណ្ឌគោលដៅក្នុងខេត្តព្រះសីហនុ បាត់ដំបង និងសៀមរាប។

### *ការងារកំណែទម្រង់ការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ*

ក្រសួងបានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារ និងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញក្នុងវិស័យនៅខេត្តបាត់ដំបង មានអ្នកចូលរួម ១៨១ នាក់ ស្រី ១៩ នាក់។ នៅឆ្នាំ ២០១៥ ក្រសួងនឹងផ្ទេរមុខងារមត្តេយ្យសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិខេត្តបាត់ដំបង។

ក្រសួងបានអនុវត្តអនុក្រឹត្យលេខ ៨៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

### *ការងាររៀបចំលិខិតបទដ្ឋាន និងការពង្រឹងការអនុវត្ត*

ក្រសួងបាន ៖

- សម្របសម្រួលការរៀបចំព្រះរាជក្រឹត្យ ២ អនុក្រឹត្យ ៣ ប្រកាស ៨ សេចក្តីសម្រេច ៦ និងសារាចរ ១
- បំប៉នមន្ត្រីអប់រំថ្នាក់ក្រោមជាតិស្តីពីក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម ១៦៦ នាក់ ស្រី ២១ នាក់
- ផ្សព្វផ្សាយអនុសញ្ញាប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើងចំពោះនារីភេទ មានអ្នកចូលរួម ១ ១០០ នាក់ ស្រី ៤៥៤ នាក់

- ផ្សព្វផ្សាយនីតិវិធីនៃការស្នើឬការតវ៉ា ការប្ដឹង និង ដំណោះស្រាយ សម្រាប់អ្នកសិក្សា មាតាបិតា អ្នកអាណាព្យាបាល និងបុគ្គលិកអប់រំ មានអ្នកចូលរួម ១៥០ នាក់ ស្រី ១២ នាក់
- ចុះត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ស្ដីពីការអប់រំ និងលិខិតបទដ្ឋានគតិយុត្តនៅថ្នាក់ក្រោមជាតិ ១៦ ខេត្ត
- ទទួលសំណុំរឿងវិវាទបុគ្គលិកអប់រំក្នុងប្រព័ន្ធតុលាការ ២១ ករណី និងក្រៅប្រព័ន្ធតុលាការ ៤ ករណី ។

*បញ្ហាប្រឈម*

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ក្របខណ្ឌគោលនយោបាយលើការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់មានភាពច្បាស់លាស់ និងស្មុគ្រស្មាញ
- សមត្ថភាពអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមិនទាន់គ្រប់គ្រាន់
- ការយល់ដឹងពីការគ្រប់គ្រងផ្អែកលើគោលការណ៍អភិបាលកិច្ច និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈនៅមានកម្រិត
- ការបញ្ជ្រាបទស្សនាទាននៃការដឹកនាំ និងគ្រប់គ្រងតាមវិធីសាស្ត្រអភិក្រមនៃការដឹកនាំ និងគ្រប់គ្រងមិនទាន់បានទូលំទូលាយ។

## ២.១.៧ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ

*ស្ថានភាពបុគ្គលិកអប់រំ*

បុគ្គលិកអប់រំមាន ១១៣ ៩៨៦ នាក់ ស្រី ៤៨ ៣៤២ នាក់ ស្មើនឹង ៤២,៤ ភាគរយ។ ក្របខណ្ឌគ្រូមត្តេយ្យសិក្សាមាន ៣ ៣២២ នាក់ ស្រី ៣ ២៤៨ នាក់ ស្មើនឹង ៩៧,៧ ភាគរយ ក្របខណ្ឌគ្រូបឋមសិក្សា ៥៨ ១២៤ នាក់ ស្រី ២៦ ៧០១ នាក់ ស្មើនឹង ៤៥,៩ ភាគរយ ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ៣៨ ២០០ នាក់ ស្រី ១៤ ៧១១ នាក់ ស្មើនឹង ៣៨,៥ ភាគរយ ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានអប់រំកាយនិងកីឡា ១ ៩៤៦ នាក់ ស្រី ៣៧៤ នាក់ ស្មើនឹង ១៩,២ ភាគរយ អធិការបឋម ៨២ នាក់ ស្រី ២០ នាក់ ស្មើនឹង ២៤,៤ ភាគរយ អធិការមធ្យម ៤៦ នាក់ ស្រី ១៤ នាក់ ស្មើនឹង ៣០,៤ ភាគរយ និងក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម ១២ ២៦៦ នាក់ ស្រី ៣ ២៧៤ នាក់ ស្មើនឹង ២៦,៧ ភាគរយ។

បុគ្គលិកអប់រំបម្រើការងារនៅថ្នាក់ជាតិ ៣ ០២៣ នាក់ ស្រី ៨៣៧ នាក់ ស្មើនឹង ២៧,៦ ភាគរយ និងថ្នាក់ក្រោមជាតិ ១១០ ៩៦៣ នាក់ ស្រី ៤៧ ៥០៥ នាក់ ស្មើនឹង ៤២,៨ ភាគរយ។

គ្រូបង្រៀនជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតសរុប ៣ ៤៥១ នាក់ ស្រី ១ ៥២៦ នាក់ ស្មើនឹង ៤៤,២ ភាគរយ ក្នុងនោះ គ្រូបង្រៀនជាប់កិច្ចសន្យាចំណោះទូទៅ ១ ៧៣១ នាក់ ស្រី ៩១៩ នាក់ ស្មើនឹង ៥៣ ភាគរយ គ្រូអក្ខរកម្មជាប់កិច្ចសន្យា ១ ២៦៩ នាក់ ស្រី ៤៥៨ នាក់ ស្មើនឹង ៣៦ ភាគរយ មន្ត្រីជាប់កិច្ចសន្យា ១៩ នាក់ ស្រី ១០ នាក់ ស្មើនឹង ៥២,៦ ភាគរយ និងបុគ្គលិកអណ្តែត ៤៣២ នាក់ ស្រី ១៣៩ នាក់ ស្មើនឹង ៣២,១ ភាគរយ។ គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប ១៩ ០១៦ នាក់ ស្រី ៦៦៥៣ នាក់ ក្នុងនោះគ្រូបង្រៀនពីរវេន ១៧ ០៣៥ នាក់ ស្រី ៥ ៨០១ នាក់ ស្មើនឹង ៣៤ ភាគរយ និងគ្រូបង្រៀនថ្នាក់គួប ១ ៩៨១ នាក់ ស្រី ៨៥២ នាក់ ស្មើនឹង ៤៣ ភាគរយ។

## *ការជ្រើសរើសបុគ្គលិកអប់រំ*

ក្រសួងបាន ៖

- ប្រកាសតែងតាំងកម្មសិក្សាគ្រូគ្រប់កម្រិត ៤ ៣៣២ នាក់ ស្រី ២ ៧៥៨ នាក់ ស្មើនឹង ៦៣,៦ ភាគរយ ក្នុងនោះគ្រូមត្តេយ្យសិក្សា ១៩៤ នាក់ ស្រី ១៩២ នាក់ ស្មើនឹង ៩៨,៩ ភាគរយ គ្រូបង្រៀនកម្រិតបឋម ២២០៦ នាក់ ស្រី ១ ៥៣៧ នាក់ ស្មើនឹង ៦៩,៦ ភាគរយ គ្រូបង្រៀនកម្រិតមូលដ្ឋាន ១ ៣៥៤ នាក់ ស្រី ៧៧៥ នាក់ ស្មើនឹង ៥៧,២ ភាគរយ គ្រូបង្រៀនកម្រិតឧត្តម ៥៥០ នាក់ ស្រី ២៥១ នាក់ ស្មើនឹង ៤៥,៦ ភាគរយ និងគ្រូបង្រៀនឧត្តមសិក្សា ២៥ នាក់ ស្រី ៣ នាក់ ស្មើនឹង ១២ ភាគរយ
- តាំងស៊ប់គ្រូបង្រៀនកម្រិតឧត្តម ១ ៥៨៦ នាក់ ស្រី ៤៨១ នាក់ ស្មើនឹង ៣០,៣ ភាគរយ គ្រូបង្រៀនកម្រិតមូលដ្ឋាន ៣ ៤២៣ នាក់ ស្រី ១ ៦៥៦ នាក់ ស្មើនឹង ៤៨,៣ ភាគរយ និងគ្រូបង្រៀនកម្រិតបឋម ២ ១៣៩ នាក់ ស្រី ៧៤៤ នាក់ ស្មើនឹង ៣៤,៧ ភាគរយ
- អនុញ្ញាតច្បាប់លំហែមាតុភាពជូនបុគ្គលិកអប់រំ ២ ៦៩៣ នាក់ ច្បាប់ព្យាបាលជំងឺ ៣៩ នាក់ ស្រី ១៦ នាក់ ស្មើនឹង ៤១ ភាគរយ និងអនុញ្ញាតច្បាប់មានធុរៈផ្ទាល់ខ្លួន ៣១ នាក់ ស្រី ១៨ នាក់ ស្មើនឹង ៥៨ ភាគរយ។ ឧទ្ទេសនាមបុគ្គលិកអប់រំទៅបង្រៀនសិស្សពិការនៅអង្គការផ្សេងៗ ២២៨ នាក់ ស្រី ១១០ នាក់ ស្មើនឹង ៤៨,២ ភាគរយ។ ច្បាប់ដាក់បុគ្គលិកអប់រំឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ១ ២៩៤ នាក់ ស្រី ៤១៤ នាក់ ស្មើនឹង ៣២ ភាគរយ អនុញ្ញាតឱ្យចូលបម្រើការងារវិញ ៥២៥ នាក់ ស្រី ១៥៣ នាក់ ស្មើនឹង ២៩,១ ភាគរយ។ លុបឈ្មោះបុគ្គលិកអប់រំ ១ ០៣០ នាក់ ស្រី ៣១៥ នាក់ ស្មើនឹង ៣០,៦ ភាគរយ និងអនុញ្ញាតច្បាប់ដាក់បុគ្គលិកអប់រំឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ៩៦ នាក់ ស្រី ១១ នាក់ ស្មើនឹង ១១,៤ ភាគរយ។

បុគ្គលិកអប់រំបានផ្លាស់ប្តូរកន្លែងបម្រើការងារក្នុងក្របខណ្ឌក្រសួង ៧៨៦ នាក់ ស្រី ២៩៦ នាក់ ស្មើនឹង ៣៧,៦ ភាគរយ និងផ្ទេរក្របខណ្ឌចេញទៅក្រសួងផ្សេង ១៨៧ នាក់ ស្រី ៤១ នាក់ ស្មើនឹង ២១,៩ ភាគរយ។

បុគ្គលិកអប់រំដែលអាយុចូលនិវត្តន៍ និងស្ម័គ្រចិត្ត ២២១០ នាក់ ស្រី ៦១៣ នាក់ ស្មើនឹង ២៧,៧ ភាគរយ។ មន្ត្រីគ្រប់គ្រងត្រូវបានតែងតាំង និងផ្ទេរភារកិច្ច ២៤ នាក់ ស្រី ៣ នាក់ ស្មើនឹង ១២,៥ ភាគរយ។

គ្រូបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកមាន ៣១ ៩៩៤ នាក់ ស្រី ១១ ៤៩៣ នាក់ ស្មើនឹង ៣៥,៩ ភាគរយ។

## *ការលើកទឹកចិត្តបុគ្គលិកអប់រំ*

ក្រសួងបាន៖

- រៀបចំការប្រឡងប្រជែងផ្លាស់ប្តូរក្របខណ្ឌផ្ទៃក្នុងបុគ្គលិកអប់រំក្របខណ្ឌ (ក) ៣០០ នាក់ ស្រី ៨៣ នាក់ ស្មើនឹង ២៧,៦ ភាគរយ និងក្របខណ្ឌ (ខ) ២០០ នាក់ ស្រី ៨៥ នាក់ ស្មើនឹង ៤២,៥ ភាគរយ
- ដំឡើងឋានន្តរស័ក្តិជូនបុគ្គលិកអប់រំ ៨ នាក់ ស្រី ២ នាក់ ស្មើនឹង ២៥ ភាគរយ ដំឡើងថ្នាក់តាមសញ្ញាបត្រដែលខ្ពស់ជាងក្របខណ្ឌ ៤១៣ នាក់ ស្រី ១០៦ នាក់ ស្មើនឹង ២៥,៦ ភាគរយ ដំឡើងថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិកអប់រំក្រោមឱវាទទីស្តីការ និងរាជធានី ខេត្ត ២៥ ០២០ នាក់ ស្រី ៩ ៧៦៥ នាក់ ស្មើនឹង ៣៩ ភាគរយ ដំឡើងថ្នាក់តាមសញ្ញាបត្រជូនបុគ្គលិកអប់រំនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១៣ នាក់ ស្រី ១ នាក់ និងតាមវេនជ្រើសរើស ៣២៦ នាក់ ស្រី ៦៩ នាក់ ស្មើនឹង ២១,១ ភាគរយ
- រៀបប្រាក់បៀវត្សជូនមន្ត្រីដែលទំនេរគ្មានបៀវត្សចូលបម្រើការងារវិញ ១៩ នាក់ ស្រី ៧ នាក់ កែសម្រួលបៀវត្ស ៥០៥ នាក់ ស្រី ៣០ នាក់ រៀបចំបៀវត្សតាមប្រកាសដំឡើងថ្នាក់ ២ ៨៦៨ នាក់ ស្រី ៧៩៥ នាក់ រៀបចំបៀវត្សមន្ត្រីដែលផ្លាស់ពីរាជធានី ខេត្តមកក្រោមឱវាទក្រសួង ៨៣ នាក់ ស្រី ២២ នាក់ និងរៀបប្រាក់បៀវត្សមន្ត្រីតែងតាំងក្នុងមុខតំណែង ២៣ នាក់ ស្រី ៤ នាក់
- រៀបចំបៀវត្សជូនគ្រូចេញថ្មីគ្រប់កម្រិត ៤ ២៦៩ នាក់ ស្រី ២ ៧៤៣ នាក់ ស្មើនឹង ៦៤,២ ភាគរយ ក្នុងនោះគ្រូមត្តេយ្យសិក្សា ១៩៧ នាក់ ស្រី ១៩២ នាក់ គ្រូបង្រៀនកម្រិតបឋម ២ ២០៦ នាក់ ស្រី ១ ៥៣៧ នាក់ ស្មើនឹង ៦៩,៦ ភាគរយ គ្រូបង្រៀនកម្រិតមូលដ្ឋាន ១ ៣២៨ នាក់ ស្រី ៧៦៧ នាក់ ស្មើនឹង ៥៧,៧ ភាគរយ និងគ្រូបង្រៀនកម្រិតឧត្តម ៥៣៨ នាក់ ស្រី ២៤៧ នាក់ ស្មើនឹង ៤៥,៩ ភាគរយ
- ផ្តល់គ្រឿងឥស្សរិយយសការងារឆ្នាំសិក្សា ២០១១-២០១២ ជូនបុគ្គលិកអប់រំ ១ ៩៨២ នាក់ ស្រី ២៤,២ ភាគរយ។ លើកសរសើរអង្គភាពមានស្នាដៃការងារឆ្នាំសិក្សា ២០១២-២០១៣ ចំនួន ៣២៣ ក្នុងនោះទង់លេខ ១ ចំនួន ៧៧ លេខ ២ ចំនួន ៩៣ និងប័ណ្ណសរសើរ ១៥៣។ សំណើសុំគ្រឿងឥស្សរិយយសការងារឆ្នាំសិក្សា ២០១៣-២០១៤ ជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៨ ៦៧៩ នាក់ ស្រី ៣៥,២ ភាគរយ
- លើកសរសើរជូនអង្គភាពមានស្នាដៃការងារឆ្នាំសិក្សា ២០១៣-២០១៤ ចំនួន ៣៨៤ អង្គភាព និងលិខិតសរសើរជូនលោកគ្រូ អ្នកគ្រូ ៧៨១ នាក់ ស្រី ១៦,៥ ភាគរយ ដែលបានស្ម័គ្រចិត្តជួយបង្រៀនថ្នាក់បំប៉នសម្រាប់បេក្ខជនត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

*ការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ*

ក្រសួងបាន ៖

- បញ្ជូនមន្ត្រីអប់រំទៅបណ្តុះបណ្តាលក្រៅប្រទេស ថ្នាក់បណ្ឌិត ៩ នាក់ ស្រី ២ នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១២ នាក់ ស្រី ១ នាក់ និងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមក្នុងប្រទេស ៥០២ នាក់ ស្រី ១៣៩ នាក់ ស្មើនឹង ២៧,៦ ភាគរយ
- កែលម្អនិយាមប្រើប្រាស់បុគ្គលិក និងដាក់ឱ្យអនុវត្តជាផ្លូវការ
- រៀបចំនីតិវិធីនិងឧបករណ៍សម្រាប់វាយតម្លៃការបំពេញការងារបុគ្គលិក។

*បញ្ហាប្រឈម*

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការគ្រប់គ្រងក្របខណ្ឌបុគ្គលិកនៅតាមអង្គភាព និងគ្រឹះស្ថានសិក្សាមួយចំនួនពុំទាន់មានភាពសុក្រឹត
- ការបង្កើនក្របខណ្ឌបុគ្គលិកអប់រំប្រចាំឆ្នាំមិនទាន់ឆ្លើយតបនឹងកង្វះបុគ្គលិកអប់រំ
- ការផ្សព្វផ្សាយនិងចាត់តាំងអនុវត្តគោលការណ៍ និងលិខិតបទដ្ឋានពាក់ព័ន្ធការងារគ្រប់គ្រង និងប្រើប្រាស់បុគ្គលិកមិនទាន់បានទូលំទូលាយ
- ការពង្រាយគ្រូពីសាលាលើសទៅសាលាខ្វះគ្រូមានការលំបាក
- ការគាំទ្រ និងឧបត្ថម្ភជីវភាពគ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកមិនទាន់ឆ្លើយតប
- សមត្ថភាពមន្ត្រីគ្រប់គ្រងនៅគ្រប់កម្រិត និងសាលារៀនមិនទាន់ឆ្លើយតប
- ការអនុវត្តផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពមិនទាន់បានគ្រប់ជ្រុងជ្រោយ
- ការអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងារបុគ្គលិក មានវិសាលភាពតូច
- បច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិកមិនទាន់បានកែលម្អ។

## ២.១.៨ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ការងារហិរញ្ញកិច្ច*

ឆ្នាំ២០១៤ ក្រសួងបានចំណាយថវិកាកម្មវិធី ថវិកាមិនមែនកម្មវិធី និងបោះផ្សាយអាណត្តិបើកប្រាក់សរុបចំនួន ១ ២៩២ ៩០៥ ៥៩៩ ៨៩០ រៀល ស្មើនឹង ៨៩,៨៣ ភាគរយ នៃឥណទានកែតម្រូវសរុប ១ ៣៨៣ ६២៦ ८៥៥ ८៥០ រៀល។ រដ្ឋបាលកណ្តាលអនុវត្តថវិកាមិនមែនកម្មវិធី ៧៨,៥០ ភាគរយ និងថវិកាកម្មវិធី ៧៥,២៨ ភាគរយ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តអនុវត្តថវិកាមិនមែនកម្មវិធីបាន ៩២,៩៣ ភាគរយ និងថវិកាកម្មវិធី ៩២,៨៩ ភាគរយ។

ក្រសួងបាន ៖

- សម្របសម្រួលបើកគណនីធនាគារដល់សាលារៀនក្នុងរាជធានី ខេត្ត ១៥ សម្រាប់ការអនុវត្តកម្មវិធីជំនួយដើម្បីកែលម្អសាលារៀនក្នុងឆ្នាំសិក្សា២០១៣-២០១៤ និងឆ្នាំសិក្សា២០១៤-២០១៥ នៅធនាគារអេស៊ីលីដា និងបន្តបើកគណនីឱ្យគ្រប់សាលារៀនទូទាំងប្រទេសក្នុងឆ្នាំ២០១៥
- កំពុងរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមព័ត៌មានវិទ្យា និងជ្រើសរើសអង្គភាពថវិកានៅរដ្ឋបាលកណ្តាល ៣ និងរាជធានី ខេត្ត ៣ ដើម្បីដំណើរការសាកល្បងក្នុងឆ្នាំ ២០១៥
- ផ្សព្វផ្សាយអនុក្រឹត្យថ្មីលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៤ ស្តីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ
- លើកសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលិខិតលេខ ១០៦ អយក.ហវ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ដើម្បីសុំកែសម្រួលប្រកាសអន្តរក្រសួង និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងនីតិវិធីចំណាយ និងស្នើសុំលើកគម្រោងចំណាយថវិកាឆ្នាំ២០១៥ ដោយផ្អែកតាមសេចក្តីព្រាងថ្មីនៃអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ តាមលិខិតលេខ ១៩៩៩ អយក.ហវ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្សព្វផ្សាយគោលការណ៍ណែនាំនីតិវិធីនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៥ ដោយមានការចូលរួមពីរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- លទ្ធកម្មទំនិញធ្វើការដេញថ្លៃ និងចុះកិច្ចសន្យាចំនួន ៣៤ កិច្ចសន្យា ដែលមានទឹកប្រាក់សរុប ៥៥ ៤៨៥ ១៦៩ ៧១១,៥៥ រៀល
- លទ្ធកម្មសំណង់ធ្វើការដេញថ្លៃនិងចុះកិច្ចសន្យាចំនួន ១៦ កិច្ចសន្យា ដែលមានទឹកប្រាក់សរុប ៣៥ ៥៦៧ ៨០៧ ៧០៥ រៀល
- លទ្ធកម្មសេវាកម្មធ្វើការដេញថ្លៃ និងចុះកិច្ចសន្យាចំនួន ២ កិច្ចសន្យាដែលមានទឹកប្រាក់សរុប ១១៥ ០០០ ០០០ រៀល
- សន្សំថវិកាពីកិច្ចលទ្ធកម្មចំនួន ៣៩ ៥៦១ ៦១៣ ៥៦១ រៀល ធៀបទៅនឹងផែនការលទ្ធកម្មដែលមានទឹកប្រាក់សរុប ១១៣ ១៥១ ១៣០ ០០០ រៀល។

## *ការសាងសង់*

ក្រសួងបាន ៖

- កំពុងសាងសង់អគាររដ្ឋបាលបន្ថែម ១ ខ្នង មាន ៧ ជាន់ សម្រាប់ ៩ នាយកដ្ឋានក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា សម្រេចបាន ៩៨ ភាគរយ
- ដាក់ឱ្យប្រើប្រាស់អគារសិក្សា ១ ខ្នង ៥ ជាន់ មាន ៤៨ បន្ទប់ នៅវិទ្យាស្ថានជាតិអប់រំ
- ដាក់ឱ្យប្រើប្រាស់ហោដ្ឋារចនាសម្ព័ន្ធកីឡា ដែលបានជួសជុលកែលម្អនៅពហុកីឡដ្ឋានជាតិ
- ដាក់ឱ្យប្រើប្រាស់ហោដ្ឋារចនាសម្ព័ន្ធអប់រំនៅវិទ្យាល័យ **ហ៊ុន សែន** កំចាយមារ និង **ជា ស៊ីម** កំចាយមារ

- ដាក់ឱ្យប្រើប្រាស់ផ្ទះសំណាក់សាស្ត្រាចារ្យ ១ អគារ អគារសិក្សា ២៧ ខ្នង អន្តេវាសិកដ្ឋាន ៦ ខ្នង នៅតាមបណ្ដារាជធានី ខេត្ត
- លើកកម្ពស់សមត្ថភាពមន្ត្រីអប់រំលើការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ១ ៧១៩ នាក់ ស្រី ១៥ ភាគរយ
- ដាក់ឱ្យប្រើប្រាស់អគារធនធាន អន្តេវាសិកដ្ឋាន ១៧ កន្លែង នៅតាមបណ្ដារាជធានី ខេត្ត
- កំពុងសាងសង់អគារសិក្សាសម្រាប់វិទ្យាល័យ អនុវិទ្យាល័យ នៅក្នុងបរិវេណសាលាបឋមសិក្សា អន្តេវាសិកដ្ឋាន បង្គន់អនាម័យ អណ្ដូងទឹក និងផ្ទះសំណាក់គ្រូ ២៤ ទីតាំងសម្រេចបាន ៥០ ភាគរយ
- ចុះសិក្សាទីតាំងតាមរាជធានី ខេត្តចំនួន ៦០ ភាគរយ តាមគម្រោងគាំទ្រវិស័យអប់រំទី២។

សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** មាន ៣ ៦២២ ខ្នង ស្មើនឹង ១៨ ៨៨៣ បន្ទប់ គិតត្រឹមថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៤។

### *ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*

ក្រសួងបានៈ

- ប្រមូលចំណូល និងបង់ចូលថវិការដ្ឋតាមរយៈការជួលទីតាំងមានទឹកប្រាក់សរុប ៩៥ ០៨០ ដុល្លារ និង ១៨៨ ៥០០ ០០០រៀល
- រៀបចំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ១៩ ទីតាំង ក្នុងចំណោម ៣៣ ទីតាំង
- ពិនិត្យការងារជួសជុលរថយន្ត ១៣៩ ករណី ម៉ូតូ ៥ ករណី ធ្វើស្លាកលេខរថយន្ត ២ គ្រឿង និងម៉ូតូ ៣៦៨ គ្រឿង ក្នុងនោះបានជួសជុលរថយន្ត ២២ គ្រឿង ប្រើកញ្ចប់ថវិកាលទ្ធកម្មនៅយានដ្ឋាន Ford និង e-garage អស់ថវិកាសរុប ១១៤ ១៦១ ១១០ រៀល
- នាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ១៦ លើក និងបានជម្រះសម្ភារៈ និងសង្ហារិម ១៣៦ មុខ ស្មើនឹង ១ ៤០៧ ឯកតា
- បានប្រមូលទិន្នន័យអចលនទ្រព្យឆ្នាំ២០១៣ រួចរាល់ មានទីតាំងសរុប ៨ ៩៨៧ (ទីតាំងក្នុងវត្ត ១២៦០ កន្លែង និងទីតាំងអប់រំ ៧ ៧២៧ កន្លែង) ក្នុងនោះ ១ ៦៥៦ កន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងមានវិវាទ ៣២០ ករណី
- ជម្រះអគារចាស់ៗចេញពីបញ្ជីសារពើភ័ណ្ឌដូចជាអគារ ១៦ ខ្នង (ខេត្តកណ្ដាល ៩ ខ្នង និងរាជធានីភ្នំពេញ ៧ ខ្នង)
- ពិនិត្យប្រគល់ និងទទួលចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តរតនគិរី និងខេត្តព្រៃវែង
- បំប៉នសមត្ថភាពស្ដីពីការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋដល់អង្គភាពរដ្ឋបាលកណ្ដាល ៧៣ នាក់ ស្រី ១៨ នាក់ នាយកសាលា ១ ០៣៥ នាក់ ស្រី ៦៩ នាក់។

## *ការពង្រឹងសវនកម្មផ្ទៃក្នុង*

ក្រសួងបាន ៖

- ធ្វើកម្មសិក្សាសវនកម្មលើការគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធីនៅថ្នាក់ក្រោមជាតិ ៧០០ សវនដ្ឋាន ដែលក្នុងនោះមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១៦ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៤ សាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត ១២ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ៨០ និងសាលារៀនចំណោះទូទៅ ៥៨៨
- ធ្វើកម្មសិក្សាសវនកម្មសាកល្បងអំពីការគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធី និងមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព នៅអង្គភាពថ្នាក់ជាតិ ១២ វិទ្យាស្ថាន ១ និងសាកលវិទ្យាល័យ ១ និងអំពីការប្រើប្រាស់ថវិកាគម្រោងគាំទ្រវិស័យអប់រំទី២ នៅ ៣ អង្គភាព
- សម្រង់ព័ត៌មាន និងទិន្នន័យនៅតាមសវនដ្ឋានដែលគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធីជំនួយកែលម្អសាលារៀន ១២ ក្នុងនោះ ថ្នាក់ជាតិ ៦ និងថ្នាក់ក្រោមជាតិ ១៦
- អនុវត្តសាកល្បងពិនិត្យតាមដានការបំពេញការងារសវនកម្មផ្ទៃក្នុង នៅតាមសវនដ្ឋានថ្នាក់ក្រោមជាតិ និងសាលារៀន ១០១ សវនដ្ឋាន ក្នុងនោះការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ៩ និងសាលារៀនចំណោះទូទៅ ៩២
- ប្រមូលព័ត៌មាន ស្ដីពីបាតុភាពអសកម្មពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ថវិកាដែលកើតមានឡើងនៅថ្នាក់ក្រោមជាតិ និងសាលារៀន ៩ ករណី។

## *ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ*

ក្រសួងបាន

- ធ្វើអធិការកិច្ចលើការអនុវត្តច្បាប់ បទប្បញ្ញត្តិ វិន័យហិរញ្ញវត្ថុ ប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋគ្រប់ជំពូក ការគ្រប់គ្រងបុគ្គលិក និងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១០ ការិយាល័យអប់រំ យុវជន និង កីឡាក្រុង ស្រុក ខណ្ឌ ៥២ គ្រឹះស្ថានសិក្សា ២៧៣ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ១ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត ៥
- ពិនិត្យឡើងវិញលើការកែលម្អតាមអនុសាសន៍នៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ៥ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ១៤ គ្រឹះស្ថានសិក្សា ៧២ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៣
- បំប៉ននីតិវិធីស្រាវជ្រាវ ដោះស្រាយទំនាស់ និងផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ មានអ្នកចូលរួម ១១០ នាក់ ស្រី ២៤ នាក់
- ទទួលពាក្យបណ្ដឹង ២៧ ករណី ក្នុងនោះបានចុះស្រាវជ្រាវ ២២ ករណី
- ធ្វើវិមជ្ឈការ និងទទួលរបាយការណ៍ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ៥ ករណី។

ការធ្វើអធិការកិច្ច និងពិនិត្យឡើងវិញលើការកែលម្អតាមអនុសាសន៍ខាងលើ បានជំរុញឱ្យមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំយុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាទាំងអស់ អនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដោយយកចិត្តទុកដាក់ និងទទួលបានលទ្ធផលវិជ្ជមាន។ ទន្ទឹមនឹងនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា ការចុះហត្ថលេខាលើគោលការណ៍ចំណាយ ឯកសារពាក់ព័ន្ធចំថ្ងៃផ្ទេរសិទ្ធិ និងថ្ងៃឈប់សម្រាក ទព្វសម្ភារមួយចំនួនមិនទាន់បានបិទស្លាកសម្គាល់។

### បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ដំណើរការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងទម្រង់របាយការណ៍មិនទាន់បានអនុវត្ត
- ការកែសម្រួលលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងនីតិវិធីចំណាយមិនទាន់បានបញ្ចប់
- ឧបករណ៍សម្រាប់ព្យាករណ៍កញ្ចប់ថវិកាមិនទាន់បានសុក្រឹតនិងជឿទុកចិត្ត
- អង្គភាពប្រើប្រាស់មិនមានបទពិសោធក្នុងការរៀបចំលក្ខណៈបច្ចេកទេស និងតម្រូវការធ្វើឱ្យអង្គភាពលទ្ធកម្មមានការលំបាកក្នុងការរៀបចំឯកសារ
- អង្គភាពជំនាញមានតម្រូវការឆាប់រហ័ស តែតាមកិច្ចលទ្ធកម្មត្រូវធ្វើតាមដំណាក់កាល
- អគារទ្រុឌទ្រោមច្រើនទាមទារការជួសជុល និងសាងសង់ថ្មី
- អ្នកស្នាក់នៅលើដីសាធារណៈរបស់រដ្ឋពុំព្រមចុះកិច្ចសន្យាស្នាក់នៅបណ្ដោះអាសន្ន
- ការធ្វើប្លង់កម្មសិទ្ធិអចលនទ្រព្យ ជួបការលំបាក
- ការជម្រះដី និងអគារចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រើរយៈពេលយូរ
- សមត្ថភាពមន្ត្រីពុំទាន់ឆ្លើយតបទៅនឹងនីតិវិធីសវនកម្មលើថវិកាកម្មវិធី
- ការងារសវនកម្មផ្ទៃក្នុងមិនទាន់បានផ្សព្វផ្សាយឱ្យបានគ្រប់សវនដ្ឋាន
- ស្តង់ដារអធិការកិច្ចថ្នាក់ជាតិមិនទាន់បានរៀបចំ
- បណ្ដឹងតវ៉ាពាក់ព័ន្ធវិស័យអប់រំមួយចំនួនមិនបានដោះស្រាយតាមនីតិវិធី។

## ២.១.៩ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ទាំង ៨ ចំណុច

| អាទិភាពកំណែទម្រង់ | វឌ្ឍនភាពសំខាន់ៗ ឆ្នាំ ២០១៤ |
|---|---|
| ការកែលម្អប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំ | - ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច<br>- ការផ្ដួចផ្ដើមរៀបចំសាលារៀនជំនាន់ថ្មី<br>- ការសាងសង់សាលាមធ្យមសិក្សាថ្មី និងសាកល្បងវិទ្យាល័យគំរូ<br>- ការបង្កើនអាហារូបករណ៍ដល់សិស្សក្រីក្រ<br>- ការរៀបចំផែនការសកម្មភាពស្តីពីការអភិវឌ្ឍគ្រូបង្រៀន<br>- ការរៀបចំក្របខណ្ឌកម្មវិធីសិក្សា |

| | |
|---|---|
| ការគ្រប់គ្រងបុគ្គលិក | - ការបើកប្រាក់បៀវត្សតាមធនាគារ<br>- ការបង្កើនប្រាក់បៀវត្សបុគ្គលិកអប់រំ<br>- ការដាក់ឱ្យអនុវត្តនិយាមប្រើប្រាស់បុគ្គលិក (ថ្មី)<br>- ការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងារ |
| កំណែទម្រង់ការប្រឡង | - ការផ្ទេរការទទួលខុសត្រូវការប្រឡងថ្នាក់ទី៩ ដល់ថ្នាក់ក្រោមជាតិ<br>- កំណែទម្រង់ការប្រឡងថ្នាក់ទី១២ |
| ការផ្តល់ជំនាញបច្ចេកទេសនិង ជំនាញទន់ដល់យុវជន | - ការរៀបចំផែនការសកម្មភាពស្តីពីការអភិវឌ្ឍយុវជន<br>- ការកសាងម៉ូឌុល និងការបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលយុវជន |
| កំណែទម្រង់ឧត្តមសិក្សា | - ការរៀបចំចក្ខុវិស័យឧត្តសិក្សា ២០៣០<br>- ការផ្ទេរសិទ្ធិឱ្យគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវការចេញសញ្ញាបត្រ<br>- ការរៀបចំផែនការយុទ្ធសាស្ត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសកម្មភាពស្រាវជាវ |
| ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | - ការដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងលេខ ៥០៨<br>- ការផ្ទេរការទទួលខុសត្រូវដល់មន្ទីរក្នុងរៀបចំ និងអនុវត្តថវិកាឆ្នាំ ២០១៥<br>- ថវិកាអប់រំកើនដល់ ១៧ ភាគរយ នៃថវិកាជាតិ<br>- ការបង្កើតអង្គភាពលទ្ធកម្ម<br>- ការពិនិត្យឡើងវិញការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ការអប់រំកាយនិងកីឡាដើម្បីត្រៀមឆ្ពោះទៅកីឡាស៊ីហ្គេម ឆ្នាំ ២០២៣ | - ការអនុម័តគោលនយោបាយស្តីការអប់រំកាយ និងកីឡា<br>- ការបង្កើតគណៈកម្មការគ្រប់គ្រងពហុកីឡដ្ឋានជាតិអូឡាំពិក<br>- ការបង្កើនប្រាក់រង្វាន់សម្រាប់ជ័យលាភី |
| ការបង្កើតធនាគារខួរក្បាលសម្រាប់វិស័យអប់រំ | - ការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំ និងលេខាធិការដ្ឋាន<br>- ការចូលរួមរៀបចំផែនការសកម្មភាពស្តីពីកីឡា និងគ្រូបង្រៀន |

## ២.២ លទ្ធផលតាមអនុវិស័យ

### ២.២.១ អនុវិស័យ ការអប់រំកុមារតូច

#### ក. លទ្ធផលសម្រេចបាន

#### ក.១ ការធានាសមធម៌នៃការទទួលបានការអប់រំ

ឆ្នាំសិក្សា២០១៤-២០១៥ សាលាមត្តេយ្យសិក្សារដ្ឋមាន ៣ ៤៤៣ កើន ២៥៩ (សាលាមត្តេយ្យសិក្សាដាច់ដោយឡែក ២៤៦ កើន ៣៨) មត្តេយ្យសិក្សាឯកជន ២៣៥ កន្លែង កើន ១៤ កន្លែង និងមត្តេយ្យសិក្សាសហគមន៍ ២ ៥៤៦ កន្លែង កើន ៣២៦ កន្លែង មានទីតាំងក្នុង ៩៥៩ ឃុំ សង្កាត់ក្នុងចំណោម ១ ៦៣៣ ឃុំ សង្កាត់។ ជារួមសាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៦ ២២៤ សាលា/កន្លែង កើន ៥៩៩។

*ប្រការនេះបានជួយឱ្យកុមារដល់វ័យសិក្សាបានចូលរៀនត្រឹមត្រូវតាមអាយុ ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សានៅបឋមសិក្សា។*

ថ្នាក់មត្តេយ្យសិក្សាគ្រប់ប្រភេទមាន ៨ ៩១៨ កើន ៥២០ ក្នុងនោះថ្នាក់មត្តេយ្យសិក្សារដ្ឋ ៥ ២៧៣ កើន ៣៩៤ មត្តេយ្យសិក្សាសហគមន៍ ២ ៦៦៦ កើន ២៣៤ និងមត្តេយ្យសិក្សាឯកជន ៩៧៩ ថយ ៥៨។

កុមារអាយុពី ០ ទៅក្រោម ៦ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ៣៦០ ០៤១ នាក់ ស្មើនឹង ១៩,៥ ភាគរយ នៃចំនួនប្រជាជនអាយុពី ០ ទៅក្រោម ៦ឆ្នាំ ស្រី ១៨២ ២៩៤ នាក់ ស្មើនឹង ៥០,៦ ភាគរយ។

កុមារអាយុ ៣ឆ្នាំមាន ៥០ ៤៣៨ នាក់ ស្មើនឹង ១៦,៦ ភាគរយ នៃចំនួនប្រជាជនអាយុ ៣ឆ្នាំ ស្រី ២៥ ៨៥៩ នាក់ ស្មើនឹង ៥១,២ ភាគរយ កើន ៧៣៧ នាក់ ស្រី ៤៥៦ នាក់។

កុមារអាយុ ៤ឆ្នាំមាន ៨៥ ៤៥៩ នាក់ ស្មើនឹង ២៩ ភាគរយ នៃចំនួនប្រជាជនអាយុ ៤ឆ្នាំ ស្រី៤៣ ២១៩ នាក់ ស្មើនឹង ៥០,៥ ភាគរយ កើន ១៤ ៥៦៤ នាក់ ស្រី ៧ ២៧៩ នាក់។

កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាព ១៧៧ ០៧៧ នាក់ ស្មើនឹង ៦១,៤ ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ (ចំណុចដៅ ESP ៦៦ ភាគរយ) ស្រី ៨៩ ១៣០ នាក់ ស្មើនឹង ៥០,៣ ភាគរយ កើន ៦ ៥៥៦ នាក់ ស្រី ៦ ៤៥១ នាក់។

រូបភាពទី៥ ៖ លទ្ធផលធៀបនឹងចំណុចដៅ ESP ឆ្នាំសិក្សា២០១៤ -២០១៥



កុមារបានទទួលសេវាអប់រំកុមារតូចតាមរាជធានី ខេត្ត មានការកើនឡើងជាបន្តបន្ទាប់បើធៀបនឹងឆ្នាំសិក្សា២០១៣-២០១៤។ ប៉ុន្តែការកើនឡើងនេះ មានលក្ខណៈនៅយឺតនៅឡើយដោយសារការផ្តល់ធាតុចូលសម្រាប់ការពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាព មិនទាន់ឆ្លើយតបនឹងតម្រូវការ។

**រូបភាពទី៦ ៖ ភាគរយកុមារអាយុ ៥ឆ្នាំទទួលបានការអប់រំតាមរាជធានី ខេត្ត ឆ្នាំសិក្សា២០១៤-២០១៥**




បុគ្គលិកអប់រំមាន ១០ ០១៥ នាក់ ស្រី ៩១,៥ ភាគរយ កើន ៦៨៧ នាក់ ស្រី ៧,៤ ភាគរយ ក្នុងនោះ បុគ្គលិកអប់រំមត្តេយ្យសិក្សារដ្ឋ ៥ ០២៧ នាក់ ស្រី ៩៥,៩ ភាគរយ កើន ៣១០ នាក់ ស្រី ៦,៨ ភាគរយ បុគ្គលិកមត្តេយ្យសិក្សាសហគមន៍ ២ ៧៨៦ នាក់ ស្រី ៩៧ ភាគរយ កើន ២៦៣ នាក់ ស្រី១០,៦ ភាគរយ និងបុគ្គលិកមត្តេយ្យសិក្សាឯកជន ២ ២០២ នាក់ ស្រី ៧៥,៨ ភាគរយ កើន ១១៤ នាក់ ស្រី ៦,៣ ភាគរយ។

*ប្រការនេះបានជួយធានាឱ្យការអប់រំកុមារតូចដំណើរការប្រកបដោយប្រសិទ្ធភាព។*

ការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទង់ផ្ទះ មានឪពុកម្តាយកុមារចូលរួម ៧៥ ០០៣ គ្រួសារ ប្រធានក្រុមម្តាយ ១៥ ៥០៩ នាក់ ម្តាយបង្គោល ៣ ២៦៦ នាក់ និងកុមារ ១១១ ៦៩៣ នាក់ ស្រី ៥៦ ៩៣៦ នាក់។ ភូមិដែលបានអនុវត្តកម្មវិធីអប់រំកុមារតូចតាមផ្ទះមាន ៣ ០២៥ ក្នុងចំណោម ១៤ ១១៩ ភូមិ ស្ថិតក្នុងឃុំ សង្កាត់ ៩១០ ក្នុងចំណោម ១៦៣៣ និងស្រុក ខណ្ឌ ១៦៨ ក្នុងចំណោម ១៩៧។

*ប្រការនេះបញ្ជាក់ថា ការប្រមូលកុមារចូលរៀនមានការកើនឡើងជាលំដាប់ ដោយសារបានពង្រីកថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា និងមណ្ឌល ឬថ្នាក់មត្តេយ្យសិក្សាសហគមន៍ រួមទាំងការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទង់ផ្ទះ។*

## ការអនុវត្តកម្មវិធីនានា

### *កម្មវិធីអប់រំពហុភាសា*

កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចបានអនុវត្តក្នុងក្រុង ស្រុក ១២ កើន ១ នៃខេត្តគោលដៅ ៥ មានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមមត្តេយ្យសិក្សាសហគមន៍ ៣៤ កើន ១១ មានសិស្ស ៧០៧ នាក់ កើន ២៥២ នាក់ ស្រី ៣៦២ នាក់ កើន ១១១ នាក់។ ភាសាដែលបានប្រើប្រាស់រួមមានភាសា ទំពួន គ្រឹង ចារ៉ាយ ព្នង និងកួយ។

ក្រសួងបាន៖

- បើកសិក្ខាសាលារៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសានៅមត្តេយ្យសិក្សា មានអ្នកចូលរួម ២៣ នាក់ ស្រី ១៣ នាក់
- បំប៉នសមត្ថភាពគ្រូបង្គោល ស្តីពីការអប់រំពហុភាសា នៅរាជធានីភ្នំពេញ មានអ្នកចូលរួម ១៩ នាក់ ស្រី ១៦ នាក់។

*ប្រការនេះ បានជួយលើកទឹកចិត្តឱ្យកុមារជនជាតិដើមភាគតិចបានចូលរៀនប្រកបដោយសមធម៌។*

### *កម្មវិធីអប់រំបញ្ចូលគ្នា*

កម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការបានអនុវត្តនៅខេត្តគោលដៅ ៥ កើន ២ មានខេត្តសៀមរាប និងរតនគិរី។ កម្មវិធីនេះបានអនុវត្តមត្តេយ្យសិក្សារដ្ឋមាន ៥៨ សាលា និងមត្តេយ្យសិក្សាសហគមន៍ ១៧ កន្លែង កើន ៣៨ មានសិស្ស ១២២ នាក់ កើន ៥១ នាក់ ស្រី ៥៩ នាក់ កើន ២៤ នាក់។ គ្រូមត្តេយ្យសិក្សាសម្រាប់កម្មវិធីអប់រំកុមារពិការមានបញ្ញាស្តាប់ ៨០ នាក់ ស្រី ២០ នាក់។

*ប្រការនេះបានបង្កឱកាសឱ្យកុមារពិការបានចូលរៀនដោយគ្មានការរើសអើង។*

### *ការងារសាងសង់*

ក្រសួងបានកំណត់ទីតាំងសាងសង់មត្តេយ្យសិក្សាសហគមន៍ ក្រោមគម្រោងគាំទ្រវិស័យអប់រំទី២ ចំនួន ៥០០ កន្លែង និងមត្តេយ្យសិក្សាធនធាន ៧០។

## ក.២ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតប

### *លទ្ធផលនៃការសិក្សា*

កុមារអាយុ ៥ឆ្នាំបានបញ្ចប់ការសិក្សាថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ ១៥៩ ៥២៥ នាក់ ស្រី ៨០ ១៧៩ នាក់ កើន ១៦ ៣៣៦ នាក់ ស្រី ៨ ០៧៧ នាក់។ កុមារអាយុ ៥ឆ្នាំ ឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាព និងចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាបាន ៥៧,៩ ភាគរយ។

### ការកែលម្អបរិស្ថានសាលា និងសម្ភារសិក្សា

សាលាមត្តេយ្យសិក្សាដាច់ដោយឡែកនៅតាមរាជធានី ខេត្ត បានជួសជុល និងកែលម្អបរិស្ថានក្នុង និងក្រៅថ្នាក់ដូចជាធ្វើរបងសាលា លាបថ្នាំពណ៌ គូររូបគំនូរលើជញ្ជាំង ខឿន ដងទង់ជាតិ សួនច្បារ និងរៀបចំទីធ្លាឱ្យមានអនាម័យល្អ។ ថ្នាក់រៀនបានរៀបចំជ្រុងទៅតាមប្រភេទដូចជាជ្រុងល្បែង ជ្រុងសិល្បៈ ជ្រុងតន្ត្រី ជ្រុងវិទ្យាសាស្ត្រ និងជ្រុងអនាម័យ។ ថ្នាក់មត្តេយ្យសិក្សាសហគមន៍បានរៀបចំកែលម្អបរិស្ថានសិក្សាឱ្យមានលក្ខណៈសមស្របតាមនិយាមគរុកោសល្យ។

### ការអនុវត្តម៉ោង និងកម្មវិធីសិក្សា

ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគសិក្សានៅសាលារៀន និងថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាកម្រិតទាបអនុវត្តបាន ៨៣,៤ ភាគរយ មត្តេយ្យសិក្សាកម្រិតមធ្យម ៨៨,២ ភាគរយ មត្តេយ្យសិក្សាកម្រិតខ្ពស់ ៨២,២ ភាគរយ ធៀបទៅនឹងកម្មវិធីសិក្សាប្រចាំឆ្នាំ។

ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគនៅមណ្ឌលឬថ្នាក់មត្តេយ្យសិក្សាសហគមន៍អនុវត្តបាន ៩៣ ភាគរយ ធៀបទៅនឹងកម្មវិធីសិក្សាប្រចាំឆ្នាំ។

ការអនុវត្តសកម្មភាពរបស់កម្មវិធីអប់រំកុមារតូចតាមផ្ទះ និងកម្មវិធីអប់រំមាតាបិតាបានប្រើប្រាស់ឯកសារប្រាស្រ័យទាក់ទងរវាងម្ដាយ និងកូន អនុវត្តសកម្មភាពប្រចាំថ្ងៃ និងប្រើប្រាស់ប្រតិទិន ផ្ទាំងរូបភាព និងសម្ភារៈពាក់ព័ន្ធផ្សេងៗទៀត។

ក្រសួងបាន៖

- ពិគ្រោះយោបល់ស្ដីពីការកែលម្អកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ នៅរាជធានីភ្នំពេញ មានអ្នកចូលរួម ៨៥ នាក់ ស្រី ៧៦ នាក់
- ពិគ្រោះយោបល់ស្ដីពីឯកសារស្តង់ដារសម្រាប់បំប៉នកម្មវិធីអប់រំមាតាបិតា និងមត្តេយ្យសិក្សាសហគមន៍ នៅខេត្តសៀមរាប មានអ្នកចូលរួម ៣០ នាក់ ស្រី ២០ នាក់
- ពិគ្រោះយោបល់ស្ដីពីកម្មវិធីអប់រំមាតាបិតា នៅខេត្តព្រះសីហនុ មានអ្នកចូលរួម ២៨ នាក់ ស្រី ១៩ នាក់។

### ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

ក្រសួងបាន៖

- ជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ និងផ្ដល់ការបំប៉នដំបូង ៨ថ្ងៃ ឬ ១០ថ្ងៃ និងបំប៉នបន្ថែមជាបន្តបន្ទាប់
- ប្រឡងបញ្ចប់ការបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សា (១២+២ និង៩+២) ចំនួន ២០៨ នាក់ ស្រី ២០៣នាក់

- កំពុងបណ្តុះបណ្តាលគរុសិស្សឆ្នាំទី២ ចំនួន ២០២ នាក់ ស្រី ១៨៨ នាក់
- ប្រឡងជ្រើសរើសគ្រូមត្តេយ្យសិក្សា (១២+២ និង៩+២) ចំនួន ២៥០ នាក់ ស្រី ២២៦ នាក់
- បំប៉នគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ស្តីពីវិធីសាស្រ្តបង្រៀនមុខវិជ្ជាបុរេសំណេរសម្រាប់គ្រូមត្តេយ្យសិក្សារដ្ឋ មានអ្នកចូលរួម ២៣៣ នាក់ ស្រី ១៧២ នាក់ និងគ្រូមត្តេយ្យសិក្សា ២ ៨៩៦ នាក់ ស្រី ១៩៥៤ នាក់
- បំប៉នគ្រូមត្តេយ្យសិក្សាស្តីពីវិធីសាស្រ្តបង្រៀន ការផលិត និងប្រើប្រាស់សម្ភារឧបទេសលើមុខវិជ្ជាបុរេសំណេរ និងបុរេគណិត មានអ្នកចូលរួម ៥២ នាក់ ស្រី ៥២ នាក់
- បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីការអប់រំមាតាបិតា មានអ្នកចូលរួម ២០ នាក់ ស្រី ១៧ នាក់ និងគ្រូឧទ្ទេសថ្នាក់ក្រោមជាតិ ៣០២ នាក់ ស្រី ២៥៦ នាក់។

***ការអភិវឌ្ឍកម្មវិធីសិក្សា និងចងក្រងឯកសារ***

ក្រសួងបាន៖

- បំប៉នសមត្ថភាពមន្ត្រីជំនាញស្តីពីការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ នៅខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង មានអ្នកចូលរួម ៥០ នាក់ ស្រី ១២ នាក់
- រៀបចំឯកសារគោលការណ៍ណែនាំសម្រាប់អនុវត្តមត្តេយ្យសិក្សាធនធាន គោលការណ៍ណែនាំសម្រាប់អនុវត្តកម្មវិធីអប់រំមាតាបិតាដោយផ្តោតលើសេវាអាហារូបត្ថម្ភ ការថែទាំ និងការប្រើប្រាស់សេវាសុខាភិបាល ឯកសារស្តង់ដារបំប៉ន និងសម្ភារឧបទេសសម្រាប់បំប៉នគ្រូ មត្តេយ្យសិក្សារដ្ឋ គ្រូបឋមសិក្សាបង្រៀនថ្នាក់មត្តេយ្យសិក្សា និងគ្រូមត្តេយ្យសិក្សាសហគមន៍ ស្តង់ដារសម្រាប់បំប៉នដំបូង និងបំប៉នបន្តដល់មាតាបិតាបង្គោលស្តីពីកម្មវិធីអប់រំមាតាបិតា ឯកសារទាក់ទងការងារមត្តេយ្យសិក្សាសហគមន៍។

***ការងារត្រួតពិនិត្យតាមដាន និងសិក្សាស្រាវជ្រាវ***

ក្រសួងបាន៖

- ពង្រឹងសមត្ថភាពមន្ត្រីអប់រំកុមារតូច ស្តីពីការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល មានអ្នកចូលរួម ៥៥២ នាក់ ស្រី ៣១១ នាក់
- ចុះពិនិត្យតាមដាន និងវាយតម្លៃការងារអប់រំកុមារតូច ១៧ ខេត្ត គឺខេត្តព្រះវិហារ កំពត ក្រចេះ ព្រះសីហនុ កំពង់ចាម បន្ទាយមានជ័យ ស្វាយរៀង ពោធិ៍សាត់ ព្រៃវែង កំពង់ស្ពឺ ស្ទឹងត្រែង ឧត្តរមានជ័យ តាកែវ កំពង់ធំ រតនគិរី ប៉ៃលិន និងកំពង់ឆ្នាំង

- ចុះពិនិត្យលើដំណើរការរៀបចំផែនការ និងប្រើប្រាស់ថវិកាជំនួយកែលម្អសាលារៀន ១០ ខេត្ត គឺខេត្តបន្ទាយមានជ័យ ព្រះសីហនុ កំពង់ចាម កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង ក្រចេះ កែប កោះកុង និងសៀមរាប
- ចុះពិនិត្យតាមដានដំណើរការអនុវត្តគម្រោងជំនួយកែលម្អសាលារៀន ៤ ខេត្ត គឺខេត្តកំពង់ស្ពឺ ស្វាយរៀង បាត់ដំបង និងកំពង់ចាម។

## ក.៣ ការលើកកម្ពស់ប្រសិទ្ធភាពភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

### *ការអភិវឌ្ឍសមត្ថភាពក្នុងប្រទេស*

ក្រសួងបាន៖

- បំប៉នមន្ត្រីជំនាញកុមារតូច ស្តីពីការរៀបចំផែនការអភិវឌ្ឍមត្តេយ្យសិក្សារដ្ឋនៅខេត្តបាត់ដំបង មានអ្នកចូលរួម ១៨៧ នាក់ ស្រី ១៥២ នាក់ និងកំពង់ចាម មានអ្នកចូលរួម ២០៦ នាក់ ស្រី ១៨២ នាក់
- បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីការងារគ្រប់គ្រងរដ្ឋបាល និងការងារបច្ចេកទេសផ្នែកមត្តេយ្យសិក្សាសហគមន៍ នៅខេត្តតាកែវ មានអ្នកចូលរួម ២០ នាក់ ស្រី ១៣ នាក់
- បំប៉នមន្ត្រីថ្នាក់ក្រោមជាតិស្តីពីការតម្រង់ទិសការងារគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ នៅខេត្តស្វាយរៀង កំពង់ធំ កំពត និងបាត់ដំបង មានអ្នកចូលរួម ៦៤៣ នាក់ ស្រី ៤២១ នាក់។

### *ការអភិវឌ្ឍសមត្ថភាពក្រៅប្រទេស*

- មន្ត្រីជំនាញ ២ នាក់ ចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការវាយតម្លៃផលប៉ះពាល់គម្រោង "បញ្ជាក់ការប្តេជ្ញាចិត្តទៅជាការអនុវត្តជាក់ស្តែង" នៅសាធារណរដ្ឋកូរ៉េ
- មន្ត្រីជំនាញ ៣ នាក់ ស្រី ១ នាក់ ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យចុងក្រោយ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវការអភិវឌ្ឍកុមារតូចតំបន់អាស៊ីប៉ាស៊ីហ្វិក នៅថៃ
- មន្ត្រីជំនាញ ២ នាក់ ចូលរួមសិក្ខាសាលាស្តីពីការរៀបចំគោលការណ៍ណែនាំសម្រាប់គ្រូមត្តេយ្យសិក្សាតំបន់អាស៊ីប៉ាស៊ីហ្វិក នៅថៃ
- មន្ត្រីជំនាញ ៣ នាក់ ស្រី ២ នាក់ ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ឌីប្លូម៉ាជាន់ខ្ពស់ ស្តីពីសិទ្ធិកុមារ ការគ្រប់គ្រងថ្នាក់រៀន និងសាលារៀន នៅស៊ុយអែត
- មន្ត្រីជំនាញ ៣ នាក់ ស្រី ១ នាក់ ចូលរួមសន្និសីទថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីការអភិវឌ្ឍកុមារតូច ការកសាងភាពជាដៃគូ ដើម្បីនិរន្តរភាពនិងភាពសុខដុម នៅហ្វីលីពីន។

### *ការកសាងលិខិតបទដ្ឋាន*

- ព្រះរាជក្រឹត្យស្តីពីការតែងតាំងសមាសភាពរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- អនុក្រឹត្យស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- អនុក្រឹត្យ ស្តីពីការតែងតាំងសមាសភាពប្រធានផ្នែកក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ប្រកាស ស្តីពីការតែងតាំងសមាសភាពអនុប្រធានផ្នែកក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ
- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា
- ប្រកាសស្តីពីការបំបែកការិយាល័យបឋម និងមត្តេយ្យសិក្សា ទៅជាការិយាល័យអប់រំកុមារតូច និងការិយាល័យបឋមសិក្សា ១៤ ខេត្ត
- ផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៤-២០១៨។

*ប្រការនេះបានជួយកៀរគរធនធានក្នុងការគាំពារ និងអភិវឌ្ឍកុមារតូចក្នុងក្របខណ្ឌពហុវិស័យ។*

### *ការងារគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច*

- ប្រជុំលើកទី១ មានគោលបំណងណែនាំសមាសភាពថ្នាក់ដឹកនាំ សមាជិក សមាជិកានៃគណៈកម្មាធិការជាតិ និងកំណត់តួនាទី ភារកិច្ច និងយន្តការការងារ មានអ្នកចូលរួម ៥៦ នាក់ ស្រី ១៨ នាក់
- ប្រជុំលើកទី២ មានគោលបំណងពិភាក្សា និងអនុម័តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច មានអ្នកចូលរួម ៧២ នាក់ ស្រី ២៣នាក់
- ប្រជុំផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ផ្សព្វផ្សាយគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅខេត្តព្រះសីហនុ មានអ្នកចូលរួម ៦៩ នាក់ ស្រី ២៤ នាក់ និងខេត្តកំពង់ស្ពឺ មាន ២៥០ ស្រី ៨០ នាក់

- សិក្ខាសាលាពិគ្រោះយោបល់ ២លើក ដើម្បីរៀបចំក្របខណ្ឌលទ្ធផលសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ មានអ្នកចូលរួម ៩៦ នាក់ ស្រី ៣៣ នាក់។

## ខ. ចង្កួនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំកុមារតូច | ជាក់ស្តែង ២០១៣-១៤ | ចំណុចដៅ ២០១៤-១៥ | ជាក់ស្តែង ២០១៤-១៥ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ភាគរយកុមារអាយុ៥ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | ៥៩,៩% | ៦៦% | ៦១,៤% | → |
| ២ | ភាគរយកុមារអាយុ៤ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | ២៤,៥% | ៣៣% | ២៩,១% | → |
| ៣ | ភាគរយកុមារអាយុ៣ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | ១៦,៧% | ២៧% | ១៦,៦% | ↓ |
| ៤ | ភាគរយកុមារតូចដែលគោរពតាមស្តង់ដារគុណភាព | N/A | ៤០% | N/A | ↓ |
| ៥ | ភាគរយកុមារតូចដែលអនុវត្តដែលបានអនុវត្តតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ ជាទៀងទាត់ | N/A | ៤០% | N/A | ↓ |
| ៦ | ភាគរយកុមារក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភ | N/A | ៤០% | N/A | ↓ |
| ៧ | ភាគរយកុមារនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ ទទួលបានថ្នាំទម្លាក់ព្រូន | N/A | ៩០% | ៨៧,៨% | → |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការប្រមូលកុមារអាយុ ៣ ដល់ ក្រោម ៦ ឆ្នាំចូលរៀននៅទាបជាងចំណុចដៅ
- ការសាងសង់បន្ទប់រៀន ឬសាលារៀនមិនគ្រប់គ្រាន់តាមតម្រូវការ
- កង្វះគ្រូមត្តេយ្យសិក្សារដ្ឋ
- សម្ភាររូបវន្តតាមថ្នាក់មត្តេយ្យសិក្សាមិនទាន់គ្រប់គ្រាន់ និងស្របតាមនិយាម
- សមត្ថភាពគ្រូមត្តេយ្យសិក្សាមិនទាន់ឆ្លើយតបនឹងការអនុវត្តបច្ចេកទេសមត្តេយ្យសិក្សា
- កម្មវិធីអប់រំកុមារតូចតាមផ្ទះនិងកម្មវិធីអប់រំមាតាបិតាមិនទាន់អនុវត្តស្របតាមគោលការណ៍ណែនាំ
- ការប្រើប្រាស់មូលនិធិឃុំ សង្កាត់សម្រាប់ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគមន៍ និងថវិកាសម្រាប់ដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍មិនទាន់មានការឯកភាពគ្នា
- ការផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅថ្នាក់ក្រោមជាតិពុំទាន់បានទូលំទូលាយ។

## ២.២.២ អនុវិស័យ ការអប់រំបឋមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ការធានាសមធម៌នៃការទទួលបានការអប់រំ

ឆ្នាំសិក្សា ២០១៤-២០១៥ សាលាបឋមសិក្សាសាធារណៈមាន ៧ ០៥១ កើន ៥៨ ធៀបនឹងឆ្នាំសិក្សា ២០១៣-២០១៤។ សាលារៀនមិនគ្រប់កម្រិតថយពី ៨១៦ មក ៧៤៣។ សាលាកុមារមេត្រី (កម្រិតមធ្យមនិងអភិវឌ្ឍ) កើនពី ៥ ០៦៨ ដល់ ៥ ១៩៩។ សាលាបឋមសិក្សាឯកជនមាន ២៩៧ មានទីតាំងនៅគ្រប់រាជធានី ខេត្ត។

ថ្នាក់រៀនមាន ៥៩ ៦៥៤ កើន ២០០។ បន្ទប់រៀនមាន ៤២ ៩៨០ កើន ៧៤៨។

សិស្សបឋមសិក្សាមាន ២ ០១២ ១៧៥ នាក់ ស្រី ៩៧០ ៩៩៩ នាក់ ស្មើនឹង ៤៨,៣ ភាគរយ ថយ ៦១ ៦៣៦ នាក់ ស្រី ២៣ ៩៩០ នាក់។ សិស្សបឋមសិក្សាឯកជន ៧៣ ៧៩៤ នាក់ ស្រី ៣៦ ៦៨៦ នាក់ ស្មើនឹង ៤៩,៧ ភាគរយ។ អត្រាពិតចូលរៀនថ្មីសរុបមាន ៩៩,៤ ភាគរយ ស្រី ១០០ ភាគរយ (ចំណុចដៅ ESP ១០០ ភាគរយ ស្រី ១០០ ភាគរយ) ក្នុងនោះអត្រាពិតចូលរៀនថ្មីបឋមសិក្សាសាធារណៈ ៩៥,៩ ភាគរយ កើន ០,៦ ភាគរយ ស្រី ៩៦,៥ ភាគរយ ថយ ១,២ ភាគរយ និងអត្រាពិតចូលរៀនថ្មីបឋមសិក្សាឯកជន ៣,៥ ភាគរយ ស្រី ៣,៥ ភាគរយ ។

*ប្រការនេះបញ្ជាក់ឱ្យឃើញថាកុមារកម្ពុជាកាន់តែទទួលបានការអប់រំប្រកបដោយសមធម៌។*

អត្រាពិតនៃការសិក្សាសរុបមាន ៩៧,៩ ភាគរយ ស្រី ៩៨,៤ ភាគរយ (ចំណុចដៅ ESP ៩៨ ភាគរយ ស្រី ៩៨ ភាគរយ) ក្នុងនោះអត្រាពិតនៃការសិក្សាបឋមសិក្សាសាធារណៈមាន ៩៤,៥ ភាគរយ ស្រី ៩៤,៩ ភាគរយ ថយ ១,១ ភាគរយ ស្រីថយ ០,៩ ភាគរយ និងអត្រាពិតនៃការសិក្សាបឋមសិក្សាឯកជន ៣,៤ ភាគរយ ស្រី ៣,៥ ភាគរយ ។

បុគ្គលិកអប់រំបឋមសិក្សាមាន ៥៥ ៧៨៨ នាក់ ស្រី ២៦ ៤៣១ នាក់ ស្មើនឹង ៤៧,៤ ភាគរយ ថយ ១៧០ នាក់ ស្រីកើន ៨៤៤ នាក់។ បុគ្គលិកបង្រៀន ៤៤ ២៩២ នាក់ ស្រី ២៣ ២២៧ នាក់ ស្មើនឹង ៥២,៤ ភាគរយ ថយ ៦០៣ នាក់ ស្រីកើន ៥៩៧ នាក់។ គ្រូបង្រៀនពីរថ្នាក់ពីរវេន ១៧ ០៣៥ នាក់ ស្រី ៥ ៨០១ នាក់ និងគ្រូបង្រៀនថ្នាក់គួប ១ ៩៨១ នាក់ ស្រី ៨៥២ នាក់។

#### ការអនុវត្តកម្មវិធីនានា

#### *ការគ្រប់គ្រងថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន*

គ្រប់សាលារៀនបានទទួលថវិកាដំណើរការ និងកែលម្អសាលារៀន។ សាលារៀននីមួយៗមានការរៀបចំផែនការអភិវឌ្ឍប្រចាំឆ្នាំ ដែលមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលា។ រាល់ចំណូលចំណាយមានតារាងតម្លាភាពបិទផ្សាយ។

*ប្រការនេះ បានជួយឱ្យសាលារៀនមានលទ្ធភាពប្រមូលកុមារចូលរៀន និងមានការចូលរួមពីសហគមន៍កាន់តែប្រសើរឡើង។*

### *កម្មវិធីអប់រំពហុភាសា*

កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច បានអនុវត្តក្នុងក្រុង ស្រុក ១៦ កើន ២ លើខេត្តគោលដៅ ៥ គឺខេត្តរតនគិរី មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមសាលារៀន ៨៣ កើន ២ មានសិស្ស ៣ ៣៣៨ នាក់ ស្រី ១ ៥៦៤ នាក់ កើន ៩៣៧ នាក់ ស្រី ៤៥១ នាក់។ ក្រសួងបានរៀបចំផែនការសកម្មភាពដាក់បញ្ចូលសាលារៀនសហគមន៍ ៨៣ ទៅជាសាលារៀនសាធារណៈ។

*ប្រការនេះបានធ្វើជាស្ពាន ដើម្បីជួយសិស្សឱ្យឆ្លងពីភាសាកំណើតទៅភាសាជាតិ ក្នុងការបន្តការសិក្សាប្រកបដោយប្រសិទ្ធភាព។*

### *កម្មវិធីពន្លឿនការសិក្សា*

ថ្នាក់ពន្លឿនការសិក្សាបានអនុវត្តក្នុងក្រុង ស្រុក ១០ កើន ៣ លើខេត្តគោលដៅ ៣ គឺខេត្តកំពត ព្រះវិហារ និងក្រចេះ។ ថ្នាក់ពន្លឿនបានអនុវត្តនៅតាមសាលារៀន ៥២ កើន ២៨ មានសិស្ស ២ ០១៥ នាក់ ស្រី ៨១៣ នាក់ កើន ១ ៣២៩ នាក់ ស្រី ៨២ នាក់។

*ប្រការនេះ បានជួយសិស្សដែលលើសអាយុឱ្យបានចូលរៀនស្របតាមកម្រិតថ្នាក់ និងត្រូវអាយុជាពិសេសជួយកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។*

### *កម្មវិធីអប់រំបញ្ចូលគ្នា*

កម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការបានអនុវត្តនៅតាមសាលារៀន ៣ ៤២០ កើន ២៤០ មានសិស្ស ៧២ ៣៦៦ នាក់ ស្រី ៣០ ៨៨៧ នាក់ កើន ១ ១៩១ នាក់ ស្រី ៥៣៧ នាក់។ គ្រូបង្រៀន២ ៣០០ នាក់ ស្រី ៦៣៧ នាក់ បានទទួលការបំប៉នស្តីពីការអប់រំបញ្ចូលគ្នា។

ក្រសួងបានបោះពុម្ពសៀវភៅអក្សរប្រេលសម្រាប់កុមារពិការភ្នែក និងសៀវភៅអក្សរសញ្ញាសម្រាប់កុមារគថ្លង់ ១១ ៧៧១ ក្បាល។ កម្មវិធីនេះផ្តល់ឱកាសដល់កុមារពិការបានចូលរៀនដោយគ្មានការរើសអើង។

### *កម្មវិធីស្បៀងអាហារនៅតាមសាលារៀន និងអាហារូបករណ៍*

កម្មវិធីស្បៀងអាហារនៅតាមសាលារៀនបានអនុវត្តក្នុងសាលាបឋមសិក្សា និងថ្នាក់មត្តេយ្យសិក្សាលើខេត្តគោលដៅ ១៥ ដែលគាំទ្រដោយកម្មវិធីស្បៀងអាហារពិភពលោក។ សាលារៀន ១ ៣៣៣ មានសិស្ស ៣៨៩ ៣៩៩ នាក់ ស្រី ១៨៨ ៣៤៨ នាក់ ទទួលអាហារពេលព្រឹក សាលារៀន ៣ ៣៦៥ មានសិស្ស ៤៣ ៧២៧ នាក់ ស្រី ២៤ ០០៨ នាក់ ទទួលអាហារូបករណ៍ជាស្បៀង សាលារៀន ៧២២ មានសិស្ស ៨ ៥៥៩ នាក់ ស្រី ៤ ៧៩៩ នាក់ ទទួលអាហារូបករណ៍ជាសាច់ប្រាក់។ កម្មវិធីនេះគាំទ្រដល់កុមារដែលមកពីគ្រួសារ

ក្រីក្រ និងកុមារជួបប្រទះអសន្តិសុខស្បៀងទទួលការអប់រំប្រកបដោយសមធម៌។ កម្មវិធីស្បៀងអាហារនៅតាមសាលារៀនត្រូវបានរៀបចំជាផែនទីបង្ហាញផ្លូវ ដើម្បីធានានិរន្តរភាពក្នុងការអនុវត្ត។

ក្រសួងធ្វើវិសោធនកម្មអនុក្រឹត្យស្ដីពីការផ្ដល់អាហារូបករណ៍សម្រាប់បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ និងបានដាក់ឆ្លងទីស្ដីការគណៈរដ្ឋមន្ត្រី។

## *ការអប់រំសុខភាព*

ក្រសួងបាន៖

- ទទួលសម្ភារៈបោះពុម្ព និងឯកសារអប់រំផ្សព្វផ្សាយពីដៃគូអភិវឌ្ឍ ដូចជាសៀវភៅការអប់រំបំណិនជីវិតស្ដីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់ថ្នាក់ទី៥ និងទី៦ ចំនួន ៣ ៥០០ ក្បាល សៀវភៅ "ការលូតលាស់ និងការប្រែប្រួល" ១៤០ ៥៥៥ ក្បាល ដើម្បីចែកសិស្សស្រីវ័យជំទង់នៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា
- ផ្ដល់រូបភាពផ្ទាំងធំស្ដីពីវដ្ដនៃជំងឺគ្រុនចាញ់ និងការអប់រំបង្ការជំងឺគ្រុនចាញ់ ៧ ០០០ ផ្ទាំង ដល់គ្រឹះស្ថានសិក្សានៅតាមខេត្តដែលមានអត្រាជំងឺគ្រុនចាញ់ខ្ពស់
- ផ្ដល់សៀវភៅការអប់រំបង្ការជំងឺគ្រុនចាញ់ ៤ ០០០ ក្បាល និងសៀវភៅការអប់រំសុខភាពស្ដីពីសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន ២ ៥០០ ក្បាល ដល់សាលាបឋមសិក្សា
- ផ្ដល់ប្រអប់សង្គ្រោះបឋមដល់សាលាបឋមសិក្សា ២២៥ នៅតាមរាជធានី ខេត្ត
- បំប៉នមន្ត្រីអប់រំ និងមន្ត្រីសុខាភិបាល ១ ៤៤៨ នាក់ ស្រី ៤១ ភាគរយ លើការបង្ការដង្កូវព្រូននៅខេត្តព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី តាកែវ មណ្ឌលគិរី និងរាជធានីភ្នំពេញ។ សាលាបឋមសិក្សា ១៤ នៅរាជធានីភ្នំពេញ ខេត្តកំពត កំពង់ឆ្នាំង កំពង់ធំ តាកែវ និងព្រះវិហារ បានអនុវត្តកម្មវិធីលាងសម្អាតដៃ និងដុសសម្អាតមាត់-ធ្មេញ
- តម្រង់ទិសស្ដីពីការអនុវត្តគម្រោងអនាម័យគំរូតាមសាលារៀនដល់នាយក នាយិកា គ្រូបឋមសិក្សា និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ នៅខេត្តកំពង់ឆ្នាំង កំពង់ធំ កំពត តាកែវ និងរាជធានីភ្នំពេញ មានអ្នកចូលរួម ២ ៩៥២ នាក់ ស្រី ៤៧ ភាគរយ
- ធ្វើការអប់រំសុខភាពមាត់-ធ្មេញ ការលាងសម្អាតដៃ និងផ្ដល់សម្ភារៈអនាម័យ (ច្រាសដុសធ្មេញនិងសាប៊ូ) ដល់នាយក នាយិកា គ្រូបឋមសិក្សា ២៨៤ នាក់ ស្រី ៤៥ ភាគរយក្នុងរាជធានីភ្នំពេញ ខេត្តកំពត ពោធិសាត់ និងតាកែវ និងអនុវត្តបន្តផ្ទាល់ជាមួយសិស្សថ្នាក់ទី៣ និងទី៤ ចំនួន ៣៧ ៦១៨ នាក់ ស្រី ៤៨ ភាគរយ
- បំប៉នស្ដីពីការអប់រំសុខភាពភ្នែកដល់គ្រូបឋមសិក្សា ៤ ២៤៣ នាក់ ស្រី ៤៥ ភាគរយ ដើម្បីបន្តអប់រំដល់សិស្សក្នុងខេត្តកណ្ដាល ព្រៃវែង កំពង់ធំ កំពង់ឆ្នាំង និងកំពង់ស្ពឺ

- ផ្តល់ថ្នាំទម្លាក់ព្រូន ២ លើក ដល់សិស្សបឋមសិក្សាទូទាំងប្រទេសលើកទី១ ចំនួន ១ ៩០០ ៥៧០ នាក់ និងលើកទី២ ចំនួន ១ ០៦៩ ១៧៥ នាក់ ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល
- ប្រារព្ធយុទ្ធនាការផ្តល់ថ្នាំទម្លាក់ព្រូន ដល់សិស្សានុសិស្សសាលាបឋមសិក្សាវត្តបូណ៌ ខេត្តសៀមរាប មានអ្នកចូលរួម ៨០០ នាក់ ស្រី ៣៧ ភាគរយ
- ចែកសម្ភារសិក្សាដែលមានសារអប់រំបង្ការជំងឺដង្កូវព្រូន ក្រោមគម្រោងកុមារឆ្លាតដល់សិស្សបឋមសិក្សា ១៨ ខេត្ត និងផ្សព្វផ្សាយសារាចរណែនាំស្តីពីការហាមឃាត់ការពិសាបារីនៅកន្លែងធ្វើការ និងទីសាធារណៈ។

*ប្រការនេះធានាសុខភាព និងសុវត្ថិភាពដល់សិស្សក្នុងការសិក្សាបានជាប់លាប់ទៀងទាត់ និងជួយដល់ការលូតលាស់កាយសម្បទា និងសតិបញ្ញា។*

## ក.២ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតប

អត្រាឡើងថ្នាក់នៅបឋមសិក្សាបានកើនដល់ ៨៦,៥ ភាគរយ ស្រី ៨៨,៥ ភាគរយ និង ប្រុស ៨៤,៧ ភាគរយ។ អត្រាត្រួតថ្នាក់បានកើនដល់ ៥,១ ភាគរយ ស្រី ៤,៣ ភាគរយ និងប្រុស ៦,០ ភាគរយ ធៀបនឹងឆ្នាំសិក្សា២០១២-២០១៣ មានការកើនឡើងតិចតួច។ អត្រាបោះបង់ការសិក្សាបានថយមកត្រឹម ៨,៣ ភាគរយ ស្រី ៧,២ ភាគរយ និងប្រុស ៩,៤ ភាគរយ។

តេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបានអនុវត្តសាលាសំណាកគំរូ ២២០ សិស្ស ៦ ០០០ នាក់។ លទ្ធផលតេស្តបង្ហាញថា សិស្សសម្រេចបានស្តង់ដារមុខវិជ្ជាភាសាខ្មែរ ៥២,៥ ភាគរយ និងគណិតវិទ្យា ៤២,៨ ភាគរយ។ លទ្ធផលនេះបានផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ។

*ប្រការនេះ ទាមទារឱ្យមានការខិតខំបន្ថែមទៀតក្នុងការលើកកម្ពស់ការបង្រៀននិងរៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា។*

លំនាំនៃការកើនឡើង និងថយចុះនៃអត្រាលំហូរនៅបឋមសិក្សា មានសភាពដូចគ្នាទាំងថ្នាក់ជាតិ ទាំងតំបន់ជនបទ និងទាំងតំបន់ប្រជុំជន។

**តារាងទី៤ ៖ អត្រាលំហូរសិស្សនៅបឋមសិក្សា រវាងឆ្នាំសិក្សា ភូមិសាស្ត្រ និងយេនឌ័រ**

| | | អត្រាលំហូរ (សរុប) | | | អត្រាលំហូរ (ស្រី) | | | អត្រាលំហូរ (ប្រុស) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៣-២០១៤ | ថ្នាក់ជាតិ | ៨៦,៥ | ៥,១ | ៨,៣ | ៨៨,៥ | ៤,៣ | ៧,២ | ៨៤,៧ | ៦,០ | ៩,៤ |
| | ប្រជុំជន | ៩០,៦ | ៣,៧ | ៥,៧ | ៩២,៤ | ២,៩ | ៤,៧ | ៨៩,០ | ៤,៥ | ៦,៥ |
| | ជនបទ | ៨៥,៨ | ៥,៤ | ៨,៨ | ៨៧,៨ | ៤,៥ | ៧,៧ | ៨៣,៩ | ៦,២ | ៩,៩ |
| ២០១២-២០១៣ | ថ្នាក់ជាតិ | ៨៤,៧ | ៤,៨ | ១០,៥ | ៨៧,៦ | ៤,១ | ៨,៣ | ៨២,១ | ៥,៥ | ១២,៤ |
| | ប្រជុំជន | ៨៨,៧ | ៣,៥ | ៧,៨ | ៩០,៧ | ២,៧ | ៦,៦ | ៨៦,៩ | ៤,១ | ៨,៩ |
| | ជនបទ | ៨៤,០ | ៥,១ | ១០,៩ | ៨៧,០ | ៤,៤ | ៨,៦ | ៨១,៣ | ៥,៧ | ១៣,០ |

អត្រាបញ្ចប់ការសិក្សាបឋមសិក្សាបានថយមក ៨៤,១ ភាគរយ ស្រី ៨៦,៦ ភាគរយ និងប្រុស ៨១,៨ ភាគរយ។ លំនាំនៃការថយចុះអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានសភាពដូចគ្នាទាំងថ្នាក់ជាតិ ទាំងតំបន់ជនបទ និងទាំងតំបន់ប្រជុំជន។

**តារាងទី៥ ៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា រវាងឆ្នាំសិក្សា ភូមិសាស្ត្រ និងយេនឌ័រ**

| | អត្រាបញ្ចប់ការសិក្សា ២០១៣-២០១៤ | | | អត្រាបញ្ចប់ការសិក្សា ២០១៤-២០១៥ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ថ្នាក់ជាតិ | ៨៨,៩ | ៩០,២ | ៨៧,៧ | ៨៤,១ | ៨៦,៦ | ៨១,៨ |
| ប្រជុំជន | ៧៦,៨ | ៧៨,៥ | ៧៥,៣ | ៧៤,១ | ៧៦,៦ | ៧១,៨ |
| ជនបទ | ៩១,៧ | ៩២,៨ | ៩០,៦ | ៨៦,៥ | ៨៨,៨ | ៨៤,២ |

## *ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន*

ក្រសួងបាន៖

- បញ្ចប់ការបណ្តុះបណ្តាលគ្រូបឋមសិក្សា ១២+២ និង ៩+២ ចំនួន ២ ២២២ នាក់ ស្រី ៦៩,៨ ភាគរយ និងកំពុងបណ្តុះបណ្តាល ២ ២៦០ នាក់ ស្រី ៨៦,៧ ភាគរយ និងប្រឡងជ្រើសរើសគ្រូបឋមសិក្សា ១២+២ និង៩+២ ចំនួន ៣ ២៨៤ នាក់ ស្រី ៦៦,៣ ភាគរយ
- បំប៉នគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ២ ៩៩៤ នាក់ ស្រី ៨៦,២ ភាគរយ ឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បោះពុម្ពឯកសារសម្រាប់បំប៉នគ្រូកម្រិតមូលដ្ឋានជំនាន់ទី៨ លើ ១៣ មុខវិជ្ជា ៧ ៨០៤ ក្បាល ព្រឹត្តិបត្រវាយតម្លៃការបណ្តុះបណ្តាលគ្រូបង្រៀន ១ ៥០០ ច្បាប់ និងឯកសារការអប់រំបញ្ចូលគ្នា ៨ ៥០០ ក្បាល
- កសាងឯកសារសម្របសម្រួលស្តីពីបញ្ហាស្តាប់នៃការអប់រំបញ្ចូលគ្នា
- បំប៉នគ្រូឧទ្ទេសស្តីពីការអប់រំបញ្ចូលគ្នា ៨៧៣ នាក់ ស្រី ៣៥,៥ ភាគរយ និងគរុសិស្ស ៤ ២៩៤ នាក់ ស្រី ៦៦,៥ ភាគរយ
- បំប៉នគ្រូឧទ្ទេស ២៣៦ នាក់ ស្រី ៣៧,២ ភាគរយ ស្តីពីកម្មវិធីសាលាកុមារមេត្រី
- បំប៉នគ្រូបង្រៀនថ្នាក់ទី៤ ចំនួន ១ ៨៨៩ នាក់ ស្រី ២៨,៩ ភាគរយ ស្តីពីវិធីសាស្ត្របង្រៀនភាសាអង់គ្លេស
- សិក្ខាសាលាណែនាំនាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ១១៤ នាក់ ស្រី ១៩,៣ ភាគរយ ស្តីពីការប្រើប្រាស់ប្រព័ន្ធធានាគុណភាពបណ្តុះបណ្តាលគ្រូបង្រៀន

- បំប៉នគ្រូបង្រៀនថ្នាក់ទី២ និងអ្នកពាក់ព័ន្ធ ១០ ៧០៤ នាក់ ស្រី ៣ ៨៣៥ នាក់ នៅខេត្ត ១០ ស្តីពីការប្រើប្រាស់សៀវភៅភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី២ ថ្មី សម្រាប់កម្មវិធីអំណានថ្នាក់ដំបូង
- បំប៉នគ្រូបង្រៀនថ្នាក់ទី៣ និងអ្នកពាក់ព័ន្ធ ២២ ៧៤៧ នាក់ ស្រី ៧ ៣៨៧ នាក់ នៅតាមក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តទាំង ២៥ ស្តីពីការប្រើប្រាស់សៀវភៅភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី៣ ថ្មី EGRA។

## *ការផ្គត់ផ្គង់សៀវភៅសិក្សាគោលនិងកម្មវិធីសិក្សា*

សៀវភៅសិក្សាគោល ១ ១៩៣ ៣៤៦ ច្បាប់ បានចែកចាយដល់សាលារៀនទូទាំងប្រទេសតាមផលធៀបសៀវភៅ-សិស្ស ១:១ នៅថ្នាក់ទី១-៣ សិស្សម្នាក់ ៣ ក្បាល ជាក់ស្តែង ២,៩៧ (ចំណុចដៅ ៣) និងនៅថ្នាក់ទី៤-៦ សិស្សម្នាក់ ៤ ក្បាល ជាក់ស្តែង ៣,៩៩ (ចំណុចដៅ ៤)។ មន្ត្រីទទួលបន្ទុកការគ្រប់គ្រងនិងផ្គត់ផ្គង់សៀវភៅ ១ ២៧៨ នាក់ ស្រី ៣០ ភាគរយ បានទទួលការបំប៉នលើការគ្រប់គ្រងតាមដានត្រួតពិនិត្យ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល។

គ្រូបង្រៀន ១៤៤ នាក់ ស្រី ២៥ ភាគរយ បានទទួលការបំប៉នលើការប្រើប្រាស់ស្តង់ដារកម្មវិធីសិក្សាថ្នាក់ទី៣ ទី៦ ទី៩ និងទី១២។

អ្នកនិពន្ធសៀវភៅភាសាអង់គ្លេសថ្នាក់ទី៥ ចំនួន ៨ នាក់ ស្រី ១២,៥ ភាគរយ បានអភិវឌ្ឍសមត្ថភាព។ គ្រូឧទ្ទេសបង្គោលតាមភូមិភាគ ២៩៥ នាក់ ស្រី ៥៦ នាក់ និងគ្រូបង្រៀនថ្នាក់ទី៤ ចំនួន ១ ៤៨៩ នាក់ ស្រី ២៨,៩ ភាគរយ បានទទួលការបំប៉នវិធីសាស្ត្របង្រៀនភាសាអង់គ្លេស។

គ្រូបង្រៀន ១០០ នាក់ ស្រី ៦០ ភាគរយ បានទទួលការបំប៉នស្តីពីគរុកោសល្យបង្រៀនភាសាបារាំង។

## *ការងារបណ្ណាល័យ*

ស្តង់ដារបណ្ណាល័យបឋមសិក្សា បានដាក់ឱ្យអនុវត្តនៅតាមបណ្ណាល័យសាលារៀនទូទាំងប្រទេស។ បណ្ណាល័យទូទាំងប្រទេសមាន ៣ ៨៨០។ បណ្ណាល័យមានលក្ខណៈស្តង់ដារ ២ នៅខេត្តកំពត និងកំពង់ស្ពឺ។ អភិវឌ្ឍសេចក្តីព្រាងគោលការណ៍ណែនាំ និងឯកសារជំនួយស្តីពីការជំរុញការអានតាមសាលារៀន។ គ្រូឧទ្ទេស នាយក និងបណ្ណារក្ស ១ ០៨២ ស្រី ៣០,៤ ភាគរយ បានបំប៉នការងារគ្រប់គ្រង និងស្តង់ដារបណ្ណាល័យបឋមសិក្សា។ សៀវភៅអាន ៣០ ៨៤០ ក្បាល ឧបត្ថម្ភដោយដៃគូអភិវឌ្ឍនានា ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងបណ្ណាល័យ។

អង្គការរូមធូរីដសាងសង់បណ្ណាល័យ ២៥ ខ្នង រៀបចំបណ្ណាល័យ ៥៥ កន្លែង និងពង្រីកកម្មវិធីអំណាន ២១២ សាលា នៅខេត្តសៀមរាប និងព្រៃវែង។

*ប្រការនេះបានបណ្តុះទម្លាប់កុមារក្នុងការអាន និងស្រាវជ្រាវ។*

### *ការពិនិត្យតាមដាន និងវាយតម្លៃ*

ក្រសួងបាន៖

- ចុះអធិការកិច្ច និងវាយតម្លៃការងារធានាគុណភាពអប់រំសាលាបឋមសិក្សា ១១៧
- ចុះសិក្សាស្រាវជ្រាវវាស់ស្ទង់សមត្ថភាពកម្រិតសមមូល ខេត្ត ៥ គឺតាកែវ កំពង់ចាម សៀមរាប បាត់ដំបង និងព្រះសីហនុ ដើម្បីរៀបចំគោលការណ៍ និងយន្តការអនុវត្ត
- ផ្សព្វផ្សាយនិងអនុវត្តកម្រងសំណួរវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៅរាជធានី ខេត្ត ១៨
- បង្កើតឧបករណ៍សម្រាប់វាយតម្លៃការបកស្រាយទិន្នន័យ និងសរសេររបាយការណ៍ស្តីពីលទ្ធផលសិក្សារបស់សិស្សបឋមសិក្សាក្រោមការគាំទ្របច្ចេកទេសពីអង្គការកុងហ្វេមែន (CONFEMEN)។

*ប្រការនេះបានជួយកែលម្អ និងអភិវឌ្ឍសាលារៀនឱ្យស្របតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។*

### *ការងារបុគ្គលិក*

មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនាយក នាយិកាសាលារៀន ៥៩៤ នាក់ ស្រី ៩,៩ ភាគរយ បានបំប៉នសមត្ថភាពលើការងារគ្រប់គ្រងបុគ្គលិក។ បុគ្គលិកអប់រំ ៦០ ៣៦១ នាក់ ស្រី ៤០,៤ ភាគរយ បានធ្វើនិយ័តកម្មក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ តាមយុទ្ធសាស្ត្រកំណែទម្រង់ការងារគ្រប់គ្រងបុគ្គលិក។ គ្រូ ៩១ នាក់ ស្រី ៣៥ ភាគរយ បានពង្រាយពីសាលាលើសទៅសាលាខ្វះ។ គ្រូចេញថ្មី ៤ ២៦៩ នាក់ ស្រី ៦៤,៣ ភាគរយ បានបែងចែកទៅសាលារៀនដែលខ្វះគ្រូ។

## **ក.៣ ការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង**

ក្រសួងបាន៖

- ដាក់ឱ្យអនុវត្តបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា
- បំប៉នសមត្ថភាពគណៈកម្មការទ្រទ្រង់សាលារៀន ១ ៦៧៧ នាក់ ស្រី ១០,៣ ភាគរយ ស្តីពីតួនាទី និងភារកិច្ចចូលរួមអភិវឌ្ឍវិស័យអប់រំ
- បំប៉នសមត្ថភាពនាយកនាយិកា ៩៥០ នាក់ ស្រី ១៣,៩ ភាគរយ លើការអនុវត្តគម្រោងជំនួយកែលម្អសាលារៀន និងថវិកាដំណើរការសាលារៀន
- ចុះពិនិត្យតាមដាននិងពង្រឹងសមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌដល់នាយកសាលាគ្រូបង្រៀនលើការងារគ្រប់គ្រងដឹកនាំបច្ចេកទេស និងបរិស្ថាន
- បង្កើតឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល និងដាក់ឱ្យអនុវត្តនៅសាលាបឋមសិក្សាសាធារណៈទូទាំងប្រទេស

- កែសម្រួលឧបករណ៍វាយតម្លៃកម្មវិធីសាលាកុមារមេត្រី និងដាក់ឱ្យសាកល្បងក្នុងខេត្ត ៣ គឺខេត្តតាកែវ កំពត និងព្រះសីហនុ
- បញ្ចប់ផែនការមេកម្មវិធីសាលាកុមារមេត្រីកម្រិតអប់រំមូលដ្ឋាន (ថ្នាក់ទី១-ទី៩)
- ដាក់ឱ្យប្រើប្រាស់ផែនការគោលនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-២០១៨
- ដាក់ឱ្យប្រើប្រាស់ផែនការគោលអភិវឌ្ឍសមត្ថភាព ឆ្នាំ ២០១៤-២០១៨
- អភិវឌ្ឍផែនការសកម្មភាពថ្នាក់ពហុភាសា
- បំប៉នសមត្ថភាពលើការគ្រប់គ្រងនាយកសាលាមត្តេយ្យសិក្សា និងសាលារៀនចំណេះទូទៅ មានអ្នកចូលរួម ៣០០ នាក់ ស្រី ២៩ នាក់
- បណ្តុះបណ្តាលមន្ត្រីអប់រំ និងនាយក ៤០ នាក់ ស្រី ៤០ ភាគរយ ស្តីពីការគ្រប់គ្រងគ្រឹះស្ថានប្រកបដោយគុណភាព។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំបឋមសិក្សា | ជាក់ស្តែង ២០១៣-១៤ | ចំណុចដៅ ២០១៤-១៥ | ជាក់ស្តែង ២០១៤-១៥ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | ៧២,៥% | ៨៥% | ៧៣,៦% | → |
| ២ | អត្រាពិតចូលរៀនថ្មី | ៩៥,៣% | ១០០% | ៩៩,៤% | ↑ |
| | អត្រាពិតចូលរៀនថ្មី (ស្រី) | ៩៥,៣% | ១០០% | ១០០% | ↑ |
| ៣ | អត្រាពិតនៃការសិក្សា | ៩៨,២% | ៩៨% | ៩៧,៩% | → |
| | អត្រាពិតនៃការសិក្សា (ស្រី) | ៩៨,៥% | ៩៨% | ៩៨,៤% | → |
| ៤ | អត្រាបោះបង់ការសិក្សា | ១០,៥% | ៤% | ៨,៣% | → |
| | អត្រាបោះបង់ការសិក្សា (ស្រី) | ៨,៣% | ៤% | ៧,២% | → |
| ៥ | អត្រាត្រួតថ្នាក់ | ៤,៨% | ៣% | ៥,១% | ↓ |
| | អត្រាត្រួតថ្នាក់(ស្រី) | ៤,១% | ៣% | ៤,៣% | ↓ |
| ៦ | អត្រាបញ្ចប់ការសិក្សា | ៨៨,៩% | ១០០% | ៨៤,១% | ↓ |
| | អត្រាបញ្ចប់ការសិក្សា(ស្រី) | ៩០,២% | ១០០% | ៨៦,៦% | ↓ |
| ៧ | ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | ៨០% | ៨៥% | ៦២% | ↓ |
| ៨ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | ៧៦,៨% | ៩០% | ៧៨,៧% | ↓ |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅម.បឋមភូមិ(ស្រី) | ៨១,៤% | ៩០% | ៨១,២% | ↓ |
| ៩ | ភាគរយសាលាបឋមសិក្សាមាន | | | | |
| | បង្គន់អនាម័យនិងទឹកស្អាត | ៨២,៨៣% | ៨៧% | ៨០,៩% | ↓ |
| | កន្លែងសម្អាតដៃ | ៤៩,៥៩% | ៦០% | ៤៧,២% | ↓ |
| | ប្រអប់សង្គ្រោះបឋម | ៧០% | ៧០% | ២៩,៣% | ↓ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- អន្តរាគមន៍ក្នុងការផ្តល់ និងការពង្រីកសេវាអប់រំតំបន់ជួបការលំបាកនិងក្រុមកុមារបាត់បង់ឱកាសមិនទាន់បានពេញលេញ
- សនិទានកម្មគ្រូបង្រៀននៅមិនទាន់មានប្រសិទ្ធភាព
- ប្រសិទ្ធភាពនៃការអនុវត្តម៉ោងសិក្សា និងកម្មវិធីសិក្សានៅបឋមសិក្សាមិនទាន់សុក្រឹត
- ការប្រើប្រាស់ថវិកាសាលារៀន មិនបានផ្តោតលើការលើកកម្ពស់គុណភាពអប់រំ
- អភិបាលកិច្ចសាលារៀនមិនទាន់មានប្រសិទ្ធភាពខ្ពស់។

## ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ក. លទ្ធផលសម្រេចបាន

### ក.១ ការទទួលបានសេវាអប់រំប្រកបដោយសមធម៌

ឆ្នាំសិក្សា ២០១៤-២០១៥ គ្រឹះស្ថានមធ្យមសិក្សាមាន ១ ៧០៤ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៩ និងវិទ្យាល័យ ៤៥៥ ចែកចេញជាវិទ្យាល័យពីថ្នាក់ទី៧ ដល់ទី១២ មាន ៤២៥ និងវិទ្យាល័យពីថ្នាក់ទី១០ ដល់ទី១២ មាន ៣០។ អនុវិទ្យាល័យកើន ៥ និងវិទ្យាល័យកើន ១១ ក្នុងចំណោមវិទ្យាល័យទាំង ៤៥៥ មានវិទ្យាល័យធនធាន ៣៦ កើន ៧ បើធៀបនឹងឆ្នាំសិក្សា ២០១៣-២០១៤។

ឃុំ សង្កាត់ ១៤១ លើ ១ ៦៣៣ ស្មើនឹង ៨,៦ ភាគរយ មិនទាន់មានអនុវិទ្យាល័យ និងស្រុក ៨ លើ ១៩៧ ស្មើនឹង ៤ ភាគរយ មិនទាន់មានវិទ្យាល័យនៅឡើយដោយសារស្ថានភាពភូមិសាស្ត្រ និងស្ថានភាពប្រជាសាស្ត្រមិនអំណោយផល ជាពិសេសនៅតាមតំបន់កោះ និងតំបន់ព្រៃភ្នំ ដែលប្រជាពលរដ្ឋរស់នៅរាយប៉ាយ។ ស្រុកទាំងនោះរួមមានស្រុកថ្មបាំង ខេត្តកោះកុង ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ស្រុកវើនសៃ តាវែង អូរជុំ អណ្ដូងមាស អូរយ៉ាដាវ និងលំផាត់ ខេត្តរតនគិរី។ បច្ចុប្បន្ននេះ ទោះបីស្រុក និងឃុំ មានវិទ្យាល័យ និងអនុវិទ្យាល័យហើយក៏ដោយ ក៏នៅមានស្រុក និងឃុំមួយចំនួនទៀតនៅមានបញ្ហាខ្វះអគារសិក្សា អគារសិក្សាចាស់ទ្រុឌទ្រោម រោងដោល ដែលទាមទារឱ្យមានការដោះស្រាយជាបន្ទាន់។

អនុវិទ្យាល័យ ១៥,៣ ភាគរយ និងវិទ្យាល័យ ៤,២ ភាគរយ មិនទាន់មានបង្គន់អនាម័យ។ អនុវិទ្យាល័យ ៥៣,៨ ភាគរយ និងវិទ្យាល័យ ៤០,១ ភាគរយ មិនទាន់មានទឹកស្អាត។

មធ្យមសិក្សាបឋមភូមិមានបុគ្គលិកអប់រំ ៣២ ៥២៥ នាក់ ស្រី ១២ ៩៣៣ នាក់ ស្មើនឹង ៣៩,៧ ភាគរយ ថយ ៩១ នាក់ ស្រីកើន ១០៦ នាក់។ បុគ្គលិកបង្រៀនមាន ២៧ ៧៩៣ នាក់ ស្រី ១១ ៨៤៤ នាក់ ស្មើនឹង ៤២,៦ ភាគរយ ថយ ៣៦ នាក់ ស្រីកើន ៨០ នាក់។

*ទោះបីបុគ្គលិកអប់រំ និងបុគ្គលិកបង្រៀនមានការថយចុះក៏ដោយ ក៏អាចធានាបានដំណើរការបង្រៀន និងរៀន។*

មធ្យមសិក្សាទុតិយភូមិមានបុគ្គលិកអប់រំ ១៤ ០៥៥ នាក់ ស្រី ៤ ៥០៥ នាក់ ស្មើនឹង ៣២ ភាគរយ កើន ៧២៥ នាក់ ស្រី ៦៤៦ នាក់។ បុគ្គលិកបង្រៀន ១២ ២២៧ នាក់ ស្រី ៤ ០៥៣ នាក់ ត្រូវជា ៣៣,១ ភាគរយ កើន ៦៧០ នាក់ ស្រី ៦២០ នាក់។

*ទោះបីចំនួនគ្រូបង្រៀនកើនឡើងក៏ដោយ ក៏គ្រូបង្រៀនថ្នាក់ទី១២ មុខវិជ្ជាគីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា និងបរិស្ថានវិទ្យា នៅតាមវិទ្យាល័យមួយចំនួននៅមិនទាន់ឆ្លើយតបតាមតម្រូវការជាក់ស្តែង។*

សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈមាន ៥៤៦ ៨៦៤ នាក់ ស្រី ២៧៥ ២២២ នាក់ ស្មើនឹង ៥០,៣ ភាគរយ កើន ៨ ២៣៨ នាក់ ស្រីកើន ៧ ៤៤៩ នាក់។ សិស្សមធ្យមសិក្សាបឋមភូមិឯកជនមាន ៣ ៦១៥ នាក់ ស្រី ១ ៩០៦ នាក់ ស្មើនឹង ៥២,៧ ភាគរយ។

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥៥,១ ភាគរយ ស្រី ៥៦,២ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិសាធារណៈ ៥៣,៣ ភាគរយ ស្រី ៥៥,៣ ភាគរយ និងអត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិឯកជន ១,៨ ភាគរយ ស្រី ០,៩ ភាគរយ។

*ប្រការនេះបញ្ជាក់ឱ្យឃើញថា អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិមានការកើនឡើង និងអត្រាបោះបង់ការសិក្សានៅបឋមសិក្សាថយចុះ។*

សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈមាន ២៦២ ០៧២ នាក់ ស្រី ១២៨ ៥៩៤ នាក់ ស្មើនឹង ៤៩ ភាគរយ ថយ ៤ ២២១ នាក់ ស្រីកើន ១ ៥៥៧ នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជនមាន ២៦ ៩៤០ នាក់ ស្រី ១២ ៨៤០ នាក់ ស្មើនឹង ៤៧,៨ ភាគរយ។

អត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិ ២៥,៣ ភាគរយ ស្រី ២៦,៩ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយភូមិសាធារណៈ ២៤,២ ភាគរយ ស្រី ២៤,៦ ភាគរយ និងអត្រារួមនៃការសិក្សាមធ្យមសិក្សាទុតិយឯកជន ១,១ ភាគរយ ស្រី ២,៣ ភាគរយ។

*ប្រការនេះបញ្ជាក់ឱ្យឃើញថា អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើង។*

**តារាងទី៦ ៖ ស្ថិតិមធ្យមសិក្សា ប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៣-២០១៤ និង២០១៤-២០១៥**

| បរិយាយ | ២០១៣-២០១៤ | ២០១៤-២០១៥ | កើន-ថយ |
|---|---|---|---|
| **អនុវិទ្យាល័យ** | | | |
| សាលារៀន | ១ ២៤៤ | ១ ២៤៩ | +៥ |
| បន្ទប់រៀន | ៦ ៨៩២ | ៦ ៥៩១ | +៩៩ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យសរុប | ១៧ ៧៧០ | ១៨ ០៩៦ | +៣២៦ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យស្រី | ៦ ៥៦០ | ៦ ៩៨៦ | +៤២៦ |
| ថ្នាក់រៀនមធ្យមសិក្សាបឋមភូមិ | ១២ ២៨១ | ១២ ៣៩០ | +១០៩ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិសរុប | ៣២ ៦១៦ | ៣២ ៥២៥ | -៩១ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិស្រី | ១២ ៨២៧ | ១២ ៩៣៣ | +១០៦ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិសរុប | ២៧ ៨២៩ | ២៧ ៧៩៣ | -៣៦ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិស្រី | ១១ ៧៦៤ | ១១ ៨៤៤ | +៨០ |
| សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈសរុប | ៥៣៨ ៦២៦ | ៥៤៦ ៨៦៤ | +៨ ២៣៨ |
| សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈស្រី | ២៦៧ ៧៧៣ | ២៧៥ ២២២ | +៧ ៤៤៩ |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនសរុប | ១ ៨២៨ | ៣ ៦១៥ | +១ ៧៨៧ |

| | | | |
|---|---|---|---|
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនស្រី | ១ ០៣២ | ១ ៩០៦ | +៨៧៤ |
| **វិទ្យាល័យ** | | | |
| សាលារៀន | ៤៤៤ | ៤៥៥ | +១១ |
| បន្ទប់រៀន | ១០ ០១៦ | ១០ ០៩៦ | +៨០ |
| បុគ្គលិកអប់រំនៅវិទ្យាល័យសរុប | ២៨ ១៧៦ | ២៨ ៤៨៤ | +៣០៨ |
| បុគ្គលិកអប់រំនៅវិទ្យាល័យស្រី | ១០ ១២៦ | ១០ ៤៥២ | +៣២៦ |
| ថ្នាក់រៀនមធ្យមសិក្សាទុតិយភូមិ | ៦ ០៣១ | ៥ ៩៣៣ | -៩៨ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិសរុប | ១៣ ៣៣០ | ១៤ ០៥៥ | +៧២៥ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិស្រី | ៣ ៨៥៩ | ៤ ៥០៥ | +៦៤៦ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិសរុប | ១១ ៥៥៧ | ១២ ២២៧ | +៦៧០ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិស្រី | ៣ ៤៣៣ | ៤ ០៥៣ | +៦២០ |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈសរុប | ២៦៦ ២៩៣ | ២៦២ ០៧២ | -៤ ២២១ |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈស្រី | ១២៧ ០៣៧ | ១២៨ ៥៩៤ | +១ ៥៥៧ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនសរុប | ២៧ ៦៤៤ | ២៦ ៩៤០ | -៧០៤ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនស្រី | ១២ ៩៧៥ | ១២ ៨៨០ | -៩៥ |

សិស្សចូលរៀនថ្មីអប់រំបច្ចេកទេសមាន ៨០៥ នាក់ ស្រី ៣០៧ នាក់ ស្មើនឹង ៣៨,១ ភាគរយ។ សិស្សវិទ្យាល័យកំពង់ឈើទាលខេត្តកំពង់ធំ ២៩០ នាក់ ស្រី ១៣៤ នាក់ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន-រ៉ូតា** ខ្សាច់កណ្តាល ១២០ នាក់ ស្រី ៤ នាក់ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ខេត្តកំពង់ឆ្នាំង ៥១ នាក់ ស្រី ២២ នាក់។

*ប្រការនេះបញ្ជាក់ថា សិស្សកាន់តែចាប់អារម្មណ៍ក្នុងការជ្រើសរើសជំនាញបច្ចេកទេសបម្រើឱ្យទីផ្សារការងារ និងប្រកបមុខរបរចិញ្ចឹមជីវិត។*

## តារាងទី៧ ៖ ស្ថិតិសិស្សនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

| បរិយាយ | ២០១៣-១៤ | ២០១៤-១៥ | កើន-ថយ |
|---|---|---|---|
| សិស្សវិទ្យាល័យកំពង់ឈើទាល (សរុប) | ៥៦១ | ៥៩៧ | +៣៦ |
| សិស្សវិទ្យាល័យកំពង់ឈើទាល (ស្រី) | ២២៥ | ២៧៣ | +៤៨ |
| សិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន-រ៉ូតាខ្សាច់កណ្តាល (សរុប) | ៧៦ | ១៧៥ | +៩៩ |
| សិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន-រ៉ូតាខ្សាច់កណ្តាល (ស្រី) | ៥ | ៧ | +២ |
| សិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី (សរុប) | ៥១ | ៩៦ | +៤៥ |

| | | | |
|---|---|---|---|
| សិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី (ស្រី) | ២៨ | ៤៦ | +១៨ |

## រូបភាពទី៧ ៖ ការប្រែប្រួលចំនួនសិស្សអប់រំបច្ចេកទេស (សរុប និងស្រី)

វិទ្យាល័យកំពង់ឈើទាលខេត្តកំពង់ធំ




វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
សម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន-រ៉ូតា ខ្សាច់កណ្តាល




វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
សម្តេចព្រះបរមនាថ នរោត្តម សីហមុនី




## តារាងទី៨ ៖ ចំនួនសិស្សថ្មីផ្នែកអប់រំបច្ចេកទេសតាមជំនាញឆ្នាំសិក្សា២០១៤-២០១៥

| សិស្ស | អេឡិចត្រូនិច | | អគ្គិសនី | | បសុវប្បកម្ម | | ក្សេត្រសាស្ត្រ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិស្សជ្រើសរើសថ្មី | ១៦៧ | ៣៤ | ៣១១ | ៣៣ | ២៣៤ | ១៧២ | ៩៣ | ៦៧ | ៨០៥ | ៣០៧ |

### ការអនុវត្តកម្មវិធីនានា

### *កម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សា*

កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិ បានគ្របដណ្តប់លើសាលារៀន ៨០៩ ដែលមានសិស្សអាហារូបករណ៍ ៥៩ ៩៧១ នាក់ ស្រី ៣៥ ៨៥១ នាក់ ស្មើនឹង ៥៩,៧ ភាគរយ គាំទ្រដោយថវិកាជាតិ។ ក្រៅពីនេះ អាហារូបករណ៍ផ្តល់ដោយដៃគូអភិវឌ្ឍនានាក្រោមរូបភាពផ្សេងៗគ្នា ដូចជាការផ្តល់មធ្យោបាយធ្វើដំណើរ ឯកសណ្ឋាន ស្បែកជើង សម្ភារសិក្សាជាដើម។ ដៃគូអភិវឌ្ឍទាំងនោះដូចជា គម្រោងមូលនិធិអភិវឌ្ឍវិស័យអប់រំកម្ពុជា ៣៥៣ នាក់ ស្រី ២០៥ នាក់ អង្គការអនាគតកុមារអន្តរជាតិខេត្តបាត់ដំបង ៨៩ នាក់ ស្រី ៥៨ នាក់ គម្រោងលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមាររបស់អង្គការទស្សនៈពិភពលោក ១ ២៥១ នាក់ ស្រី ៥៩០ នាក់។

សិស្សក្រីក្រ និងរៀនពូកែនៅមធ្យមសិក្សាទុតិយភូមិបានទទួលអាហារូបករណ៍ ១ ០០០ នាក់ ស្រី ៦០០ នាក់ ស្មើនឹង ៦០ ភាគរយ គាំទ្រដោយគម្រោងលើកកម្ពស់គុណភាពអប់រំ បានបញ្ចប់នៅខែតុលា ឆ្នាំ២០១៤។

*កម្មវិធីនេះ បានជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា។*

### *ការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាបឋមភូមិ*

សាលារៀនមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី ៩២៣ ស្មើនឹង ៥៥,១ ភាគរយ នៃសាលារៀនដែលមានកម្រិតមធ្យមសិក្សាបឋមភូមិ ១ ៦៧៤ សាលា ក្នុងនោះ៖

- សាលាកុមាមេត្រីបែបម្ចាស់ការ ៧២៣ ស្មើនឹង ៧៨,៣ ភាគរយ បានអនុវត្តដោយចាប់ផ្តើមពីការថ្លៃប្រឌិតតាមលទ្ធភាព និងតាមលក្ខណសម្បត្តិជាក់ស្តែង
- សាលាកុមារមេត្រី ១០០ ស្មើនឹង ១០,៨ ភាគរយ បានផ្ទេរពីសាលារៀនមានប្រសិទ្ធភាពរបស់គម្រោងទ្រទ្រង់វិស័យអប់រំកម្ពុជា
- សាលាកុមារមេត្រី ១០០ ស្មើនឹង ១០,៨ ភាគរយ គាំទ្រដោយគម្រោងកែលម្អអប់រំកម្រិត មូលដ្ឋាននៅកម្ពុជាបានដំណើរការនៅខេត្តក្រចេះកំពង់ចាម និងសៀមរាប។ ក្រោមរូបភាពសាលាកុមារមេត្រីកម្រិតមូលដ្ឋាន ៥ កម្រិតមធ្យម ៥១ កម្រិតអភិវឌ្ឍ ៩៤ ក្នុងនោះនៅទីប្រជុំជនមាន ២៥ សាលា តំបន់ជនបទ ៥២ សាលា និងតំបន់ដាច់ស្រយាល ២៣ សាលា។

*កម្មវិធីនេះបានរួមចំណែកកាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។*

### *សាលារៀនជំនាន់ថ្មី*

ក្រសួងបានបង្កើតឱ្យមានសាលារៀនជំនាន់ថ្មី ដែលបានអនុវត្តសាកល្បង នៅខេត្តកំពង់ចាម (អនុវិទ្យាល័យអនុវត្ត) ដោយផ្តោតការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អសាលារៀន ជាពិសេសលើការគ្រប់គ្រងថវិកា ដំណើរការបង្រៀននិងរៀនលើបំណិនកុំព្យូទ័រ ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ សួនបំណិនជីវិត ដំណើរការក្រុមប្រឹក្សាយុវជន និងការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន។

### *ការអនុវត្តកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា*

ក្រសួងបាន៖

- បន្តអនុវត្តកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា នៅតាមសាលាមធ្យមសិក្សា ៣២២ ក្នុង ៤៥ ស្រុកនៃខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ និងស្វាយរៀង។ សាលារៀន ១០៧ បានអនុវត្តប្រព័ន្ធរំលឹកជាមុន ១០៨ អនុវត្តប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ និង១០៧ ជាសាលារៀន សម្រាប់ប្រៀបធៀបជាមួយសាលាដែលមិនបានទទួលអន្តរាគមន៍ពីកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សារបស់អង្គការខេប
- សាកល្បងឧបករណ៍អធិការកិច្ចតាមប្រធានបទ ស្តីពីអត្រាបោះបង់ការសិក្សានៅថ្នាក់ទី៩ ចំនួន ១៥ សាលា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងតាកែវ។

### *ការអប់រំបច្ចេកទេស*

ក្រសួងបាន៖

- ចុះសិក្សាស្រាវជ្រាវដើម្បីពង្រីកកម្មវិធីអប់រំបច្ចេកទេសនៅខេត្តត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង និងកំពង់ស្ពឺ
- អភិវឌ្ឍផែនការគោលស្តីពីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ
- អភិវឌ្ឍកម្មវិធីសិក្សាអប់រំបច្ចេកទេស ៥ មុខជំនាញ រួមមានមេកានិក អគ្គិសនី អេឡិចត្រូនិច កសិកម្ម និងគណនេយ្យហិរញ្ញវត្ថុ។

### *ការអប់រំបំណិនជីវិត*

ក្រសួងបានចុះពិនិត្យតាមដានការអនុវត្តកម្មវិធីបំណិនជីវិតនៅ ៤០ សាលា លើការអនុវត្តមុខវិជ្ជាគេហវិទ្យា កសិកម្ម និងកុំព្យូទ័រ។ គ្រូមធ្យមសិក្សាទទួលបន្ទុកផ្នែកបំណិនជីវិត ៥៨៦ នាក់ ស្រី ៣២ ភាគរយ បានបំប៉នផ្នែកគេហវិទ្យា កសិកម្ម កាត់ដេរសំលៀកបំពាក់ ការបណ្តុះផ្សិតអំបោះ និងផ្សិតចំបើង។

*ប្រការនេះបានរួមចំណែកកាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សា និងជួយលើកកម្ពស់គុណភាពជីវិតប្រចាំថ្ងៃ។*

### *ការតម្រង់ទិសវិជ្ជាជីវៈ*

ក្រសួងបានផ្សព្វផ្សាយឯកសារតម្រង់ទិសវិជ្ជាជីវៈដល់អ្នកពាក់ព័ន្ធ ៤ ខេត្ត ដែលមានអ្នកចូលរួម ២៩៤ នាក់ ស្រី ១៨ ភាគរយ។ *កម្មវិធីនេះបានជួយជំរុញសិស្ស និងអ្នកអាណាព្យាបាលឱ្យយល់ពីតម្លៃនៃការអប់រំបច្ចេកទេស។*

### *ការប្រឹក្សាអាជីព*

ក្រសួងបាន៖

- សហការជាមួយអង្គការ FINN CHURCH AID រៀបចំអភិវឌ្ឍឯកសារស្តីពីការផ្តល់ការប្រឹក្សាអាជីពនៅតាមសាលារៀនមធ្យមសិក្សា
- បង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងការកសាងឯកសារប្រឹក្សាអាជីព និងបណ្តុះបណ្តាលគ្រូបង្គោល ១០ នាក់ ស្រី ៦ នាក់ ស្តីពីការប្រឹក្សាអាជីព។

*ប្រការនេះ ជួយសិស្សឱ្យត្រៀមខ្លួនក្នុងការជ្រើសរើសអាជីពស្របតាមសក្តានុពល។*

## គ.២ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតប

អត្រាឡើងថ្នាក់នៅមធ្យមសិក្សាបឋមភូមិថយ ០,២ ភាគរយ និងមធ្យមសិក្សាទុតិយភូមិថយ ១៥,៩ ភាគរយ។ អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិកើន ០,៤ ភាគរយ និងមធ្យមសិក្សាទុតិយភូមិកើន

២,៤ ភាគរយ។ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិថយ ០,២ ភាគរយ និងមធ្យមសិក្សាទុតិយភូមិកើន ១៣,៥ ភាគរយ។

*ប្រការនេះ បណ្តាលមកពីភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការថយចុះ ហើយសិស្សដែលប្រឡងធ្លាក់បានមកចុះឈ្មោះចូលរៀនមាន ២៤ ភាគរយ ធៀបនឹងសិស្សប្រឡងធ្លាក់សរុប។ ចំណែកសិស្សមួយចំនួនទៀតបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្ររង និងជំនាញផ្សេងៗ។ អត្រាឆ្លងភូមិសិក្សានៅគ្រប់កម្រិត មានលក្ខណៈល្អជាងឆ្នាំមុន។*

**តារាងទី៩ ៖ អត្រាលំហូរសិក្សានៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១២-២០១៣ និង ២០១៣-២០១៤**

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | មធ្យមសិក្សាទុតិយភូមិ | |
|---|---|---|---|---|
| | ២០១២-១៣ | ២០១៣-១៤ | ២០១២-១៣ | ២០១៣-១៤ |
| អត្រាឡើងថ្នាក់ | ៧៧,៤ | ៧៧.២ | ៨៤,៤ | ៦៨,៥ |
| អត្រាត្រួតថ្នាក់ | ១,៤ | ១,៨ | ១,៦ | ៤,០ |
| អត្រាបោះបង់ការសិក្សា | ២១,២ | ២១ | ១៤,០ | ២៧,៥ |
| អត្រាឆ្លងភូមិសិក្សា | ៧៦,៨ | ៧៨,៧ | ៧០,២ | ៧១,១ |

ផលធៀបសិស្ស-គ្រូកើនពី ១៩,៤ មក ១៩,៧ នៅមធ្យមសិក្សាបឋមភូមិ និងថយពី ២៣ មក ២១,៤ នៅមធ្យមសិក្សាទុតិយភូមិ។ ផលធៀបសិស្ស-ថ្នាក់នៅមធ្យមសិក្សាបឋមភូមិប្រែប្រួលពី ៤៣,៩ ទៅ ៤៤,១។ ផលធៀបសិស្ស-បន្ទប់មានការប្រែប្រួលតិចតួចនៅមធ្យមសិក្សាបឋមភូមិ និងថយពី ៤៩,២ មក ៤៨,៥ នៅមធ្យមសិក្សាទុតិយភូមិ។

**តារាងទី១០ ៖ ផលធៀបសំខាន់ៗនៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១២-២០១៣ និង ២០១៣-២០១៤**

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | មធ្យមសិក្សាទុតិយភូមិ | |
|---|---|---|---|---|
| | ២០១៣-១៤ | ២០១៤-១៥ | ២០១៣-១៤ | ២០១៤-១៥ |
| ផលធៀបសិស្ស-គ្រូ | ១៩,៤ | ១៩,៧ | ២៣ | ២១,៤ |
| ផលធៀបសិស្ស-ថ្នាក់រៀន | ៤៣,៩ | ៤៤,១ | ៤៤,២ | ៤៤,២ |
| ផលធៀបសិស្ស-បន្ទប់រៀន | ៤៨,៥ | ៤៨,៥ | ៤៩,២ | ៤៨,៥ |

បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ៩៣,៦ ភាគរយ កើន ០,៥៩ ភាគរយ ស្រី ៩៦,១ ភាគរយ កើន ០,៥៦ ភាគរយ។

បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៤០,៦ ភាគរយ ថយ ៤៦,១ ភាគរយ ស្រី ៤៣,២ ភាគរយ ថយ ៤៩,៥ ភាគរយ។ សិស្សជាប់និទ្ទេស A មាន ១១ នាក់ ស្រី ៥ នាក់ បានទទួលរង្វាន់លើកទឹកចិត្តពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងអាហារូបករណ៍សិក្សានៅគ្រឹះស្ថានឧត្តមសិក្សា។

## រូបភាពទី៨ ៖ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាឆ្នាំសិក្សា ២០១៣-២០១៤




## រូបភាពទី៩ ៖ លទ្ធផលប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឆ្នាំសិក្សា២០១៣-២០១៤




បេក្ខជនប្រឡងជាប់ផ្នែកអប់រំបច្ចេកទេសឆ្នាំទី៣ ជំនាញអគ្គិសនី ៣២ នាក់ ស្រី ៣ នាក់ អេឡិចត្រូនិច ២៩ នាក់ ស្រី ១ នាក់ និងក្សេត្រសាស្ត្រ ២៥ នាក់ ស្រី ១៧ នាក់ បសុវប្បកម្ម ៣០ នាក់ ស្រី ១៤ នាក់។

### *លទ្ធផលប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស*

ក្រសួងបាន៖

- រៀបចំប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យាថ្នាក់ទី៩ និងទី១២ និងជ្រើសរើសជ័យលាភី ៥៨ នាក់ ស្រី ២៤ នាក់ លើចំនួនបេក្ខជនសិស្សពូកែថ្នាក់រាជធានី ខេត្ត ៤៨០ នាក់ ស្រី ២១០ នាក់ ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសបាន ១០ នាក់

- បញ្ជូនសិស្សចូលរួមការប្រកួតប្រជែងគណិតវិទ្យាអូឡាំព្យាដអាស៊ីប៉ាស៊ីហ្វិកលើកទី២៦ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ីលើកទី១៥ នៅសិង្ហបុរី និងការប្រកួតប្រជែងរូបវិទ្យាអន្តរជាតិលើកទី៤៥ នៅកាហ្សាក់ស្ថាន។

សិស្ស ២ នាក់ បានទទួលពានរង្វាន់ល្អប្រសើរបំផុត និងសិស្ស ១ នាក់ ទទួលបានពានរង្វាន់ពិសេសនៅក្នុងការប្រកួតប្រជែងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ និងគណិតវិទ្យាវ័យក្មេងរបស់ស៊ីមេអូលើកទី៩ នៅម៉ាឡេស៊ី។

*ប្រការនេះជួយលើកទឹកចិត្តឱ្យសិស្សខិតខំប្រឹងប្រែងរៀនសូត្រ និងជួយលើកកិត្តិយសបុគ្គល និងជាតិ។*

## *ការអនុវត្តកម្មវិធីសិក្សា*

តាមរយៈការចុះពិនិត្យតាមដានការគ្រប់គ្រង ការបង្រៀន និងរៀននៅតាមគ្រឹះស្ថានសិក្សា ក្រសួងបានជំរុញការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល និងការបង្រៀនតាមបែបអន្តរមុខវិជ្ជាក្នុងកម្មវិធីសិក្សាគួបផ្សំនឹងការប្រើសម្ភារឧបទេស បន្ទប់ពិសោធន៍សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ។ លទ្ធផលថ្នាក់ទី៩ និងថ្នាក់ទី១២ អនុវត្តកម្មវិធីសិក្សាបាន ១០០ ភាគរយ ចំណែកកម្រិតថ្នាក់ដទៃទៀតអនុវត្តបានពី ៨៧ ទៅ ៩៧ ភាគរយ នៃកម្មវិធីសិក្សា។

វិទ្យាល័យធនធាន ៣៦ បានដំណើរការរៀន និងបង្រៀនដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើផ្នែកកុំព្យូទ័រ ពិសោធន៍ផ្នែកវិទ្យាសាស្ត្រ និងបណ្ណាល័យ។

គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ ១៤,៤ ភាគរយ អនុវត្តការសិក្សាពីរវេន។ គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិអនុវត្តការសិក្សាពីរវេនបានថយពី ៤៦ ភាគរយ មក ៣៧,១ ភាគរយ។

គ្រូបង្រៀនថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន ១៤៤ នាក់ ស្រី ២៥ ភាគរយ បានបំប៉នស្តីពីការប្រើប្រាស់ស្តង់ដារកម្មវិធីសិក្សាថ្នាក់ទី៩ និងទី១២ ។

ក្រុមការងារពិនិត្យឡើងវិញកម្មវិធីសិក្សា ៤៧ នាក់ ស្រី ២៥ ភាគរយ បានបំប៉នស្តីពីការពិនិត្យកម្មវិធីសិក្សា និងសរសេរសេចក្តីព្រាងកម្មវិធីសិក្សាថ្មី ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ។

## *ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៨*

ក្រសួងបានចុះធ្វើតេស្តវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៨ នៅ ២០០ សាលារៀន។ ក្រសួងបានបញ្ចូលទិន្នន័យតេស្តវាយតម្លៃថ្នាក់ជាតិលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យាថ្នាក់ទី៨ រួចរាល់ និងកំពុងវិភាគលទ្ធផលតេស្ត។

*ប្រការនេះនឹងជួយផ្តល់ព័ត៌មានដល់អ្នកអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សា និងអ្នកពាក់ព័ន្ធ ដើម្បីកែលម្អការបង្រៀន និងរៀន។*

## *ការផ្គត់ផ្គង់សៀវភៅសិក្សាគោល*

ការផ្គត់ផ្គង់សៀវភៅសិក្សាគោលតាមផលធៀបសៀវភៅ-សិស្ស ១:១ (សិស្ស ១ នាក់ ទទួលបានសៀវភៅ ១ សម្រាប់មាន ៤ ក្បាល) នៅថ្នាក់ទី៧-៩ សម្រេចបាន ១០០ ភាគរយ លើចំណុចដៅ។ តាមផលធៀបសៀវភៅ-សិស្ស ១:១ (សិស្ស ១ នាក់ ទទួលបានសៀវភៅ ១ សម្រាប់មាន ៧ ក្បាល) នៅថ្នាក់ទី១០ សម្រេចបាន ៩៧,៨ ភាគរយ។ តាមផលធៀបសៀវភៅ-សិស្ស ២:១ (សិស្ស ២ នាក់ ទទួលបានសៀវភៅ ១ សម្រាប់មាន ១០ ក្បាល) នៅថ្នាក់ទី១១-១២ សម្រេចបាន៩៨,៧ ភាគរយ។

*ប្រការនេះជួយសិស្សឱ្យមានលទ្ធភាពក្នុងការសិក្សា និងស្រាវជ្រាវដើម្បីសម្រេចបានតាមគោលដៅនៃកម្មវិធីសិក្សា។*

## *ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន*

ក្រសួងបាន៖

- បញ្ជូនគ្រូផ្នែកអប់រំបច្ចេកទេស ២ នាក់ ជាស្ត្រីទៅរៀនបន្តថ្នាក់បរិញ្ញាបត្រ និងគ្រូផ្នែកអប់រំបច្ចេកទេស និងផ្នែកចំណេះទូទៅជំនាញកសិកម្ម អេឡិចត្រូនិច បសុវប្បកម្ម កុំព្យូទ័រ រូបវិទ្យា និងការរៀបចំកម្មវិធីសិក្សា ៧ នាក់ ស្រី ២៨,៥ ភាគរយ នៃវិទ្យាល័យកំពង់ឈើទាលទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅថៃ
- បំប៉នគ្រូបង្រៀន ៣ ៧៦៥ នាក់ ស្រី ៣៤,៩ ភាគរយ នៅអនុវិទ្យាល័យ ៦៧៥ ស្តីពីឯកសារណែនាំគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រភាគ ៣ គ្រូបង្រៀនថ្នាក់ទី៧ ចំនួន ៤ ២៤៤ នាក់ ស្រី ៣១,៣ ភាគរយ ស្តីពីការសិក្សាស្រាវជ្រាវមេរៀន គ្រូឧទ្ទេស និងគ្រូបង្រៀនអនុវិទ្យាល័យវិទ្យាល័យ ២៤១ នាក់ ស្រី ២៦,៩៧ ភាគរយ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ២៣៦ នាក់ ស្រី ៣៧,២ ភាគរយ ស្តីពីកម្មវិធីសាលាកុមារមេត្រីមធ្យមសិក្សា
- បំប៉ននាយកនាយករងគ្រឹះស្ថានមធ្យមសិក្សា ៥០០ នាក់ ស្រី ១៣,៥ ភាគរយ ស្តីពីការងារគ្រប់គ្រងនិងដឹកនាំ គ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៨១ នាក់ ស្រី ៣៣,៣ ភាគរយ ស្តីពីការអប់រំបញ្ចូលគ្នា
- បញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ជំនាន់ទី២៤ ចំនួន ១ ៣១១ នាក់ ស្រី ៥៨, ៩ ភាគរយ គ្រូបង្រៀនកម្រិតឧត្តមបរិញ្ញា+១ ជំនាន់ទី១៩ ចំនួន ១ ០០០ នាក់ ស្រី ២៨,៤ ភាគរយ
- បំប៉នគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូកម្រិតមូលដ្ឋាន ១ ៥០០ នាក់ ស្រី ៤៧,០ ភាគរយ ជំនាន់ទី៧ វេនទី២ និង ១ ៩៩៤ នាក់ ស្រី ៤៥, ៤ ភាគរយ ជំនាន់ទី៨ វេនទី១

- បញ្ជូនមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ១ នាក់ ទៅសិក្សាបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកកម្មវិធីសិក្សា នៅថៃ។

*ការងារបណ្ណាល័យ*

បណ្ណារក្ស និងមន្ត្រីទទួលបន្ទុក ១ ២៧៨ នាក់ ស្រី ៣០ ភាគរយ បានទទួលការបំប៉នស្តីពីការផ្គត់ផ្គង់ និងគ្រប់គ្រងសៀវភៅសិក្សាគោល។

មន្ត្រីទទួលបន្ទុកការងារបណ្ណាល័យថ្នាក់មន្ទីរ នាយកសាលា បណ្ណារក្ស ៨៨ នាក់ ស្រី ៦០ ភាគរយ នៅ ១៥ ខេត្ត បានទទួលការបំប៉នស្តីពីការងារបច្ចេកទេសបណ្ណាល័យនៅមធ្យមសិក្សា។

*ប្រការនេះបានធ្វើឱ្យបណ្ណារក្ស និងមន្ត្រីទទួលបន្ទុកការងារបណ្ណាល័យមានជំនាញគ្រប់គ្រងបច្ចេកទេសបណ្ណាល័យច្បាស់លាស់ និងជំរុញការបណ្តុះទម្លាប់សិស្សក្នុងការអាន និងការស្រាវជ្រាវ។*

## ក.៣ ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

*ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្អែកលើលទ្ធផល*

ក្រសួងបាន៖

- ចុះពិនិត្យតាមដានលើការគ្រប់គ្រង ការបង្រៀន និងរៀននៅតាមគ្រឹះស្ថានមធ្យមសិក្សា ១៦០ ទូទាំងរាជធានី ខេត្ត ក្នុងនោះមានវិទ្យាល័យ ១២០
- ចុះពិនិត្យតាមដានការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិនៅតាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ ១៦៤ ទូទាំងរាជធានី ខេត្ត ក្នុងនោះមានវិទ្យាល័យ ៧៦
- ចុះពិនិត្យតាមដាន និងវាយតម្លៃដំណើរការប្រតិបត្តិអគារធនធានទាំង ៣៦ រៀងរាល់ត្រីមាស
- ចុះអធិការកិច្ចសាលារៀនចំណេះទូទៅ ២២ និងពិនិត្យតាមដានវាយតម្លៃការងារធានាគុណភាពអប់រំ ២៧
- ចុះពិនិត្យតាមដានការបង្រៀននិងរៀន និងការប្រឡងឆមាសផ្នែកអប់រំបច្ចេកទេសនៅវិទ្យាល័យកំពង់ឈើទាល វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន- រ៉ូតា** ខ្សាច់កណ្តាល និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**។

*ប្រការនេះជួយកែលម្អការងារដឹកនាំ គ្រប់គ្រង ការបង្រៀន និងរៀន និងការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន។*

*ការអភិវឌ្ឍសមត្ថភាព*

មន្ត្រី ៥ នាក់ បានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងផែនការ នៅវិទ្យាស្ថានជាតិអប់រំ។ មន្ត្រី ៧ នាក់ ស្រី ៣ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅវិទ្យាស្ថានភាសាបរទេស។ មន្ត្រី ១ នាក់ជាស្ត្រី បានប្រឡងជាប់ជាគ្រូឧទ្ទេសសម្រាប់បណ្តុះបណ្តាលអធិការនៅវិទ្យាស្ថានជាតិអប់រំ។

ក្រសួងបាន៖

- សហការបើកវគ្គបំប៉នស្តីពីការបង្រៀន និងរៀន ការអប់រំការប្រឆាំងអំពើពុករលួយនៅមធ្យមសិក្សាទុតិយភូមិដល់គ្រូសីលធម៌ ពលរដ្ឋវិជ្ជានៅខេត្តបាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ និងព្រះសីហនុ មានអ្នកចូលរួម ១៩៦ នាក់ ស្រី ៧៨ នាក់
- បំប៉នគ្រូឧទ្ទេសស្តីពីការកសាងឯកសារសម្រាប់បំប៉នប្រធាន អនុប្រធានមណ្ឌលសំណេរ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានអ្នកចូលរួម ១៩ នាក់ ស្រី ២ នាក់
- បំប៉នមន្ត្រីអប់រំ ស្តីពីកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានអ្នកចូលរួម ២២៩ នាក់ ស្រី ៣១ នាក់
- បំប៉នសមត្ថភាពមន្ត្រីអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីឯកសារណែនាំប្រធាន អនុប្រធានមណ្ឌលសំណេរ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតាមភូមិភាគ និងរាជធានីភ្នំពេញ ៩៦២ នាក់ ស្រី ៩៨ នាក់ ក្នុងនោះ ២៨៣ នាក់ ស្រី ២៨ នាក់ ឧបត្ថម្ភដោយថវិកាកម្មវិធី និង ៦៧៩ នាក់ ស្រី ៧០ នាក់ ឧបត្ថម្ភដោយថវិកាមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព
- បំប៉នសមត្ថភាពស្តីពីការរៀបចំអក្សរសម្ងាត់ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២ វគ្គ ដល់បុគ្គលិកអប់រំអង្គភាពក្រោមឱវាទក្រសួង ៤៤៧ នាក់ ស្រី៩០ នាក់
- បំប៉នក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីការកសាងឯកសារសាលាកុមារមេត្រីនៅមធ្យមសិក្សាមានអ្នកចូលរួម ៤០ នាក់ ស្រី ១២ នាក់
- បំប៉នសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីការអនុវត្តកម្មវិធីកុមារមេត្រីនៅមធ្យមសិក្សាសម្រាប់ប្រធានក្រុមបច្ចេកទេស មានអ្នកចូលរួម ៦៣ នាក់ ស្រី ២៤ នាក់
- បំប៉នសមត្ថភាពស្តីពីការអនុវត្តអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដល់មន្ត្រីការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡា មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា នាយក នាយករង និងលេខាធិការសាលាមធ្យមសិក្សានៅទូទាំងប្រទេស មានអ្នកចូលរួម ៣ ៦៧៨នាក់ ស្រី ៤០៥ នាក់ ឧបត្ថម្ភថវិកាដោយគម្រោងគាំទ្រវិស័យអប់រំទី២
- បំប៉ន និងផ្សព្វផ្សាយឯកសារអប់រំតម្រង់វិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិ ៤ ខេត្ត មានអ្នកចូលរួម ២៩៤ នាក់ ស្រី ៥៣ នាក់
- បំប៉នគ្រូផ្នែកអប់រំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិនៅខេត្តព្រះវិហារ កំពង់ចាម និងមណ្ឌលគិរី មានអ្នកចូលរួម ៥៨៦ នាក់ ស្រី ១៨៧ នាក់ លើជំនាញកាត់ដេរសម្លៀកបំពាក់ ការបណ្តុះផ្សិតអំបោះ និងផ្សិតចំបើង។

បុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសនិងវិជ្ជាជីវៈ ១ នាក់ បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាធារណរដ្ឋកូរ៉េ វគ្គបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងស្តីពីការអភិវឌ្ឍបច្ចេកទេសនៅមធ្យមសិក្សានៅសាធារណរដ្ឋកូរ៉េ ១ នាក់ វគ្គរៀបចំសរសេរកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមនៅថៃ ១ នាក់ វគ្គបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅជប៉ុន ២ នាក់ និងវគ្គបណ្តុះបណ្តាលស្តីពីមគ្គុទ្ទេសក៍នៃអាជីព នៅអ៊ីតាលី ១ នាក់។

*ការបំប៉នសមត្ថភាពមន្ត្រីអប់រំលើការងារប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានជួយឱ្យការងារកំណែទម្រង់នេះទទួលបានជោគជ័យ។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|
| | | ២០១៣-១៤ | ២០១៤-១៥ | ២០១៤-១៥ | |
| ១ | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ២១,២% | ១១% | ២១% | ↓ |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | ២០,៩% | ១១% | ២០,៣% | ↓ |
| ២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៥៥,៣% | ៦៧% | ៥៥,១% | ↓ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | ៥៦,២% | ៦៦% | ៥៦,២% | ↓ |
| ៣ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៦% | ៣១% | ២៥,៣% | ↓ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ(ស្រី) | ២៥,៧% | ២៨% | ២៦,៩% | ↓ |
| ៤ | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | ៧០,២% | ៨៣% | ៧១,១% | ↓ |
| | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ(ស្រី) | ៧១,៤% | ៨៣% | ៧២,៩% | ↓ |
| ៥ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៣៩,១% | ៥២% | ៤០,៣% | ↓ |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ស្រី) | ៤០% | ៥២% | ៤១,៨% | ↓ |
| ៦ | ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | ១០,៥% | ៩% | ១០,៩៧% | ↑ |
| ៧ | ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | ៥៥,៦% | ៦០% | ៥៣,១% | ↓ |
| ៨ | សាលាមធ្យមសិក្សាមានបង្គន់អនាម័យ | | | | |
| | មធ្យមសិក្សាបឋមភូមិ | ៦៣,៦% | ៩០% | ៦៣,១% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | ៩៨% | ១០០% | ៩៥,៨% | ↓ |
| ៩ | សាលាមធ្យមសិក្សាមានទឹកស្អាត | | | | |
| | មធ្យមសិក្សាបឋមភូមិ | ៣៦,៤% | ៩០% | ៣៤,៥% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | ៦២,៦% | ១០០% | ៥៩,៩% | ↓ |
| ១០ | ចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស | ៣ | ៤ | ៣ | ↓ |
| ១១ | ចំនួនសិស្សក្នុងការអប់រំមធ្យមសិក្សាបច្ចេកទេស | ៦៥៣ | ១២៣៨ | ៨៦៨ | ↓ |
| | ចំនួនសិស្សក្នុងការអប់រំមធ្យមសិក្សាបច្ចេកទេស(ស្រី) | ២៣៨ | ៣៨៧ | ៣២៦ | ↓ |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្ភារៈបង្រៀននិងរៀន គ្រូឯកទេសតាមមុខវិជ្ជាមួយចំនួន ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ និងគ្រូបង្រៀនបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសមិនទាន់ឆ្លើយតបតាមតម្រូវការ
- កម្មវិធីទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សមធ្យមសិក្សា មិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ដូចជាកម្មវិធីអាហារូបករណ៍
- សាលារៀនអនុវត្តកម្មវិធីសាលាកុមារមេត្រីមធ្យមសិក្សានៅ មិនទាន់បានពង្រីកវិសាលភាព
- ការអប់រំបំណិនជីវិត ការតម្រង់ទិសវិជ្ជាជីវៈ និងការប្រឹក្សាអាជីពមិនទាន់បានពង្រីកវិសាលភាព
- លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅមានកម្រិតទាប
- ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅមានកម្រិតខ្ពស់ ជាពិសេសនៅថ្នាក់ទី៧
- វិធានការ និងជម្រើសសម្រាប់ផ្តល់ឱកាសដល់សិស្សប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីបន្តការសិក្សាមិនទាន់បានទូលំទូលាយ
- ការអនុវត្តកម្មវិធីសិក្សានៅមិនទាន់បានពេញលេញតាមការណែនាំរបស់ក្រសួង
- ការអនុវត្តអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុនដើម្បីទប់ស្កាត់សិស្សបោះបង់ការសិក្សានៅមិនទាន់ពង្រីកវិសាលភាពបាន
- នាយកសាលាមធ្យមសិក្សាមួយចំនួននៅមិនទាន់គោរពតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវ
- ចំនួនអធិការមធ្យមសិក្សាមិនទាន់ឆ្លើយតបនឹងតម្រូវការទាំងបរិមាណ និងគុណភាព។

## ២.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ការទទួលបានសេវាអប់រំប្រកបដោយសមធម៌

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១១០ កើន ៥ ធៀបនឹងឆ្នាំ២០១៣ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៤៣ និងឯកជន ៦៧ ដែលមានទីតាំងនៅតាមបណ្តារាជធានីខេត្ត១៩។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៤។ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន ៦៣ រដ្ឋ ៩ និងឯកជន ៥៤។គ្រឹះស្ថានឧត្តមសិក្សា ៣៨ បណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ។

តារាងទី១១ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

| ល.រ | ឈ្មោះក្រសួង ស្ថាប័ន | រដ្ឋ | ឯកជន | សរុប |
|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ៩ | ៥៤ | ៦៣ |
| ២ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ | ០ | ៣ |
| ៣ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ | ០ | ១ |
| ៤ | ក្រសួងសុខាភិបាល | ៣ | ០ | ៣ |
| ៥ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១២ | ១៣ | ២៥ |
| ៦ | ក្រសួងធម្មការ និងសាសនា | ៣ | ០ | ៣ |
| ៧ | ក្រសួងការពារជាតិ | ៥ | ០ | ៥ |
| ៨ | ក្រសួងមហាផ្ទៃ | ១ | ០ | ១ |
| ៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | ០ | ១ |
| ១០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | ០ | ១ |
| ១១ | ធនាគារជាតិនៃកម្ពុជា | ១ | ០ | ១ |
| ១២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១ | ០ | ១ |
| ១៣ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | ០ | ១ |
| ១៤ | ក្រសួងរ៉ែ និងថាមពល | ១ | ០ | ១ |
| | សរុប | ៤៣ | ៦៧ | ១១០ |

ឆ្នាំសិក្សា ២០១៣-២០១៤ គ្រូបង្រៀនឧត្តមសិក្សាមាន ១១ ៥៦៦ នាក់ ស្រី ១ ៦៦៧ នាក់ ស្មើនឹង ១៤,៤ ភាគរយ ក្នុងនោះគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ ៣ ៤០៩ នាក់ ស្រី ៦២០ នាក់ ស្មើនឹង ១៨,១៨ ភាគរយ គ្រូបង្រៀនកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ៧ ១៤០ នាក់ ស្រី ៩៣០ នាក់ ស្មើនឹង ១៣,០២ ភាគរយ និងគ្រូបង្រៀនកម្រិតបណ្ឌិត ៨៣៦ នាក់ ស្រី ៦៨ នាក់ ស្មើនឹង ៨,១៣ ភាគរយ។

### តារាងទី១២ ៖ ការប្រៀបធៀបបុគ្គលិកអប់រំនៅឧត្តមសិក្សា

| គ្រូបង្រៀន | ឆ្នាំសិក្សា២០១២-២០១៣ | | | | ឆ្នាំសិក្សា២០១៣-២០១៤ | | | |
|---|---|---|---|---|---|---|---|---|
| | បរិញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិត | សរុប | បរិញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិត | សរុប |
| គ្រូបង្រៀនជាតិ | ៣៤៧០ | ៦០៣២ | ៧០០ | ១០២០២ | ៣១៣៩ | ៦៦៣២ | ៧១៧ | ១០៤៨៨ |
| គ្រូបង្រៀនបរទេស | ២៥០ | ២៨៥ | ១០៥ | ៦៤០ | ២៧០ | ៤៨៥ | ១១៩ | ៨៧៤ |
| សរុប | ៣៧២០ | ៦៣១៧ | ៨០៥ | ១០៨៤២ | ៣៤០៩ | ៧១១៧ | ៨៣៦ | ១១៣៦២ |

និស្សិតថ្នាក់បរិញ្ញាបត្ររងមាន ១៥ ៦៣៥ នាក់ ស្រី ៧ ២៩៩ នាក់ ស្មើនឹង ៤៦,៧ ភាគរយ ក្នុងនោះ និស្សិតអាហារូបករណ៍ ១ ៦៣២ នាក់ ស្រី ៥៧១ នាក់ ស្មើនឹង ៣៤,៩ ភាគរយ។ ប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតថ្នាក់បរិញ្ញាបត្ររងថយ ៨ ០៧៦ នាក់ ស្រី ៣៤៥ នាក់ ស្មើនឹង ៤,៣ ភាគរយ។

រូបភាពទី១០ ៖ និស្សិតថ្នាក់បរិញ្ញាបត្ររង ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤




និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រមាន ២១៤ ២៦៦ នាក់ ស្រី ៩២ ៥៤៣ នាក់ ស្មើនឹង ៤៣,២ ភាគរយ។ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតថ្នាក់បរិញ្ញាបត្រថយ ១,៦ ភាគរយ ស្រីកើន ៦,៧ ភាគរយ។ និស្សិតអាហារូបករណ៍មាន ២៨ ៦៧៦ នាក់ ស្រី ១២ ៦៨៥ នាក់ ស្មើនឹង ៤៤,៥ ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតអាហារូបករណ៍ថយ ១ ភាគរយ ស្រីកើន ១៥,៣ ភាគរយ។ និស្សិតកំពុងសិក្សាឆ្នាំទី១ នៃថ្នាក់បរិញ្ញាបត្រមាន ៦១ ០០៩ នាក់ ស្រី ២៦ ០៩៦ នាក់ ស្មើនឹង ៤២,៧ ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក និស្សិតឆ្នាំទី១ ថយ ៩,៧ ភាគរយ ស្រីថយ ៩,៨ ភាគរយ។

## រូបភាពទី១១ ៖ និស្សិតថ្នាក់បរិញ្ញាបត្រ ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤




និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រមាន ១៩ ១៩១ នាក់ កើន ៨,២ ភាគរយ ស្រី ១៩,៩ ភាគរយ កើន ១២,៨ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៨ ០១០ នាក់ កើន ៨,១ ភាគរយ ស្រី ៣៧៧២ នាក់ ស្មើនឹង ២០,៩ ភាគរយ កើន ១២,៩ ភាគរយ និងថ្នាក់បណ្ឌិត ១ ១៨១ នាក់ កើន ៩,០ ភាគរយ ស្រី ៦០ នាក់ ស្មើនឹង ៥,០ ភាគរយ កើន ០,៤ ភាគរយ។ និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រចូលសិក្សាឆ្នាំដំបូងមាន ៥ ៩៧៤ នាក់ កើន ១៦,៥ ភាគរយ ស្រី ២៤,៧ ភាគរយ កើន ២៣,៤ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៥ ៨៤២ នាក់ កើន ១៤,៧ ភាគរយ ស្រី ២៥,១ ភាគរយ កើន ២២,៩ ភាគរយ និងថ្នាក់បណ្ឌិត ១៣២ នាក់ កើន ២៥៦,៧ ភាគរយ ស្រី ៨,៥ ភាគរយ កើន ១០០ ភាគរយ។

*ប្រការនេះបង្ហាញថា កម្ពុជាមានសុទិដ្ឋិនិយមក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាពខ្ពស់។*

## រូបភាពទី១២ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤



រូបភាពទី១៣ ៖ និស្សិតកំពុងសិក្សាថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤




ក្រសួងបាន៖

- ប្រឡងជ្រើសរើសនិស្សិត ៦៦២ នាក់ ស្រី ២៦,៦ ភាគរយ ទៅសិក្សានៅបរទេស និងទទួលចុះឈ្មោះនិស្សិតបញ្ចប់ការសិក្សាពីបរទេស ១៩២ នាក់ ស្រី ២១,៨ ភាគរយ
- បំប៉ននិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស និងនិស្សិតបរទេសមកសិក្សានៅកម្ពុជាស្តីពីវប្បធម៌ ប្រពៃណី និងការរស់នៅ ២៩៩ នាក់ ស្រី ២២,៤ ភាគរយ
- បញ្ជូននិស្សិតអាហារូបករណ៍ទៅសិក្សានៅវៀតណាម ១២០ នាក់ ស្រី ២០ ភាគរយ នៅឡាវ ១០ នាក់ ស្រី ១០ ភាគរយ នៅសាធារណរដ្ឋប្រជាមានិតចិន ១០៤ នាក់ ស្រី ២៩,៨ ភាគរយ និងនិស្សិតអាហារូបករណ៍ព្រះរាជទានម្ចាស់ក្សត្រីមហាចក្រីសិរិនធរ នៅថៃ ២១៩ នាក់ ស្រី ២៩,៦ ភាគរយ។

និស្សិតអាហារូបករណ៍បរទេសកំពុងសិក្សានៅកម្ពុជាមាន ១៦០ នាក់ ស្រី ២៨,១ ភាគរយ វៀតណាម ១១១ នាក់ ស្រី ២៩,៧ ភាគរយ ឡាវ ៤៣ នាក់ ស្រី ១៣,៩ ភាគរយ និងសាធារណរដ្ឋប្រជាមានិតចិន ៦ នាក់ ស្រី ១០០ ភាគរយ។ និស្សិតអាហារូបករណ៍បរទេសទើបមកដល់ថ្មីមាន ៣១ នាក់ ស្រី ៤៨,៣ ភាគរយ វៀតណាម ១៥ នាក់ ស្រី ៤០ ភាគរយ ឡាវ ១០ នាក់ ស្រី ៣០ ភាគរយ និងសាធារណរដ្ឋប្រជាមានិតចិន ៦ នាក់ ស្រី ១០០ ភាគរយ។

និស្សិតបរទេសរៀនបង់ថ្លៃសិក្សា ១៣ នាក់ ស្រី ៤៦,១ ភាគរយ សាធារណរដ្ឋកូរ៉េ ៦ នាក់ វៀតណាម ៤ នាក់ សាធារណរដ្ឋប្រជាមានិតចិន ២ នាក់ និងជប៉ុន ១ នាក់ និងសម្រួលឱ្យចូលរៀនទៅតាមមុខវិជ្ជាដែលបានស្នើសុំ។

និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ៥ ៦០២ នាក់ ស្រី ២ ២៦៤ នាក់ ស្មើនឹង ៤២ ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ ៦៤៨ នាក់ ស្រី ២៤២ នាក់ ស្មើនឹង ៣៣,១ ភាគរយ។ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមាន ៤៥ ៨៨៤ នាក់ ស្រី ១៩ ៧០៧ នាក់ ស្មើនឹង ៤២,៩ ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ ៦ ៦៧៩ នាក់ ស្រី ២ ៧២៤ នាក់ ស្មើនឹង ៤១,២ ភាគរយ។ និស្សិតថ្នាក់ក្រោយ

បរិញ្ញាបត្របញ្ចប់ការសិក្សាមាន ៤ ៥៤៩ នាក់ ស្រី ២៣ ភាគរយ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ ៤ ៥១៥ នាក់ ស្រី ១ ០៤៧ នាក់ ស្មើនឹង ២៣,២ ភាគរយ (និស្សិតដែលបានសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ១៣០ នាក់ ស្រី ១៨,៤ ភាគរយ) កើន ៣១,៦ ភាគរយ ស្រី ២៣,២ ភាគរយ និងថ្នាក់បណ្ឌិត ៣៤ នាក់ ស្រី ១ នាក់ ស្មើនឹង ២,៩ ភាគរយ កើន ១០០ ភាគរយ ស្រីថយ ៥០ ភាគរយ។

*ប្រការនេះបានបញ្ជាក់ឱ្យឃើញថា ចំនួននិស្សិតនារីនៅឧត្តមសិក្សាមានការកើនឡើងគួរឱ្យកត់សម្គាល់។*

រូបភាពទី១៤ ៖ និស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្ររង ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់២០១៣-២០១៤




រូបភាពទី១៥ ៖ និស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤



រូបភាពទី១៦ ៖ និស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីឆ្នាំសិក្សា ២០០២-២០០៣ ដល់ ២០១៣-២០១៤




រូបភាពទី១៧ ៖ និស្សិតបញ្ចប់ថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៣-២០១៤




រូបភាពទី១៨ ៖ និស្សិតកំពុងសិក្សា និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមវិស័យឆ្នាំសិក្សា ២០១៣-១៤






រូបភាពទី១៩ ៖ និស្សិតកំពុងសិក្សា និងបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតតាមវិស័យឆ្នាំសិក្សា២០១៣-១៤







## ក.២ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតប

ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សាសម្រេចបានតាមស្តង់ដារធានាគុណភាពផ្ទៃក្នុង ១៨,៩។

*ប្រការនេះបញ្ជាក់ថា គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនមិនទាន់បានឆ្លើយតបនឹងស្តង់ដារធានាគុណភាពផ្ទៃក្នុង។*

### *ការរៀបចំក្របខណ្ឌគោលនយោបាយឧត្តមសិក្សា*

ក្រសួងបាន៖

- ចេញគោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០ សំដៅធានាសមធម៌នៃការចូលរៀនរបស់និស្សិត ប្រសិទ្ធភាពភាពរលូននៃការសម្របសម្រួលការគ្រប់គ្រងនៅឧត្តមសិក្សា និងយន្តការចាំបាច់នានាដើម្បីគាំទ្រដល់ប្រព័ន្ធឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស
- បង្កើតក្រុមការងារពិនិត្យតាមដាន និងវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន
- ពិនិត្យស្ថានភាពបណ្តុះបណ្តាលផ្ទៃក្នុងគ្រឹះស្ថានឧត្តមសិក្សា ៥៩។

### *ការទទួលស្គាល់គុណភាពអប់រំនៅឧត្តមសិក្សា*

ក្រសួងបាន៖

- រៀបចំឯកសារស្តង់ដារជាតិស្តីពី ការទទួលស្គាល់គុណភាពអប់រំនៅឧត្តមសិក្សា និងផ្សព្វផ្សាយតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ៤ មានអ្នកចូលរួម ១៨៨ នាក់ស្រី ២៥ នាក់

- អនុញ្ញាតឱ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញអក្សរសាស្ត្រខ្មែរ បង្កើតដេប៉ាតឺម៉ង់ភាសាថៃ និងបង្កើតមហាវិទ្យាល័យអប់រំ
- ទទួលស្គាល់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ៣
- ទទួលស្គាល់សាលាកិច្ចការរដ្ឋាភិបាល និងទំនាក់ទំនងអន្តរជាតិ **តេជោសែន** និងការបណ្តុះបណ្តាលជំនាញថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៅសាកលវិទ្យាល័យកម្ពុជា
- ផ្សព្វផ្សាយឯកសារស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិ មានអ្នកចូលរួម ១៦០ នាក់ ស្រី ២៥ នាក់
- ត្រៀមលក្ខណៈបើកសាកលវិទ្យាល័យត្បូងឃ្មុំ
- បញ្ឈប់ការទទួលស្គាល់វិទ្យាស្ថានប៊ុណ្ណាកម្ពុជា
- ព្រាងគោលការណ៍លម្អិតស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ចុះពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការសិក្សារបស់និស្សិតអាហារូបករណ៍អាទិភាព និស្សិតអាហារូបករណ៍នៅអូស្ត្រាលី និងគុណភាពបណ្តុះបណ្តាលគ្រឹះស្ថានឧត្តមសិក្សា ១៤ ដែលគាំទ្រដោយគម្រោងលើកកម្ពស់គុណភាពនិងសមត្ថភាពឧត្តមសិក្សា។

រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យបង្កើតសាកលវិទ្យាល័យក្រចេះ តាមអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។

*ការលើកកម្ពស់សកម្មភាពស្រាវជ្រាវ*

ក្រសួងបាន៖

- ផ្តល់មូលនិធិសម្រាប់អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍ដល់គ្រឹះស្ថានឧត្តមសិក្សា ២៤ ក្នុងនោះមានអនុគម្រោង ៤៥។ អនុគម្រោងដែលបានបញ្ចប់រួចរាល់ ១៥ និង ៣០ បញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០១៥ គាំទ្រដោយគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា
- បំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ស្តីពីការរៀបចំផែនការសកម្មភាពស្រាវជ្រាវ មានអ្នកចូលរួម ១០៥ នាក់ ស្រី ១២ នាក់
- រៀបចំវេទិកាអ្នកស្រាវជ្រាវ ការបង្ហាញវិស័យអាទិភាពក្នុងការស្រាវជ្រាវ២០១៥-២០១៨ មានអ្នកចូលរួម ១០៥ នាក់ ស្រី ១៦ នាក់ និងវេទិកាស្រាវជ្រាវអប់រំកម្ពុជាលើកទី១ រៀបចំដោយសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្រោមកិច្ចសហការជាមួយអង្គការយូណេស្កូ មានអ្នកចូលរួមថ្នាក់ជាតិ និងអន្តរជាតិ ៤៩២ នាក់ ។

### *ការពង្រឹងយន្តការជ្រើសរើសនិស្សិត*

ក្រសួងបាន៖

- ជ្រើសរើសនិស្សិតអាហារូបករណ៍រដ្ឋតាមប្រព័ន្ធកុំព្យូទ័រឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ចំនួន ៣ ៣៦៤ នាក់ ស្រី ២ ០៤៣ នាក់ ស្មើនឹង ៦០,៧ ភាគរយ
- បញ្ជូនកូនសៀវភៅ និងសំណុំពាក្យសុំអាហារូបករណ៍ទៅដល់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីចែកជូនបន្តដល់សិស្សថ្នាក់ទី១២ នៅតាមវិទ្យាល័យទូទាំងប្រទេស
- ផ្សព្វផ្សាយណែនាំពីគោលការណ៍ នៃការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេសដល់សិស្ស និស្សិត មន្ត្រីរាជការ តំបន់ដាច់ស្រយាលជួបការលំបាក ១៥ ដង។

*ប្រការនេះបានឆ្លុះបញ្ចាំងពីទស្សនាទានរយៈពេលវែងសម្រាប់អភិវឌ្ឍឧត្តមសិក្សា។*

## **ក.៣ ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅគ្រប់កម្រិត**

### *ការលើកកម្ពស់អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា*

ក្រសួងបាន៖

- ប្រគល់សិទ្ធិចុះហត្ថលេខាលើសន្លឹកសញ្ញាបត្រការបញ្ជាក់វិញ្ញាបនបត្របណ្តោះអាសន្ននិងសន្លឹកសញ្ញាបត្រថតចម្លង និងការចេញសន្លឹកសញ្ញាបត្រលើកទី២ (ទុតិយតា) ជូនគ្រឹះស្ថានឧត្តមសិក្សា
- បង្កើតគណៈកម្មការពិនិត្យខ្លឹមសារ និងរូបភាពផ្សព្វផ្សាយពាណិជ្ជកម្មសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បោះពុម្ពកម្រងព័ត៌មានស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ (ព័ត៌មានទូទៅស្តីពីថ្នាក់ដឹកនាំគ្រឹះស្ថាន កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងតម្លៃសិក្សា)
- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានឧត្តមសិក្សាក្រៅប្រទេសដូចជា សាធារណរដ្ឋកូរ៉េ ថៃ សហរដ្ឋអាមេរិក សាធារណរដ្ឋប្រជាមានិតចិន បារាំង វៀតណាម។ល។ លើការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ កម្មវិធីសិក្សា ការស្រាវជ្រាវ និងការផ្លាស់ប្តូរបទពិសោធ
- ទទួលស្គាល់ក្រុមប្រឹក្សាភិបាលគ្រឹះស្ថានឧត្តមសិក្សាឯកជន ៤។

រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាភិបាលគ្រឹះស្ថានសាធារណៈ ២ ។

*ការអភិវឌ្ឍសមត្ថភាពមន្ត្រីឧត្តមសិក្សា*

ក្រសួងបាន៖

- បញ្ជូនមន្ត្រី ៣ នាក់ ទៅចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងការងារលទ្ធកម្ម
- បញ្ជូនមន្ត្រី ៤ នាក់ ស្រី ១ នាក់ ទៅចូលរួមសិក្ខាសាលាស្តីពីការវាយតម្លៃផលប៉ះពាល់តាមតំបន់នៅសាធារណរដ្ឋកូរ៉េ ដើម្បីត្រៀមវិភាគផលប៉ះពាល់នៃការសិក្សារបស់និស្សិតអាហារូបករណ៍អាទិភាពពិសេស
- បញ្ជូនមន្ត្រី ៥ នាក់ ស្រី ១ នាក់ ទៅចូលរួមទស្សនកិច្ចសិក្សានៅបង់ក្លាដែសស្តីពីការអនុវត្តការងារស្រាវជ្រាវការងារលទ្ធកម្ម និងការងារគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអនុវត្តអនុគម្រោងស្រាវជ្រាវតាមគ្រឹះស្ថានឧត្តមសិក្សា
- បញ្ជូនមន្ត្រីជំនាញ និងបុគ្គលិកគ្រឹះស្ថានឧត្តមសិក្សាឯកជន ២១ នាក់ ស្រី ៥ នាក់ ទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅអូស្ត្រាលី ក្នុងនោះ ១៩ នាក់ ស្រី ៦ នាក់ បានបញ្ចប់ការសិក្សាត្រឡប់មកវិញ
- បញ្ជូនមន្ត្រី ៥ នាក់ ទៅសិក្សាវគ្គបណ្តុះបណ្តាលជាន់ខ្ពស់អន្តរជាតិស្តីពីការធ្វើផែនការ និងគ្រប់គ្រងអប់រំនៅបារាំង
- រៀបចំសន្និសីទអន្តរជាតិលើកទី៣ ស្តីពីគណិតវិទ្យា និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំគណិតវិទ្យា រយៈពេល ៣ថ្ងៃ មានអ្នកចូលរួម ២៥០ នាក់ ស្រី ៦៧ នាក់
- ពិនិត្យ និងចេញសញ្ញាបត្រនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ២ ៣៨៧ នាក់ ស្រី ៤៥៥ នាក់ និងបណ្ឌិត ២៥ នាក់ ស្រី ១ នាក់
- បញ្ជូនមន្ត្រី ៤ នាក់ ចូលរួមសន្និសីទអន្តរជាតិស្តីពីការធានាគុណភាពអប់រំឧត្តមសិក្សានៅថៃ។

*ប្រការនេះបានជួយលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រង។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ឧត្តមសិក្សា | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|
| | | ២០១៣-១៤ | ២០១៤-១៥ | ២០១៣-១៤ | |
| ១ | ភាគរយនិស្សិតអាហារូបករណ៍រដ្ឋចូលរៀនឆ្នាំទី ១ | ៥% | 8% | ៩,៩% | ↑ |
| ២ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | ១៣% | 15% | ១២,៤% | → |
| ៣ | គ្រូបង្រៀនដែលមានគុណវុឌ្ឍិនៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់កើន ១០០០នាក់ និងបណ្ឌិត ២៥០នាក់ | | | | |
| | - បរិញ្ញាបត្រជាន់ខ្ពស់ក្នុងស្រុក | ៥០ | ៧០ | ៦០០ | ↑ |
| | - បណ្ឌិតក្នុងស្រុក | ២០ | ៣០ | ១៧ | ↓ |
| | - បរិញ្ញាបត្រជាន់ខ្ពស់នៅបរទេស | ៥០ | ៧០ | ២០០ | ↑ |
| | - បណ្ឌិតនៅបរទេស | ២០ | ២០ | ១៤ | ↓ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ភាគរយនិស្សិតបញ្ចប់ការសិក្សាក្នុងកម្មវិធីអាទិភាពអាស៊ាន | ៨៧% | ៨៨% | N/A | ↓ |
| ៥ | ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ | ៧០% | ៧២% | N/A | ↓ |
| ៦ | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សារៀបចំផែនការថវិកាប្រចាំឆ្នាំ | ១០% | ២០% | N/A | ↓ |
| ៧ | ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សាសម្រេចបានតាមស្តង់ដារធានាគុណភាពផ្ទៃក្នុង | ១០% | ២០% | ១៨,៩% | → |
| ៨ | ថវិកាសម្រាប់អនុវិស័យឧត្តមសិក្សា | ៤% | ៨% | N/A | ↓ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- គ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា មានចំនួនតិច
- ការបណ្តុះបណ្តាលថ្នាក់វិជ្ជាជីវៈ និងបច្ចេកទេសមធ្យម នៅមានចំនួនតិច
- គោលនយោបាយជាតិស្តីពីអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា នៅឧត្តមសិក្សា មិនទាន់បានរៀបចំ
- គ្រឹះស្ថានឧត្តមសិក្សាភាគច្រើនផ្តោតតែលើការបង្រៀនជាងការស្រាវជ្រាវ
- ធនធានគ្រូបង្រៀនឧត្តមសិក្សា និងមូលដ្ឋានសម្ភារៈនៅតាមគ្រឹះស្ថានឧត្តមសិក្សាមិនទាន់សមាមាត្រទៅនឹងចំនួននិស្សិត។

## ២.២. ៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

### ក. លទ្ធផលសម្រេចបាន

### ក.១ ការទទួលបានសេវាអប់រំប្រកបដោយសមធម៌

ក្រសួងបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធនៅតាមរាជធានី ខេត្តមានកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ២៥ កម្មវិធី ក្រោយអក្ខរកម្ម ២៣ កម្មវិធីចូលរៀនឡើងវិញ ២៣ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ ២៥ កម្មវិធីសមមូលបឋមសិក្សា ១៨ និងបំពេញវិជ្ជា ២២ ។

*កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*

អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចនៅកម្ពុជារបស់ក្រសួងផែនការបង្ហាញថា អត្រាអក្ខរកម្មជនយុវជន (អាយុ ១៥-២៤ឆ្នាំ) បានកើនពី ៩២,១ ភាគរយ ស្រី ៩១,៣ ភាគរយ នៅឆ្នាំ២០១២ ដល់ ៩៣ ភាគរយ ស្រី ៩២,៨ ភាគរយ នៅឆ្នាំ ២០១៣។ ចំពោះអត្រាអក្ខរកម្មជនពេញវ័យ (អាយុ១៥-៤៥ឆ្នាំ) កើនពី ៧៧,៦ ភាគរយ នៅឆ្នាំ២០០៨ ដល់ ៨០ ភាគរយ នៅឆ្នាំ២០១៣។

រូបភាពទី២០ ៖ ភាគរយអ្នកសិក្សាកម្មវិធីអក្ខរកម្មវិជ្ជាជីវៈតាមក្រុមអាយុ ឆ្នាំ២០១៤




រូបភាពទី២០ បង្ហាញថា ក្រុមអាយុ ២៥-៤៥ឆ្នាំ បានចូលរៀនក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈរហូតដល់ ៥១,៥ ភាគរយ ច្រើនជាងក្រុមអាយុផ្សេងទៀត។ ដោយឡែកក្រុមអាយុ ៤៥ឆ្នាំឡើងមានតែ ៥ ភាគរយ ប៉ុណ្ណោះ ដោយសារក្រុមនេះ ជាក្រុមពលកម្មសកម្មគ្មានឱកាសចូលរៀនតាមកម្មវិធីអប់រំក្នុងប្រព័ន្ធ។

ថ្នាក់អក្ខរកម្មវិជ្ជាជីវៈមាន ១ ១៩០ ថយ ៨៧ ស្មើនឹង ៦,៨ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ ថ្នាក់អក្ខរកម្មវិជ្ជាជីវៈគ្រប់គ្រងដោយក្រសួង ១ ១០៨ ថយ ៨០ ស្មើនឹង ៦,៧ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍមាន ៨២ ថយ ៧ ស្មើនឹង ៧,៩ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

គ្រូអក្ខរកម្មវិជ្ជាជីវៈមាន ១ ២១១ នាក់ ស្រី ៤៨៣ នាក់ ស្មើនឹង ៣៩,៩ ភាគរយ ថយ ១០១ នាក់ ស្មើនឹង ៧,៧ ភាគរយ ស្រី ៤ នាក់ ស្មើនឹង ០,៨ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ គ្រូអក្ខរកម្មវិជ្ជាជីវៈគ្រប់គ្រង

ដោយក្រសួង ១ ១០៨ នាក់ ស្រី ៩២៥ នាក់ ស្មើនឹង ៨៣,៣ ភាគរយ ថយ ៨០នាក់ ស្មើនឹង ៦,៧ ភាគរយ ស្រី ២៩ នាក់ ស្មើនឹង ៦,៣ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍមាន ១០៣ នាក់ ស្រី ៥៨ នាក់ ស្មើនឹង ៥៦,៣ ភាគរយ ថយ ២១ នាក់ ស្មើនឹង ១៦,៩ ភាគរយ ស្រីកើន ២៥ នាក់ ស្មើនឹង ៧៥,៧ ភាគរយ។

អ្នករៀនអក្ខរកម្មវិជ្ជាជីវៈមាន ២៦ ៦០១ នាក់ ស្រី ១៨ ០១១ នាក់ ស្មើនឹង ៦៧,៧ ភាគរយ ថយ ២ ៨៥៥ នាក់ ស្មើនឹង ៩,៦ ភាគរយ ស្រី ១ ៦២០ នាក់ ស្មើនឹង ៨,២ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ អ្នករៀន ២៤ ៧៩៣ នាក់ ស្រី ១៦ ៨៥៩ នាក់ ស្មើនឹង ៦៧,៩ ភាគរយ ថយ ២ ៦៨២ នាក់ ស្មើនឹង ៩,៧ ភាគរយ ស្រី ១ ៨២៦ នាក់ ស្មើនឹង ៩,៧ ភាគរយ គាំទ្រថវិកាកម្មវិធី និងគាំទ្រថវិកាដោយដៃគូអភិវឌ្ឍមាន ១ ៨០៨ នាក់ ស្រី ១ ១៥២ នាក់ ស្មើនឹង ៦៣,៧ ភាគរយ ថយ ១៧៣ នាក់ ស្មើនឹង ៨,៧ ភាគរយ ស្រីកើន ២០៦ នាក់ ស្មើនឹង ២១,៧ ភាគរយ។

ទោះបីមានការរីកចម្រើនគួរឱ្យកត់សម្គាល់ខាងលើយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាសេសសល់មួយចំនួនដូចជា៖

- ការអនុវត្តកម្មវិធី និងការផ្តល់ទិន្នន័យព័ត៌មានអក្ខរកម្មវិជ្ជាជីវៈរបស់ដៃគូអភិវឌ្ឍនៅមានកម្រិត
- សម្ភារៈសម្រាប់ទ្រទ្រង់ថ្នាក់អក្ខរកម្មវិជ្ជាជីវៈមានការខ្វះខាត និងពុំទាន់ពេលវេលា
- ការចូលរួមសហការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈរបស់អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធមិនទាន់បានទូលំទូលាយ
- សមត្ថភាពក្នុងការរៀបចំផែនការអនុវត្ត និងពិនិត្យតាមដានសកម្មភាពអក្ខរកម្មអប់រំក្រៅប្រព័ន្ធនៅមានកម្រិតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## *កម្មវិធីក្រោយអក្ខរកម្ម*

នៅទូទាំងប្រទេសមានបណ្ណាល័យ ៣២ គាំទ្រដោយដៃគូអភិវឌ្ឍ ១ និងមណ្ឌលអាន ២០៤ ក្នុងនោះបណ្ណាល័យ ៣១ និងមណ្ឌលអាន ១៨៧ ដំណើរការ និងអ្នកចូលអាន ១១៦ ៩៥៧ នាក់ ស្រី ៥២,៦ ភាគរយ កើន ១,៣ ភាគរយ។

តារាងទី១៣ ៖ ស្ថិតិបណ្ណាល័យ មណ្ឌលអាន និងអ្នកចូលអាន

| បរិយាយ | | ២០១២-២០១៣ | | ២០១៣-២០១៤ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| បណ្ណាល័យ | អយក | ៣១ | | ៣១ | | 0 | |
| | ដៃគូ | ៨ | | ១ | | -៧ | |
| មណ្ឌលអាន | អយក | ១៩៣ | | ១៧៤ | | -១៩ | |
| | ដៃគូ | ១០១ | | ៣០ | | -៧១ | |
| អ្នកចូលអាន | អយក | ២៣៣៨៦ | ១៣២២៨ | ២២២០១ | ១២៧០៨ | -១១៨៥ | -៥២០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បណ្ណាល័យ | ដៃគូ | ៧៦២៧ | ៧២០០ | ៩៥១៤ | ៩៦៩២ | +១៧៨៧ | -២៥០៨ |
| អ្នកចូលអាន មណ្ឌលអាន | អយក | ៥៧០៨៥ | ៣២៥៨៣ | ៧៦២៨២ | ៣៩០៩៨ | +១៩១៩៧ | +៦៥១៥ |
| | ដៃគូ | ២៦៨៤០ | ១៥០៥៥ | ៨៥៦០ | ៤៨១៤ | -១៨២៨០ | -១០២៤១ |
| បណ្ណាល័យសរុប | | ៣៩ | | ៣២ | | -៧ | |
| មណ្ឌលអានសរុប | | ២៩៤ | | ២០៤ | | -៩០ | |
| អ្នកចូលអានសរុប | | ១១៤៩៣៨ | ៦៨០៦៦ | ១១៦៤៥៧ | ៦១៣១២ | +១៥១៩ | -៦៧៥៤ |

បណ្ណាល័យអប់រំក្រៅប្រព័ន្ធមាន ៣២ ថយ ៧ ស្មើនឹង ១៧,៩ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ មណ្ឌលអានមាន ២០៤ ថយ ៩០ ស្មើនឹង ៣០,៦ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

អ្នកចូលអានមាន ១១៦ ៤៥៧ នាក់ ស្រី ៦១ ៣១២ នាក់ ស្មើនឹង ៥២,៦ ភាគរយ កើន ១ ៥១៩ នាក់ ស្មើនឹង ១,៣ ភាគរយ ស្រីថយ ៦ ៧៥៤ នាក់ ស្មើនឹង ៩,៩ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍមានមណ្ឌលអាន ៣០ ស្មើនឹង ១៧,៧ ភាគរយ មានអ្នកចូលអាន ១៧ ៩៧៤ នាក់ ស្មើនឹង ១៥,៤ ភាគរយ។

បណ្ណាល័យ និងមណ្ឌលអានមួយចំនួនពុំទាន់មានភាពទាក់ទាញទាំងបរិស្ថាន ទាំងឯកសារ ហើយខ្លះទៀតខ្វះអ្នកគ្រប់គ្រង។ ក្រសួងកំពុងសិក្សាទីតាំងសម្រាប់សាងសង់បណ្ណាល័យ និងមណ្ឌលអានឱ្យមានលក្ខណៈសមស្រប និងធានានិរន្តរភាព។

### *កម្មវិធីចូលរៀនឡើងវិញ*

គ្រូបំប៉នកម្មវិធីចូលរៀនឡើងវិញ ១ ០៥៩ នាក់ ស្រី ៣១,២ ភាគរយ បានដំណើរការថ្នាក់ចូលរៀនឡើងវិញ ១០០ ភាគរយ។

ឆ្នាំសិក្សា ២០១៣-២០១៤ សិស្សបោះបង់ការសិក្សាថ្នាក់ទី៣ ដល់ទី៦ ចំនួន ១២៩ ៥៩៩ នាក់ ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបាននូវការអប់រំមូលដ្ឋានរបស់វិស័យអប់រំ។

តារាងទី១៤ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្សកម្មវិធីចូលរៀនឡើងវិញ

| បរិយាយ | | ២០១២-២០១៣ | | ២០១៣-២០១៤ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អយក | ១០០៩ | | ១០៤៦ | | +៣៧ | |
| | ដៃគូ | 0 | | ១៣ | | +១៣ | |
| គ្រូថ្នាក់បំប៉ន | អយក | ១០០៩ | ៣០៤ | ១០៤៦ | ៣២៩ | +៣៧ | +២៥ |
| | ដៃគូ | 0 | 0 | ១៣ | ២ | +១៣ | +២ |
| សិស្ស | អយក | ១៧៣៩៧ | ៧៩៨៧ | ១៧៦២៥ | ៨២០១ | +២២៨ | +២១៤ |
| | ដៃគូ | 0 | 0 | ៣១៣ | ១៥១ | +៣១៣ | +១៥១ |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្នាក់សរុប | ១០០៩ | | ១០៥៩ | | +៥០ | |
| គ្រូថ្នាក់បំប៉នសរុប | ១០០៩ | ៣០៤ | ១០៥៩ | ៣៣១ | +៥០ | +២៧ |
| សិស្សសរុប | ១៧៣៩៧ | ៧៩៨៧ | ១៧៩២៨ | ៨៣៥២ | +៥៤១ | +៣៦៥ |

ថ្នាក់បំប៉នមាន ១ ០៥៩ កើន ៥០ ស្មើនឹង ៤,៩ ភាគរយ។ ថ្នាក់បំប៉នដែលគ្រប់គ្រងដោយក្រសួងមាន ១ ០៤៦ កើន ៣៧ ស្មើនឹង ៣,៦ ភាគរយ។ ថ្នាក់បំប៉នគាំទ្រដោយដៃគូអភិវឌ្ឍមាន ១៣ កើន ១៣ ស្មើនឹង ១០០ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

គ្រូកម្មវិធីចូលរៀនឡើងវិញគ្រប់គ្រងដោយក្រសួងមាន ១ ០៤៦ នាក់ ស្រី ៣២៩ នាក់ ស្មើនឹង ៣១,៤ ភាគរយ កើន ៣៧ នាក់ ស្មើនឹង ៣,៦ ភាគរយ ស្រីកើន ២៥ នាក់ ស្មើនឹង ២,៤ ភាគរយ។ គ្រូថ្នាក់បំប៉នគាំទ្រដោយដៃគូអភិវឌ្ឍមាន ១៣ នាក់ ស្រី ២ នាក់ ស្មើនឹង ១៥,៣ ភាគរយ កើន ១៣ នាក់ ស្មើនឹង ១០០ ភាគរយ ស្រីកើន ២ នាក់ ស្មើនឹង ១០០ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

សិស្សបំប៉នមាន ១៧ ៩៣៨ នាក់ ស្រី ៨ ៣៥២ នាក់ ស្មើនឹង ៤៦,៥ ភាគរយ កើន ៥៤១ នាក់ ស្មើនឹង ៣,១ ភាគរយ ស្រីកើន ៣៦៥ នាក់ ស្មើនឹង ៤,៥ ភាគរយ។ សិស្សកម្មវិធីចូលរៀនឡើងវិញគ្រប់គ្រងដោយក្រសួងមាន ១៧ ៦២៥ នាក់ ស្រី ៨ ២០១ នាក់ ស្មើនឹង ៤៦,៥ ភាគរយ កើន ២២៨ នាក់ ស្មើនឹង ១,៣ ភាគរយ ស្រីកើន ២១៤ ស្មើនឹង ២,៦ ភាគរយ។ សិស្សកម្មវិធីចូលរៀនឡើងវិញគាំទ្រដោយដៃគូអភិវឌ្ឍមាន ៣១៣ នាក់ ស្រី ១៥១ នាក់ កើន ១០០ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ អង្គការវឌ្ឍនៈបានអនុវត្តកម្មវិធីចូលរៀនឡើងវិញនៅខេត្តពោធិ៍សាត់។

*ស្ថានភាព និងជីវភាពរស់នៅរបស់ក្រុមមុខសញ្ញា និងសិស្សបោះបង់ការសិក្សាជួបការលំបាក។*

## *កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍*

មជ្ឈមណ្ឌលសិក្សាសហគមន៍មាន ៣៤៧ ថយ ១ ជារបស់ដៃគូអភិវឌ្ឍ។ ក្នុងចំណោមមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់មានតែ ៣៣៧ ដែលបានដំណើរការ។ ថ្នាក់ជំនាញមាន ៦៧១ គ្រូជំនាញមាន ៦៧៥ នាក់ ស្រី ៥២,២ ភាគរយ។ អ្នករៀនមាន ៩ ៩១៦ នាក់ ស្រី ៦៣,១ ភាគរយ និងបានបញ្ចប់ ៨ ៥២៤ នាក់ ស្មើនឹង ៨៥,៩ ភាគរយ ស្រី ៦៣,១ ភាគរយ ថយ ៨,៩ ភាគរយ។

ឆ្នាំ២០១៤ មជ្ឈមណ្ឌលសិក្សាសហគមន៍គ្រប់គ្រងដោយក្រសួងបានដំណើរការថ្នាក់ជំនាញ ៦៣០ លើជំនាញ ៣៥ ក្នុងនោះសិស្សរៀនកាត់ដេរមាន ៣ ៤៣១ នាក់ ស្មើនឹង ៣៨,៩៨ ភាគរយ ស្រី ៣ ២៤៤ នាក់ ស្មើនឹង ៩៤,៥ ភាគរយ រីឯសិស្សរៀនថែឃុំមាន ៦ នាក់ ស្មើនឹង ០,១ ភាគរយ។

ដោយឡែកមជ្ឈមណ្ឌលសិក្សាសហគមន៍គាំទ្រដោយដៃគូអភិវឌ្ឍនានា បានដំណើរការថ្នាក់ជំនាញ ៤១ លើជំនាញ ១៦ ក្នុងនោះសិស្សចូលរៀនជំនាញកែច្នៃម្ហូបអាហាររហូតដល់ ១៨០ នាក់ ស្មើនឹង ១៦,១

ភាគរយ ស្រី ៨៣ នាក់ ស្មើនឹង ២៣,៨ ភាគរយ រីឯសិស្សចូលរៀតម្បាញមានតែ ១០នាក់ ស្មើនឹង ០,៩ ភាគរយ ប៉ុណ្ណោះ។

ជំនាញកាត់ដេរមានភាគរយខ្ពស់នេះ អាចមកពីភាគច្រើននៃមជ្ឈមណ្ឌលសិក្សាសហគមន៍បាន បំពាក់ម៉ាស៊ីនកាត់ដេរ ដែលបង្កលក្ខណៈងាយស្រួលក្នុងការរកគ្រូសហគមន៍។ មុខសញ្ញាភាគច្រើន លើសលប់ជាស្រ្តី ដែលមានបំណងទៅបម្រើការងារតាមរោងចក្រកាត់ដេរ។

**តារាងទី១៥ ៖ ស្ថិតិថ្នាក់ គ្រូជំនាញ អ្នករៀនជំនាញមុខរបរ និងមជ្ឈមណ្ឌលសិក្សាសហគមន៍**

| បរិយាយ | | ២០១២-២០១៣ | | ២០១៣-២០១៤ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ម.ស.ស | អយក | ៣២៤ | | ៣២៤ | | 0 | |
| | ដៃគូ | ២៤ | | ២៣ | | -១ | |
| ថ្នាក់ជំនាញមុខរបរ | អយក | ៥៩៥ | | ៦៣០ | | +៣៥ | |
| | ដៃគូ | ៨៧ | | ៨១ | | -៦ | |
| គ្រូជំនាញមុខរបរ | អយក | ៦០៧ | ២៨៤ | ៦៣៤ | ៣៣៧ | +២៧ | +៥៣ |
| | ដៃគូ | ៥៣ | ១៧ | ៨១ | ១៦ | -១២ | -១ |
| អ្នករៀនជំនាញ | អយក | ៩០១៩ | ៥៤៨០ | ៨៨០២ | ៥៦២៦ | -២១៧ | +១៤៦ |
| | ដៃគូ | ១៨៧៤ | ៨៦៦ | ១១១៤ | ៦៤០ | -៧៦០ | -២២៦ |
| ម.ស.សសរុប | | ៣៤៨ | | ៣៤៧ | | -១ | |
| ថ្នាក់ជំនាញសរុប | | ៦៨២ | | ៦៧១ | | +២៩ | |
| គ្រូជំនាញសរុប | | ៦៦០ | ៣០១ | ៦៧៥ | ៣៥៣ | +១៥ | +៥២ |
| អ្នករៀនជំនាញសរុប | | ១០៨៩៣ | ៦៣៤៦ | ៩៩១៦ | ៦២៦៦ | -៩៧៧ | -៨០ |

ក្នុងដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍បញ្ហាមួយចំនួននៅជួបការលំបាក ដូចជាខ្វះគ្រូជំនាញ តាមតម្រូវការរបស់សហគមន៍ ថវិកាឧបត្ថម្ភគ្រូមុខជំនាញតិច និងពុំមានថវិកាឧបត្ថម្ភសម្រាប់គណៈ គ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។ ការពង្រីកមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវបានផ្អាកជា បណ្ដោះអាសន្ន ដោយក្រសួងកំពុងសិក្សាទីតាំងសម្រាប់សាងសង់។ ស្ថានភាព និងជីវភាពរស់នៅរបស់ អ្នករៀនជួបការលំបាក និងមួយចំនួនចូលធ្វើការរោងចក្រ ហើយមួយចំនួនទៀតធ្វើចំណាកស្រុក។

## *កម្មវិធីសមមូល-បំពេញវិជ្ជា*

### *កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ*

សិស្សចូលរៀនមាន ៤ ១៤៦នាក់ ស្រី ២ ០១២ នាក់ ស្មើនឹង ៤៨,៥ ភាគរយ កើន ៣ ៣៨៧ នាក់ ស្មើនឹង ៤៤៦,២ ភាគរយ ស្រី ២ ០១២ នាក់ កើន ១ ៥៩១ នាក់។ សិស្សដែលគ្រប់គ្រងដោយក្រសួងមាន

២ ៨១៥ នាក់ កើន ២ ៨១៥ នាក់ ស្មើនឹង ១០០ ភាគរយ ស្រី ១ ៣៩៧ នាក់ កើន ១ ៣៩៧ នាក់ ស្មើនឹង ១០០ ភាគរយ។ សិស្សចូលរៀនគាំទ្រដោយដៃគូអភិវឌ្ឍ ១ ៣៣១ នាក់ កើន ៥៧២ នាក់ ស្មើនឹង ៧៥,៣ ភាគរយ ស្រី ៦១៥ នាក់ កើន ១៩៤ នាក់ ស្មើនឹង ៤៦ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

តារាងទី១៦ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្ស/អ្នករៀនកម្មវិធីសមមូលបឋមសិក្សា

| បរិយាយ | | ២០១២-២០១៣ | | ២០១៣-២០១៤ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អយក | 0 | | ១៤១ | | +១៤១ | |
| | ដៃគូ | ១៥ | | ៣៧ | | +២២ | |
| គ្រូ | អយក | 0 | 0 | ១៤១ | ៣២ | +១៤១ | +៣២ |
| | ដៃគូ | ១៥ | ៣ | ៣៧ | ១៥ | +២២ | +១២ |
| សិស្ស | អយក | 0 | 0 | ២៨១៥ | ១៣៩៧ | +២៨១៥ | +១៣៩៧ |
| | ដៃគូ | ៧៥៩ | ៤២១ | ១៣៣១ | ៦១៥ | +៥៧២ | +១៩៤ |
| ថ្នាក់សរុប | | ១៥ | | ១៧៨ | | ១៦៣ | |
| គ្រូសរុប | | ១៥ | ៣ | ១៧៨ | ៤៧ | +១៦៣ | +៤៤ |
| សិស្សសរុប | | ៧៥៩ | ៤២១ | ៤១៤៦ | ២០១២ | +៣៣៨៧ | +១៥៩១ |

ឆ្នាំ២០១៤ ក្រសួងបានដាក់ឱ្យអនុវត្តកម្មវិធីសមមូលបឋមសិក្សា ១៩ រាជធានី ខេត្ត។ បញ្ហាប្រឈមមួយចំនួន ដូចជាការផ្សព្វផ្សាយពីសារប្រយោជន៍នៃកម្មវិធីសមមូលបឋមសិក្សា សម្រាប់អ្នកពាក់ព័ន្ធពុំទាន់បានទូលំទូលាយ ស្ថានភាព និងជីវភាពរបស់ក្រុមមុខសញ្ញាជួបការលំបាក។ ថវិកាឧបត្ថម្ភគ្រូបង្រៀនកម្មវិធីសមមូលនៅមានកម្រិត ការជ្រើសរើស និងបណ្តុះបណ្តាលគ្រូនៅតំបន់ជួបការលំបាក។

## *មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា*

ថ្នាក់កម្មវិធីមធ្យមសិក្សាបឋមភូមិបំពេញវិជ្ជាមាន ២៦ ថយ ១១ ស្មើនឹង ២៩,៧ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ សិស្សចូលរៀនមាន ៧៨០ នាក់ ស្រី ១៦០ នាក់ ស្មើនឹង ២០,៥ ភាគរយ ថយ ៤៨៦ នាក់ ស្មើនឹង ៣៨,៣ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

## *មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា*

ថ្នាក់កម្មវិធីមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជាមាន ១៦២ កើន ១៩ ស្មើនឹង ១៣,២ ភាគរយធៀបនឹងឆ្នាំ២០១៣។ សិស្សចូលរៀន ៧ ២២១ នាក់ ស្រី ២ ៣៣៨ នាក់ ស្មើនឹង ៣២,៣ ភាគរយ ថយ ៣ ៧៤៩ នាក់ ស្មើនឹង ៣៤,១ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

តារាងទី១៧ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្សមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិបំពេញវិជ្ជា

| បរិយាយ | មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា | | | | | | មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១២-១៣ | | ២០១៣-១៤ | | កើន ឬ ថយ | | ២០១២-១៣ | | ២០១៣-១៤ | | កើន ឬថយ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | ៣៧ | | ២៦ | | -១១ | | ១៤៣ | | ១៦២ | | +១៩ | |
| គ្រូ | ប្រើប្រាស់គ្រូអប់រំក្នុងប្រព័ន្ធ | | | | | | | | | | | |
| សិស្ស | 1266 | 210 | 780 | 160 | -486 | -50 | 10970 | 3796 | 7221 | 2338 | | |

### *កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈសាលារៀនចល័ត*

កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈរថយន្តចល័តអនុវត្តបាន ១០ លើក ថយ ៣ លើក ស្មើនឹង ២៣ ភាគរយ មានអ្នកចូលរួម ១ ៤៣៦ នាក់ ស្រី ៩២៥ នាក់ ស្មើនឹង ៦៤,៤ ភាគរយ ថយ ៤២៣ នាក់ ស្មើនឹង ២២,៧ ភាគរយ ស្រី ៩២៥ នាក់ ថយ ៣៩៥ នាក់ ស្មើនឹង ២៩,៩ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ សម្ភារៈសម្រាប់ដំណើរការកម្មវិធីកែលម្អគុណភាពនៃជីវិតមានចំនួនតិច មិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

## ក.២ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតប

### *កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*

គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ១ ២១១ នាក់ ស្រី ៤៨៣ នាក់ ស្មើនឹង ៣៩,៩ ភាគរយ។

រូបភាពទី២១ ៖ លទ្ធផលបញ្ចប់ថ្នាក់អក្ខរកម្មវិជ្ជាជីវៈរយៈពេល ៥ឆ្នាំ




អ្នករៀនបានបញ្ចប់ថ្នាក់អក្ខរកម្មវិជ្ជាជីវៈមាន ២២ ០៣៩ នាក់ ស្រី ១៥ ១៧៦ នាក់ ស្មើនឹង ៦៨,៨ ភាគរយ ថយ ១ ២៣៨ នាក់ ស្មើនឹង ៥,៣ ភាគរយ ស្រី ១៥ ១៧៦ នាក់ ថយ ៦ ៨៦៣ នាក់ ស្មើនឹង ៤៣,១ ភាគរយ ធៀបនឹងឆ្នាំ២០១៣។ អ្នករៀនមួយចំនួនមករៀនមិនទៀងទាត់។

## កម្មវិធីក្រោយអក្ខរកម្ម

រូបភាពទី២២ ៖ ការប្រើប្រាស់បណ្ណាល័យ មណ្ឌលអានក្នុងកម្មវិធីក្រោយអក្ខរកម្ម




ឆ្នាំ២០១៤ បណ្ណាល័យមាន ៣១ កន្លែង ស្មើនឹង ៩៦,៨ ភាគរយ បានដំណើរការ និង ១ កន្លែង ស្មើនឹង ៣,១ ភាគរយ មិនដំណើរការ។ មណ្ឌលអានមាន ១៨៧ ស្មើនឹង ៩១,៦ ភាគរយ បានដំណើរការ និង ១៧ កន្លែង ស្មើនឹង ៨,៣ ភាគរយ មិនដំណើរការ។

## កម្មវិធីចូលរៀនឡើងវិញ

ឆ្នាំ ២០១៤ ចំនួនសិស្សបញ្ជូនមាន ១៥ ៤៦៣ នាក់ ស្រី ៧ ២៧១ នាក់ ស្មើនឹង ៤៧ ភាគរយ កើន ៤១១ នាក់ ស្មើនឹង ២,៧ ភាគរយធៀបនឹងឆ្នាំ២០១៣។

រូបភាពទី២៣ ៖ លទ្ធផលកម្មវិធីចូលរៀនឡើងវិញ




## កម្មវិធីបង្កើនប្រាក់ចំណូល

ឆ្នាំ២០១៤ គ្រូបង្រៀនជំនាញមុខរបរមាន ៦៧៥ នាក់ ស្រី ៣៥៣ នាក់ ស្មើនឹង ៥២,៣ ភាគរយ មានកម្រិតវប្បធម៌ចាប់ពីកម្រិតបឋមសិក្សារហូតដល់បរិញ្ញាបត្រជាន់ខ្ពស់។ ជារួមគ្រូបង្រៀន ២០ ភាគរយ

មានកម្រិតវប្បធម៌ត្រឹមបឋមសិក្សា ៥២,៣ ភាគរយ កម្រិតមធ្យមសិក្សាបឋមភូមិ ២៣,៥ ភាគរយ កម្រិតមធ្យមសិក្សាទុតិយភូមិ ៣,៨ ភាគរយ កម្រិតបរិញ្ញាបត្រ និង ០,៣ ភាគរយ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់។

*រូបភាពទី២៤ ៖ លទ្ធផលកម្មវិធីបង្កើនប្រាក់ចំណូល និងមជ្ឈមណ្ឌលសិក្សាសហគមន៍*




## *កម្មវិធីសមមូល-បំពេញវិជ្ជា*

### *កម្មវិធីសមមូល*

ឆ្នាំ ២០១៤ សិស្សបានបញ្ចប់កម្មវិធីសមមូលបឋមសិក្សាមាន ៣៧០ នាក់ ស្រី ១៨២ នាក់ ស្មើនឹង ៤៩,១ ភាគរយ ថយ ៣៨៩ នាក់ ស្មើនឹង ៥១,២ ភាគរយ ធៀបនឹងឆ្នាំ២០១៣។

*រូបភាពទី២៥ ៖ លទ្ធផលកម្មវិធីសមមូលបឋមសិក្សា*




### *មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា*

បេក្ខជនបំពេញវិជ្ជា និងស្វែរិនមកប្រឡង ៨១៤ នាក់ ស្រី ២១,២ ភាគរយ។ បេក្ខជនបំពេញវិជ្ជា និងស្វែរិនប្រឡងជាប់ ៥១៤ នាក់ ស្មើនឹង ៦៣,១ ភាគរយ ស្រី ២៣,១ ភាគរយ ថយ ៣៧,៥ ភាគរយ។

*មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា*

បេក្ខជនបំពេញវិជ្ជា និងស្វៃរិនបំពេញវិជ្ជាមកប្រឡង ៨ ៩១៨ នាក់ ស្រី ២ ៧២៩ នាក់ បេក្ខជនប្រឡងជាប់ ២ ០០២ នាក់ ស្មើនឹង ២៣,៨ ភាគរយ ស្រី ៨១៦ នាក់ ៨យ ៧៥,៦ ភាគរយ។

## គ.៣ ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅគ្រប់កម្រិត

ដើម្បីជំរុញការអនុវត្តអនុវិស័យអប់រំក្រៅប្រព័ន្ធនៅទូទាំងប្រទេស ឱ្យមានភាពរលូនប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្រសួងបានបំប៉នសមត្ថភាពមន្ត្រីដឹកនាំ និងគ្រប់គ្រងការងារអប់រំក្រៅប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២ ៧៣១ នាក់ ស្រី ៤៣៦ នាក់ ស្មើនឹង ១៥,៩ ភាគរយ រួមមាន៖

- វគ្គបំប៉នសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៤៩៨ នាក់ ស្រី ១០៩ នាក់ ស្មើនឹង ២២ ភាគរយ
- វគ្គបំប៉នកម្មវិធីអក្ខរកម្មវិជ្ជាជីវៈថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៧៨៥ នាក់ ស្រី ១០៧ នាក់ ស្មើនឹង ១៣,៦ ភាគរយ
- វគ្គបំប៉នកម្មវិធីចូលរៀនឡើងវិញថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ១១០ នាក់ ស្រី ២១ នាក់ ស្មើនឹង ១៩ ភាគរយ
- វគ្គបំប៉នកម្មវិធីសមមូលបឋមសិក្សាថ្នាក់ក្រោមជាតិ និងគ្រូកម្មវិធីសមមូល មានអ្នកចូលរួម ៣០៦ នាក់ ស្រី ៥៧ នាក់ ស្មើនឹង ១៨,៦ ភាគរយ
- វគ្គបំប៉នវិធីសាស្ត្រប្រមូលទិន្នន័យព័ត៌មានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៤៦៣ នាក់ ស្រី ៦៥ នាក់ ស្មើនឹង ១៤ ភាគរយ
- វគ្គបំប៉នគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៣៨៦ នាក់ ស្រី ៤១ នាក់ ស្មើនឹង ១០,៦ ភាគរយ
- វគ្គបំប៉នការផលិតព័ត៌មានសម្រាប់ផ្សព្វផ្សាយថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៩៣ នាក់ ស្រី ១៥ នាក់ ស្មើនឹង ១៦,១ ភាគរយ
- វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារអប់រំក្រៅប្រព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៩០ នាក់ ស្រី ២១ នាក់ ស្មើនឹង ២៣,៣ ភាគរយ
- បោះពុម្ពប័ណ្ណផ្ទត់ ផ្ទាំងរូបភាព និងគោលនយោបាយអប់រំក្រៅប្រព័ន្ធចែកជូនគ្រប់រាជធានីខេត្ត និងរៀងរាល់ទិវាអក្ខរកម្មជាតិ ៨ កញ្ញា។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍបានពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមួយចំនួននៅមូលដ្ឋានភូមិ ឃុំ សង្កាត់ទាំង ២៥ រាជធានីខេត្ត។ ពិនិត្យតាមដាន និងវាយតម្លៃ

គុណភាពអប់រំវិជ្ជាជីវៈនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និងពោធិ៍សាត់ ១៤ លើការអនុវត្តកម្មវិធីសិក្សា សកម្មភាពរៀន និងបង្រៀនមុខជំនាញប្រភព និងលក្ខខណ្ឌនៃការជ្រើសរើសសិស្ស និងគ្រូតាមជំនាញនីមួយៗ។ បានរៀបចំ និងស្នើសុំគោលការណ៍ និងយន្តការបញ្ជាក់ការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល និងចុះស្រាវជ្រាវព័ត៌មានបន្ថែម ដើម្បីឆ្លើយតបនឹងអនុក្រឹតស្តីពីនីតិវិធីនៃការវាស់ស្ទង់កម្រិតសមត្ថភាពសមមូលនៅខេត្តតាកែវ កំពង់ចាម សៀមរាប បាត់ដំបង និងព្រះសីហនុ។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែង ២០១៣ | ចំណុចដៅ ២០១៤ | ជាក់ស្តែង ២០១៤ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុចាប់ពី១៥-៤៥ឆ្នាំ | ៧៧,៦% (ឆ្នាំ២០០៨) | ៨៧,០% | ៨០%* (ឆ្នាំ២០១៣) | → |
| ២ | ភាគរយប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ៧៩% | ៦៩% | ៨២,៨% | ↑ |
| ៣ | ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | ៧ ៦៤៩ | ១៣,៨៩១ | ៨,៥២៤ | → |
| ៤ | ភាគរយកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ៨៧,១% | ៩៥% | ៨៦,២% | ↓ |
| ៥ | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ៧៥៩ | ៥,៧០៩ | ៤,១៨៦ | → |
| ៦ | រាជធានីខេត្តរៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ២ | ៥ | ២២ | ↑ |
| ៧ | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | ៣៤៨ | ៣៧១ | ៣៤៧ | → |
| ៨ | មជ្ឈមណ្ឌលសិក្សាសហគមន៍មានស្តង់ដារ | ០ | ៥% | ០ | ↓ |

<u>*សម្គាល់*</u>: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

ប្រភព៖ * អង្កេតសង្គមកិច្ច សេដ្ឋកិច្ចនៅកម្ពុជាឆ្នាំ២០១៤

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការផ្គត់ផ្គង់សម្ភារៈបង្រៀន និងរៀនសម្រាប់ទ្រទ្រង់ដំណើរការថ្នាក់អក្ខរកម្មពុំទាន់ឆ្លើយតបនឹងតម្រូវការ
- កម្មវិធីសិក្សាអក្ខរកម្មវិជ្ជាជីវៈមិនសូវមានភាពទាក់ទាញក្រុមមុខសញ្ញា
- ការប្រមូលសិស្សបោះបង់ការសិក្សាឱ្យចូលរៀនឡើងវិញជួបការលំបាក
- កង្វះការលើកទឹកចិត្តគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
- កង្វះគ្រូជំនាញមុខរបរសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍

- ការបង្រៀនជំនាញមុខរបរនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ មិនទាន់មានការផ្លាស់ប្តូរឱ្យឆ្លើយតបនឹងតម្រូវការសហគមន៍
- កង្វះបណ្ណារក្សសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ
- សមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនៅមិនទាន់ឆ្លើយតប
- ការគ្រប់គ្រងស្ថិតិ និងទិន្នន័យអប់រំក្រៅប្រព័ន្ធ ៥ ខេត្ត មិនទាន់បានល្អ។

## ២.២.៦ វិស័យ ការអភិវឌ្ឍយុវជន

### ក. លទ្ធផលសម្រេចបាន

*ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា*

ក្រសួងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងផែនការសកម្មភាពជាតិ មានស្ថាប័នពាក់ព័ន្ធចូលរួម ៧០ នាក់ ស្រី ៣៦ ភាគរយ នៅរាជធានីភ្នំពេញ។

*ការងារក្រុមប្រឹក្សាយុវជននិងកុមារ*

ក្រសួងបាន៖

- កែលម្អរចនាសម្ព័ន្ធ និងឯកសារទស្សនាទានស្តីពីការអភិវឌ្ឍយុវជន និងកុមារថ្នាក់រាជធានី ខេត្ត។ ក្រុមប្រឹក្សាកុមារពីថ្នាក់ទី៤ ដល់ ទី៩ មាន ៧ ៦០១ ក្រុម ៣៨ ២៣៧ សាខា ២២៤ ៨៥៧ អនុសាខា និងសមាជិក ១ ៣៩៤ ៩១៣ នាក់ ស្រី ៤៩ ភាគរយ។ ក្រុមប្រឹក្សាយុវជនពីថ្នាក់ទី១០ ដល់ ទី១២ មាន ៩៤៤ ក្រុម ៦ ០៣១ សាខា ៣៦ ១៨៦ អនុសាខា និងសមាជិក ២៦៦ ២៩៣ នាក់ ស្រី ៤៨ ភាគរយ
- បូកសរុបវាយតម្លៃចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" យុវជន និងកុមារ ៣២០ នាក់ ស្រី ៤៣ ភាគរយ បានទទួលរង្វាន់ និងប័ណ្ណសរសើរ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាយុវជន និងកុមារដែលមានស្នាដៃក្នុងសកម្មភាពបីល្អ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល ស្វាយរៀង តាកែវ កំពង់ឆ្នាំង មណ្ឌលគិរី និងព្រៃវែង
- ប្រារព្ធទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី៦៥ មានកុមារចូលរួម ១ ០០០ នាក់ កុមារី ៥០ ភាគរយ។ ទិវាអន្តរជាតិសម្រាប់យុវជន ១២ សីហា ខួបលើកទី១២ ក្រោមប្រធានបទ «យុវជន និងសុខភាពផ្លូវចិត្ត» មានយុវជនចូលរួម ១ ៥០០ នាក់ ស្រី ៤៥ ភាគរយ
- លើកកម្ពស់សមត្ថភាពគ្រូបង្គោល ស្តីពីការងារក្រុមប្រឹក្សាកុមារការងារក្រុមប្រឹក្សាយុវជន និងសកម្មភាពក្លឹបថ្នាក់ក្រុង ស្រុក ខណ្ឌ ៦ ៣០០ នាក់ ស្រី ៤៣ ភាគរយ
- បំប៉នការយល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍ដល់យុវជនក្រៅសាលា ១៣ ៨០០ នាក់ ស្រី ៣៦ ភាគរយ ។

*កម្មវិធីសហគ្រិនភាព*

ក្រសួងបាន៖

- បណ្តុះបណ្តាលគ្រូបង្គោល និងយុវជនសហគ្រិនថ្នាក់ជាតិ ១២៧ នាក់ ស្រី ៩,៥ ភាគរយ នៅខេត្តតាកែវ និងកំពង់ឆ្នាំង

- អនុវត្តសាកល្បងការអប់រំសហាគ្រិនភាព (ការយល់ដឹងពីធុរកិច្ច) នៅវិទ្យាល័យគោលដៅ ៥ ក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពង់ឆ្នាំង និងកំពង់ធំ ដែលមានសិស្សចូលរួម ១២៥ នាក់ ស្រី ៧៥ នាក់។

## *កម្មវិធីយុវជនស្ម័គ្រចិត្ត*

ក្រសួងបានៈ

- បង្កើតក្រុមយុវជនស្ម័គ្រចិត្តថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ ២ ៤០០ នាក់ ស្រី ១ ០៤០ នាក់
- បណ្តុះបណ្តាលការងារយុវជនស្ម័គ្រចិត្តថ្នាក់ស្រុក ខណ្ឌបាន ៤៣ ស្រុក ខណ្ឌ នៅតាមរាជធានី ខេត្ត ២២
- បង្កើតនាទីអប់រំយុវជននិងកុមារ កែលម្អ និងផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជា ដោយមានកម្មវិធីសំណួរ ចម្លើយ ជូនរង្វាន់ដល់សិស្ស
- បញ្ជូនមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញ ៥ នាក់ បានចូលរួមប្រជុំថ្នាក់ឧត្តមមន្ត្រីទទួលបន្ទុកការងារយុវជនលើកទី៧ និងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានបូក៣ ទទួលបន្ទុកការងារយុវជនលើកទី៦ នៅប្រ៊ុយណេ
- បញ្ជូនមន្ត្រីទទួលបន្ទុកការងារយុវជន ២ នាក់ បានចូលរួមប្រជុំខួបលើកទី១០ នៃកិច្ចសហប្រតិបត្តិការកម្មវិធីមិត្តភាពយុវជនមហាអនុតំបន់ទន្លេមេគង្គនៅថៃ
- បញ្ជូនមន្ត្រីជំនាញយុវជន ១ នាក់ បានចូលរួមប្រជុំវាយតម្លៃការងារនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤០ និងលើកទិសដៅការងារនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤១ នៅជប៉ុន
- បញ្ជូនយុវជន ២៨ នាក់ ស្រី ៥០ ភាគរយ និងអ្នកដឹកនាំ ១ នាក់ បានទៅចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤១ នៅតាមបណ្តាប្រទេសអាស៊ាន និងជប៉ុន ។

កុមារនិងយុវជន ៨៦ នាក់ ស្រី ៩៩ ភាគរយ និងអ្នកដឹកនាំ ៣ នាក់ បានទៅចូលរួមកម្មវិធីផ្លាស់ប្តូរទំនាក់ទំនងអប់រំ វប្បធម៌ នៅជប៉ុន សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ថៃ សាធារណរដ្ឋប្រជាមានិតចិន និងឥណ្ឌា។

កុមារនិងយុវជន ២៥ នាក់ ស្រី ៥២ ភាគរយ និងអ្នកដឹកនាំ ៤ នាក់ ស្រី ២៥ ភាគរយ បានទៅចូលរួមបោះជំរំនៅសិង្ហបុរី និងសាធារណរដ្ឋប្រជាមានិតចិន។

កុមារនិងយុវជន ២២ នាក់ ស្រី ៥៤ ភាគរយ អ្នកដឹកនាំ ២ នាក់ បានទៅចូលរួមសន្និសីទ និងវេទិកានានា នៅសាធារណរដ្ឋកូរ៉េ ជប៉ុន និងសិង្ហបុរី។

*កម្មវិធីទស្សនកិច្ចសិក្សា និងបោះជំរំ*

ក្រសួងបាន៖

- បោះជំរំយុវជនថ្នាក់ជាតិលើកទី១៦ ក្រោមប្រធានបទ «យុវជន និងបរិស្ថាន» នៅខេត្តស្ទឹងត្រែង មានសមាជិកក្រុមប្រឹក្សាយុវជនរាជធានី ខេត្ត ២៩០ នាក់ ស្រី ៣៦ ភាគរយ
- រៀបចំទស្សនកិច្ចសិក្សាដើម្បីយល់ដឹងពីសម្បត្តិវប្បធម៌ និងប្រាង្គប្រាសាទ នៅខេត្តសៀមរាប មានកុមារចូលរួម ១២០ នាក់ ស្រី ៤២ ភាគរយ និងយុវជន ៣២០ នាក់ ស្រី ៤០ ភាគរយ
- រៀបចំទស្សនកិច្ចសិក្សាយុវជនស្ម័គ្រចិត្តក្រៅសាលា ១៨១ នាក់ ស្រី ៧៨ នាក់ នៅខេត្តសៀមរាប
- រៀបចំវេទិកាយុវជនតំបន់ត្រីកោណអភិវឌ្ឍកម្ពុជា ឡាវ វៀតណាម ដែលមានប្រតិភូយុវជនចូលរួម ៥៨ នាក់ ស្រី ២៨ ភាគរយ (វៀតណាម ១៣ នាក់ ស្រី ៦ នាក់ ឡាវ ២០ នាក់ ស្រី ៦ នាក់ និង កម្ពុជា ២៥ នាក់ ស្រី ១៨ នាក់) និងបោះជំរំយុវជនកម្ពុជា ៣៥០ នាក់ ស្រី ៤២ ភាគរយ នៅខេត្តក្រចេះ
- ទទួលនាវាយុវជនអាស៊ីអាគ្នេយ៍លើកទី៤១ មានយុវជនមកពីប្រទេសសមាជិកអាស៊ាន និងជប៉ុន ៣៦៧ នាក់ ស្រី ៥០ ភាគរយ និងយុវជនជប៉ុន ៨៨ នាក់ ស្រី ៥០ ភាគរយ បានមកទស្សនកិច្ចសិក្សា។

*ការបណ្តុះបណ្តាលជំនាញដល់យុវជន*

ក្រសួងបាន៖

- ចុះសិក្សាពីតម្រូវការការងារយុវជនបាន ១៦ ខេត្ត។ មជ្ឈមណ្ឌលយុវជនក្នុងខេត្ត ១៥ បានបណ្តុះបណ្តាលជំនាញកាត់ដេរ ភ្លេងខ្មែរ ភ្លេងសម័យ ភ្លេងពិណពាទ្យ អក្សរភ្លេង ជួសជុលទូរស័ព្ទដៃ សម្អាងការ ចិញ្ចឹមមាន់ បណ្តុះផ្សិត ចម្លាក់ស្បែក ចម្លាក់ថ្មកែវ ជាងសំណង់ កុំព្យូទ័រ ដល់យុវជន ៣ ០៦៥ នាក់ ស្រី ១ ៧៨៥ នាក់
- ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារមជ្ឈមណ្ឌលយុវជន និងសកម្មភាពយុវជនស្ម័គ្រចិត្ត ២៥ រាជធានី ខេត្ត និងជំរុញដំណើរការរៀបចំអភិវឌ្ឍមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត ២២ ។

## ខ. ការសម្រេចបានសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអភិវឌ្ឍយុវជន | ជាក់ស្តែង ២០១៣-១៤ | ចំណុចដៅ ២០១៤-១៥ | ជាក់ស្តែង ២០១៤-១៥ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | ២ ៧០០ | ២ ៩០០ | ៣ ០៦៥ | ↑ |
| ២ | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព | ៣០០ | ៣០០ | ១២៥ | ↓ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ចំនួនយុវជនដែលបានបង្កើតការងារដោយខ្លួនឯងក្នុងមួយមជ្ឈមណ្ឌលក្នុងមួយឆ្នាំ | ១០ | ១០ | ៧ | ↓ |
| ៤ | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | ២ ៥០០ | ២ ៧០០ | ២ ៤០០ | ↓ |
| ៥ | ចំនួនមជ្ឈមណ្ឌលយុវជន | ៩ | ១៥ | ១៥ | ↑ |
| ៦ | ភាគរយសិស្សថ្នាក់ទី៤-៩ចូលរួមក្នុងក្រុមប្រឹក្សាកុមារ | ៩៩% | ៩៩% | ៩៩% | ↑ |
| ៧ | ភាគរយសិស្សថ្នាក់ទី១០-១២ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | ៨៩% | ៩៤% | N/A | ↓ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- សមត្ថភាពគ្រប់គ្រងរបស់មន្ត្រីទទួលបន្ទុកការងារមជ្ឈមណ្ឌលយុវជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត
- កង្វះសម្ភារៈ និងធនធានមនុស្សសម្រាប់បម្រើការនៅមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត
- ទីតាំងដីមជ្ឈមណ្ឌលយុវជនរាជធានីខេត្ត ៦ មិនទាន់មានរបង និងការសាងសង់
- ការផ្សព្វផ្សាយព័ត៌មានការងារ និងការងារស្ម័គ្រចិត្តមិនទាន់បានទូលំទូលាយ
- ការបំប៉នជំនាញទន់មិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន
- កង្វះធនធាន និងមធ្យោបាយសម្រាប់ដំណើរការក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន ជាពិសេសការបង្កើតក្លឹបសិក្សា
- កង្វះធនធាន និងមិនទាន់មានយន្តការសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

## ២.២.៧ អនុវិស័យការអប់រំកាយ និងកីឡា

### ក. លទ្ធផលសម្រេចបាន

*ការប្រកួតកីឡាសិស្ស-និស្សិត*

ការប្រកួតកីឡាសិស្សកម្រិតមធ្យមសិក្សាជ្រើសរើសជើងឯកទូទាំងប្រទេស នៅខេត្តកំពង់ឆ្នាំង មានកីឡាករ ២ ៧៣៧ នាក់ ស្រី ១ ២០៨ នាក់។ ការប្រកួតកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស នៅរាជធានីភ្នំពេញ មានកីឡាករ ១ ១៤៥ នាក់ ស្រី ២៤៩ នាក់។

*ការប្រកួតកីឡាសហព័ន្ធ*

ការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ជាតិ ២១ ប្រភេទកីឡា មានកីឡាករ ៥ ១៦១ នាក់ ស្រី ៨១៧ នាក់ នៅពហុកីឡដ្ឋានជាតិ។ កីឡាប្រណាំងកង់ នៅខេត្តកំពត កីឡាបេស្បល នៅខេត្តកំពង់ធំ កីឡាប្រណាំងទូកប្រពៃណីខ្នាតអន្តរជាតិ និងទូកកានូកាយ៉ាក់ នៅក្រុងតាខ្មៅ និងកីឡាគុនដាវ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ភូមិភាគ ៤ ប្រភេទកីឡា បានធ្វើនៅមណ្ឌលរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង កោះកុង បាត់ដំបង និងមណ្ឌលគិរី ដែលមានកីឡាករ ១ ៣៦០ នាក់ ស្រី ១៦២ នាក់។ ការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ជាតិ ៤ ប្រភេទកីឡា បានធ្វើនៅមណ្ឌលកំពត មានកីឡាករ ១ ៣៨៨ នាក់ ស្រី ៦១០ នាក់ ។

*ប្រកួតកីឡាសម្រាប់ទាំងអស់គ្នា*

សហភាពសហព័ន្ធយុវជនកម្ពុជាបានរៀបចំការប្រកួតកីឡាបាល់ទះ និងបាល់ទាត់ពានរង្វាន់សហភាពសហព័ន្ធយុវជនកម្ពុជាប្រចាំឆ្នាំ២០១៤ នៅពហុកីឡដ្ឋានជាតិ។ មន្ត្រីបច្ចេកទេស ៥ នាក់ បានដឹកនាំការប្រកួតជម្រុះកីឡាបាល់ទាត់ពានរង្វាន់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** លើកទី៨នៅខេត្តព្រៃវែង បាត់ដំបង សៀមរាប និងរាជធានីភ្នំពេញ។ មន្ត្រី ៨ នាក់ បានដឹកនាំការប្រកួតកីឡាប៉េតង់ពានរង្វាន់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី**។ មន្ត្រី ៨ នាក់ បានសហការជាមួយសហព័ន្ធបាល់ទះ កម្ពុជា ដឹកនាំការប្រកួតកីឡាបាល់ទះពានរង្វាន់ភេសជ្ជៈលីអូ និងពានរង្វាន់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅពហុកីឡដ្ឋានជាតិ ។

ក្រសួងបានសហការជាមួយនិយោជកកូរ៉េ និងនិយោជិតកម្ពុជារៀបចំព្រឹត្តិការណ៍កីឡាដើម្បីទាំងអស់គ្នាលើប្រភេទកីឡា បាល់ទាត់ បាល់ទះ អត្តពលកម្ម និងទាញព្រ័ត្រ ដើម្បីអបអរសាទរចំណងមិត្តភាពកម្ពុជា-កូរ៉េ នៅពហុកីឡដ្ឋានជាតិ។

## *ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ*

ការប្រកួតកីឡាប៉េតង់ ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី១ នៅឡាវ បានមេដាយមាស ៣ ប្រាក់ ៦ និងសំរឹទ្ធ ១។ ការប្រកួតកីឡាជើងឯកអាស៊ីតេក្វាន់ដូលើកទី៧ នៅនេប៉ាល់ បានមេដាយប្រាក់ ១ និងសំរឹទ្ធ ៣។ ការប្រកួតកីឡាជើងឯកអាស៊ីតេក្វាន់ដូលើកទី២១ នៅអ៊ូបេហ្គីស្ថាន បានមេដាយសំរឹទ្ធ ១។ ការប្រកួតកីឡាសីប៉ាក់តាក្រ ពានរង្វាន់ព្រះមហាក្សត្រថៃ នៅថៃ បានមេដាយមាស ១។ ការប្រកួតកីឡាអាស៊ីហ្គេមលើកទី១៧ នៅសាធារណរដ្ឋកូរ៉េ បានមេដាយមាស ១ លើប្រភេទកីឡាតេក្វាន់ដូ។ ការប្រកួតកីឡាជើងឯកវ៉ូវីណាម ជើងឯកអាស៊ីអាគ្នេយ៍លើកទី៣ នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា បានមេដាយមាស ៣ ប្រាក់ ៣ និងសំរឹទ្ធ ៨។ ការប្រកួតកីឡាចំបាប់ជើងឯកអាស៊ីអាគ្នេយ៍បូកអូស្ត្រាលី នៅសិង្ហបុរី បានមេដាយមាស ១ ប្រាក់ ១ និងសំរឹទ្ធ ២។ ការប្រកួតកីឡាឈិនឡុនជ្រើសរើសជើងឯកអាស៊ីលើកទី១នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា បានមេដាយមាស ២ និងសំរឹទ្ធ ៤។ ការប្រកួតកីឡាជើងឯកប៉េតង់អាស៊ីលើកទី១៨ នៅថៃ បានមេដាយមាស ៤ និងប្រាក់ ១។ ការប្រកួតកីឡាអាស៊ីឆ្នេរខ្សាច់ហ្គេមលើកទី៤ នៅថៃ បានមេដាយសំរឹទ្ធ ១។ ការប្រកួតកីឡាយូដូជើងឯកអាស៊ីអាគ្នេយ៍ ២០១៤ នៅសិង្ហបុរី បានមេដាយប្រាក់ ២។ ការប្រកួតកីឡាសាកលវិទ្យាល័យអាស៊ានហ្គេមលើកទី ១៧ នៅឥណ្ឌូនេស៊ី បានមេដាយប្រាក់ ៣។ ការប្រកួតលក្ខណៈអន្តរជាតិឆ្នាំ២០១៤ សរុបមេដាយ ៥២ គ្រឿង ក្នុងនោះមាស ១៥ ប្រាក់ ១៧ និងសំរឹទ្ធ ២០។

**តារាងទី១៨ ៖ ការបញ្ជូនកីឡាករចូលរួមប្រកួតលក្ខណៈអន្តរជាតិ និងលទ្ធផលទទួលបានឆ្នាំ២០១៤**

| ប្រភេទកីឡា | ចំនួនចូលរួម | កាលបរិច្ឆេទ | ទីកន្លែង | ឈ្មោះការប្រកួត | ប្រភេទមេដាយ | | | |
|---|---|---|---|---|---|---|---|---|
| | | | | | មាស | ប្រាក់ | សំរឹទ្ធ | សរុប |
| កីឡាប៉េតង់ | ១៦ នាក់ | ០៨-១៣/៤/១៤ | ឡាវ | ជើងឯកអាស៊ីអាគ្នេយ៍ | ៣ | ៦ | ១ | ១០ |
| តេក្វាន់ដូ ITF | ៩នាក់ | ១៨-២៣/០៤/១៤ | នេប៉ាល់ | ជើងឯកអាស៊ី ៧ | 0 | ១ | ៣ | ៤ |
| ប្រណាំងកង់ | ៨នាក់ | ១៧-២៦/០៥/១៤ | វៀតណាម | ពាន.ការពារវក្ខជាតិ | 0 | 0 | 0 | 0 |
| ចំបាប់ | ៦នាក់ | ០៧-១២/០៥/១៤ | ថៃ | ជម្រុះYog | 0 | 0 | 0 | 0 |
| តេក្វាន់ដូ WTF | ៨នាក់ | ២៣-២៩/០៥-១៤ | Uzbekistan | ជើងឯកអាស៊ី ២១ | 0 | 0 | ១ | ១ |
| អត្តពលកម្ម | ២នាក់ | ១០-១៦/០៦/១៤ | តៃវ៉ាន់ | ជើងឯកអាស៊ី ១៦ | 0 | 0 | 0 | 0 |
| វាយកូនបាល់ | ៦នាក់ | ៩-១៥/០៦/១៤ | អ៊ីរ៉ង់ | Oceania Zone Group III | 0 | 0 | 0 | 0 |
| តេក្វាន់ដូ | ៨នាក់ | ១០-១៧/០៧/១៤ | សាធារណរដ្ឋកូរ៉េ | The 2014 Gyeongiu Korean Open | 0 | 0 | 0 | 0 |
| អត្តពលកម្ម | ៥នាក់ | ២៤-២៧/០៧/១៤ | វៀតណាម | ជើងឯកលើកទី២១ | 0 | 0 | 0 | 0 |
| គុនដាវ | ២នាក់ | ២៦-២៧/០៧/១៤ | សិង្ហបុរី | មហាវិទ្យាល័យអាស៊ី២១ | 0 | 0 | 0 | 0 |
| ប៉េតង់ | ១០នាក់ | ២៨/០៨-០៣/០៩ ២០១៤ | វៀតណាម | ជើងឯកប៉េតង់លើកទី២៣ | 0 | 0 | 0 | 0 |
| សីប៉ាក់តាក្រ | ២០នាក់ | ៣-១១/០៨/១៤ | ថៃ | ពានស្តេចថៃ | ១ | 0 | 0 | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អត្តពលកម្ម ហែលទឹក ចំបាប់ | ៨នាក់ | ១៦-២៨/០៨/១៤ | ចិន | អូឡាំពិកយុវជន លើកទី២ | ០ | ០ | ០ | ០ |
| ហែលទឹក អត្តពលកម្ម យូដូ វាយកូនបាល់ តេក្វាន់ដូ បាល់ទះ ឆ្នេរខ្សាច់ ចំបាប់ | ៣៦នាក់ | ១៩/០៩-០៤/១០ ២០១៤ | សាធារណរដ្ឋកូរ៉េ | ជើងឯកអាស៊ី ១៧ | ១ | ០ | ០ | ១ |
| វ៉ូវីណាម | ១៥នាក់ | ២០-២៥/១០/១៤ | មីយ៉ាន់ម៉ា | ជើងឯកអាស៊ី ២ | ៣ | ៣ | ៨ | ១៤ |
| ចំបាប់ | ១២នាក់ | ២៣-២៧/១០/១៤ | សិង្ហបុរី | ជើងឯកអាស៊ី +១ (អូស្ត្រាលី) | ១ | ១ | ២ | ៤ |
| សីប៉ាក់តាក្រ (Chinlone) | ១៦នាក់ | ១-៦/១១/២០១៤ | មីយ៉ាន់ម៉ា | ជើងឯកអាស៊ី លើកទី១ | ២ | ០ | ៤ | ៦ |
| ប៉េតង់ | ១៦នាក់ | ២៧-៣០/១១/១៤ | ថៃ | ជើងឯកប៉េតង់ ទី១៨ | ៤ | ១ | ០ | ៥ |
| ចំបាប់ បាល់ទះ ឆ្នេរខ្សាច់ Foot volley | ១៦នាក់ | ១៤-២៣/១១/១៤ | ថៃ | ជើងឯកអាស៊ី លើកទី៤ Beach Game | ០ | ០ | ០ | ០ |
| គុនដាវ | ៥នាក់ | ៣១/១០-០២/១១ ២០១៤ | ថៃ | The Foiljunior World Cup 2014 | ០ | ០ | ០ | ០ |
| បាល់ទះឆ្នេរខ្សាច់ | ៦នាក់ | ០៨-១២/១១/១៤ | ថៃ | Beach Volleyball Continental Cup | ០ | ០ | ០ | ០ |
| ប្រណាំងកង់ | ៨នាក់ | ៣០/១១-១៨/១២ ២០១៤ | វៀតណាម | ពានរង្វាន់ការពារជាតិ | ០ | ០ | ០ | ០ |
| យូដូ | ៥នាក់ | ២២-២៥/១១ ២០១៤ | សិង្ហបុរី | អាស៊ីអាគ្នេយ៍ ២០១៤ | ០ | ២ | ០ | ២ |
| សាកលវិទ្យាល័យអាស៊ាន | ៥១នាក់ | ១០-២១/១២ ២០១៤ | ឥណ្ឌូនេស៊ី | សាកលវិទ្យាល័យអាស៊ានទី១៧ | ០ | ៣ | ០ | ៣ |
| សរុប | ២៨៦នាក់ | | ១៣ប្រទេស | | ១៥ | ១៧ | ២០ | ៥២ |

ក្រសួងបាន៖

- ប្រារព្ធពិធីប្រគល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជូនដល់កីឡាករ កីឡាការិនីទទួលជ័យលាភីប្រកួតកីឡាស៊ីហ្គេមលើកទី២៧ នៅមីយ៉ាន់ម៉ា ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ាណែត** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- ប្រារព្ធពិធីប្រគល់ប្រាក់រង្វាន់ជ័យលាភី និងប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ជូនដល់ជ័យលាភីគ្រូបង្វឹក គ្រូជំនួយ និងកីឡាករ កីឡាការិនី ក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី២៧ និងការប្រកួត

អន្តរជាតិមាន វៀរីណាម និងប៉េតង់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសតាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

- ប្រគល់ប្រាក់រង្វាន់ជ័យលាភីរបស់រាជរដ្ឋាភិបាលជូនដល់គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ កីឡាការិនី វៀរីណាម តេក្វាន់ដូ និងចំបាប់ ៣៣ នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសតាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានជាតិអប់រំ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤
- ទទួលប្រតិភូកីឡាអាស៊ីហ្គេមលើកទី១៧ និងប្រគល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត និងប្រាក់រង្វាន់ជ័យលាភីរបស់រាជរដ្ឋាភិបាលដល់វីរៈកីឡាការិនី **ស៊ន សៀវម៉ី** ដែលទទួលបានមេដាយមាសប្រភេទកីឡាតេក្វាន់ដូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានសន្តិភាព ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៤
- ប្រគល់ប្រាក់រង្វាន់ជ័យលាភី គ្រូបង្វឹក គ្រូជំនួយ កីឡាករកីឡាការិនីប៉េតង់ និងកីឡាករតេក្វាន់ដូ នៅក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥។

*ការលើកកម្ពស់សកម្មភាពអប់រំកាយ និងកីឡាក្នុងម៉ោងនិងក្រៅម៉ោងសិក្សា*

ក្រសួងបាន៖

- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេសថ្នាក់រាជធានី ខេត្ត និងគ្រឹះស្ថានសិក្សាទាំងបីកម្រិតសិក្សា
- កែលម្អទីលានកីឡាក្នុងគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ៦ នៅខេត្តតាកែវ និងកំពង់ឆ្នាំង
- ធ្វើតេស្តកាយសម្បទាកុមារអាយុ ៦ ដល់ ១២ឆ្នាំ តាមសាលាគោលដៅ ២ ក្នុងមួយរាជធានី ខេត្ត មានសិស្សចូលរួម ១៦ ៨០០ នាក់ ស្រី ៨ ៤០០ នាក់
- ចងក្រងសៀវភៅអប់រំកាយ និងកីឡា សម្រាប់គ្រូនៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត ៧ មុខវិជ្ជា តេស្តកាយសម្បទា អប់រំកាយជាមួយចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម បាល់ទាត់ បាល់ទះ និងបាល់បោះដោយសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន
- ពង្រឹងការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមសាលាបឋមសិក្សាគោលដៅ មានអ្នកចូលរួម ៥៧០ នាក់ ស្រី ១៤៣ នាក់ និងនៅសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ៤ គឺខេត្តក្រចេះ ស្ទឹងត្រែង ព្រះសីហនុ និងកំពត

- លើកកម្ពស់សមត្ថភាពគ្រូបង្រៀនមុខវិជ្ជាអប់រំកាយ និងកីឡានៅសាលាបឋមសិក្សាមកពីមន្ទីរអប់រំ យុវជន និងកីឡា ៨ គឺខេត្តកំពង់ឆ្នាំង តាកែវ បាត់ដំបង រតនគិរី ក្រចេះ ព្រះវិហារ និងស្វាយរៀង មានអ្នកចូលរួម ៣៦ នាក់ ស្រី ១២ នាក់
- រៀបចំទិវាអប់រំកាយ និងកីឡានៅសាលាបឋមសិក្សាគោលដៅ ២ នៅស្វាយរៀង មានសិស្សចូលរួម ១ ១៩០ នាក់ ស្រី ៥៦៨ នាក់
- បែងចែកសៀវភៅគ្រូស្តីពីការអប់រំកាយ និងកីឡាសម្រាប់សាលាបឋមសិក្សា ៣០ ០០០ ក្បាល ក្នុងនោះមានមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ ព្រះសីហនុ កំពង់ធំ តាកែវ បាត់ដំបង សៀមរាប ស្វាយរៀង កំពង់ឆ្នាំង បន្ទាយមានជ័យ កោះកុង កំពត ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងព្រៃវែង ដោយសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ។

### *ការកសាងលិខិតបទដ្ឋានស្តីពីការអប់រំកាយ និងកីឡា*

ក្រសួងបាន៖

- រៀបចំវេទិកាសាធារណៈស្តីពីកំណែទម្រង់វិស័យអប់រំកាយ និងកីឡានៅសាលហ្វឹកហាត់តេក្វាន់ដូប៊ូយ៉ុងខ្មែរ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលរួមមកពីគ្រប់សហព័ន្ធកីឡាជាតិ ដៃគូអភិវឌ្ឍ និងមន្ត្រីបម្រើការងារវិស័យកីឡា
- ចេញសេចក្តីប្រកាស ស្តីពីការអនុញ្ញាតឱ្យសមាជិកគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាជាតិ៩ សម្រាប់អនុវត្តការងារអាណត្តិថ្មី គឺសហព័ន្ធកីឡាប្រដាល់កម្ពុជា សហព័ន្ធកីឡាខ្មែរហែលទឹក សហព័ន្ធកីឡាវាយកូនបាល់កម្ពុជាខេមរ សហព័ន្ធកីឡាការ៉ាតេដូ សហព័ន្ធកីឡារាំកម្ពុជា សហព័ន្ធកីឡាហោះហើរកម្ពុជា សហព័ន្ធកីឡាគុងហ្វីម៉ូដូកម្ពុជា សហព័ន្ធកីឡាបាល់ឱបកម្ពុជា សហព័ន្ធកីឡាស្វូហ្វតេនីសកម្ពុជា
- ចេញប្រកាសស្តីពីការទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ជ័យលាភី ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិនានា
- ពិនិត្យឡើងវិញគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា និងបានរៀបចំវិសោធនកម្មប្រកាសអន្តរក្រសួង ស្តីពីចំណាយសម្រាប់ការរៀបចំការប្រកួតជាផ្លូវការក្នុងប្រទេស អាហារូបត្ថម្ភកីឡាករជម្រើសជាតិ និងការចូលរួមប្រកួតជាលក្ខណៈជើងឯកអន្តរជាតិ។

### *ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា*

ក្រសួងបាន៖

- ជួសជុលដំបូលអគាររដ្ឋបាល និងបន្ទប់ទឹក VIP នៃពហុកីឡដ្ឋានជាតិ

- ជួសជុលអគារ ផ្លូវ សួនច្បារ និងភ្លើងបំភ្លឺ និងទីលានរត់ប្រណាំងនៅក្នុងពហុកីឡដ្ឋានជាតិ
- រៀបចំទីប្រឹក្សាពិសេសដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យពហុកីឡដ្ឋានជាតិ
- សហការជាមួយសហព័ន្ធកីឡាបាល់ទាត់កម្ពុជាគាំទ្រដោយក្រុមហ៊ុន CCGRASS ធ្វើទំនើបកម្មទីលានបាល់ទាត់ពហុកីឡដ្ឋានជាតិ ឧបត្ថម្ភថវិកាដោយសហព័ន្ធកីឡាបាល់ទាត់អន្តរជាតិ។

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការបច្ចេកទេស សម្រាប់គម្រោងសាងសង់ **ពហុកីឡដ្ឋានជាតិមរតកតេជោ** ក្នុងក្របខណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន តាមរយៈសេចក្តីសម្រេចលេខ ១៦៣ សសរ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤។

*ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកាយនិងកីឡា*

ក្រសួងបាន៖

- ចុះពិនិត្យតាមដានលើការពង្រឹងសមត្ថភាពមន្ត្រីជំនាញកីឡា ដែលបានបំប៉នសមត្ថភាពនៅខេត្តបាត់ដំបង កំពង់ធំ ពោធិ៍សាត់ សៀមរាប កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រះសីហនុ កោះកុង តាកែវ ស្វាយរៀង ព្រៃវែង និងកំពង់ចាម
- បញ្ជូនមន្ត្រី ២ នាក់ ទៅចូលរួមវគ្គអាជ្ញាកណ្តាលបាល់ទាត់កម្រិតខ្ពស់ នៅប្រ៊ុយណេ និងមន្ត្រី ១ នាក់ ទៅចូលរួមវគ្គអាជ្ញាកណ្តាលបាល់ទាត់ក្នុងសាលតំបន់អាស៊ីអាគ្នេយ៍ នៅថៃ។

*ការលើកកម្ពស់សមត្ថភាពកីឡាករ*

គ្រូបង្វឹក និងកីឡាករ ៣៥១ នាក់ ស្រី ៦៨ នាក់ មកពីសហព័ន្ធកីឡាជាតិ ២១ បានមកហ្វឹកហ្វឺនរយៈពេល ៧ខែ ដើម្បីចូលរួមប្រកួតកីឡាអូឡាំពិកយុវជនលើកទី២ ប្រកួតកីឡាអាស៊ីហ្គេមលើកទី១៧ ប្រកួតកីឡាអាស៊ីឆ្នេរខ្សាច់លើកទី៤ ប្រកួតកីឡាសាកលវិទ្យាល័យអាស៊ានហ្គេមលើកទី១៧ និងប្រកួតជាលក្ខណៈអន្តរជាតិ។

កីឡាករបាល់ទាត់អាយុក្រោម ១៣ ឆ្នាំ (U13) ២២ នាក់ បានធ្វើការហ្វឹកហ្វឺន ស្នាក់នៅ និងរៀនសូត្រនៅមជ្ឈមណ្ឌលសាលាកីឡាបាល់ទាត់ជាតិបាទី សម្រាប់កម្ពុជាត្រៀមធ្វើម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

កីឡាករ ៩ នាក់ បានបញ្ជូនទៅហ្វឹកហ្វឺនក្រៅប្រទេស រួមមាន តេក្វាន់ដូ ៤ នាក់ វាយកូនបាល់ ១ នាក់ និង អត្តពលកម្ម ៤ នាក់ នៅសាធារណរដ្ឋកូរ៉េ សហរដ្ឋអាម៉េរិក និងជប៉ុន។

មន្ត្រីបច្ចេកទេស និងគ្រូបង្វឹក ៦ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលើជំនាញគ្រូបង្វឹក អាជ្ញាកណ្តាលប្រភេទកីឡាកាយសម្ព័ន្ធ គុនដាវ តេក្វាន់ដូ និងវូស៊ូ នៅហ្វីលីពីន ជប៉ុន ហុងហ្គារី សាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋប្រជាមានិតចិន។

ក្រសួងបាន៖

- ចុះកិច្ចព្រមព្រៀងទទួលយកគ្រូកូរ៉េខាងជើង មកបង្ហាត់ក្រុមជម្រើសជាតិតេក្វាន់ដូ ITF គ្រូសាធារណរដ្ឋកូរ៉េ បង្ហាត់ក្រុមជម្រើសជាតិចំបាប់ និងគ្រូបរទេសឥណ្ឌូនេស៊ី បង្ហាត់ក្រុមជម្រើសជាតិវាយសី
- ផលិត និងចែកចាយទស្សនាវដ្ដីកីឡា ៦ លេខ ១២ ០០០ ក្បាល ។

### *ការងារបណ្ដុះបណ្ដាលគ្រូអប់រំកាយ និងមន្ត្រីជំនាញ*

ក្រសួងបាន៖

- បណ្ដុះបណ្ដាល និងប្រឡងបញ្ចប់គរុសិស្សជំនាន់ទី២២ ចំនួន ១៤៧ នាក់ ស្រី ៤៩ នាក់ និងកំពុងបណ្ដុះបណ្ដាលគរុសិស្សជំនាន់ទី២៣ ចំនួន ១៤៨ នាក់ ស្រី ៣៩ នាក់
- ប្រឡងជ្រើសរើសគរុសិស្សឱ្យចូលរៀនជំនាន់ទី២៤ ចំនួន ១៥០ នាក់ ស្រី ៣៣ នាក់
- កែលម្អកម្មវិធីសិក្សាអប់រំកាយនិងកីឡា សម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយនិងកីឡា និងបកប្រែឯកសារជាភាសាជាតិមានសៀវភៅ សំណុំសាច់ដុំ បទបញ្ញាលំហាត់បាល់ទាត់ កាយសរីរសាស្ត្រ វិធីសាស្ត្រកីឡា បទបញ្ញាបាល់ទះ បទបញ្ញាកីឡាដើរ និងបទបញ្ញាកីឡាអុក
- ពិនិត្យតាមដានការបង្ហាត់បង្រៀនរបស់គ្រូអប់រំកាយ និងកីឡា ២៣ ខេត្ត ជាលទ្ធផលបានកែលម្អចំណុចខ្វះខាតរបស់គ្រូបង្ហាត់នៅលើទីលាន
- ពិនិត្យតាមដានវាយតម្លៃគរុសិស្សអប់រំកាយនិងកីឡា ចុះធ្វើកម្មសិក្សានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡានៅរាជធានីភ្នំពេញ ៣២ សាលា។

### *ការលើកកម្ពស់ភាពជាអ្នកដឹកនាំគ្រប់គ្រង*

ក្រសួងបាន៖

- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រង និងមន្ត្រីបច្ចេកទេសអប់រំកាយនិងកីឡា នៅគ្រឹះស្ថានមធ្យមសិក្សា មានអ្នកចូលរួម ៦៣ នាក់ ស្រី ២០ នាក់
- បណ្ដុះបណ្ដាលមន្ត្រីជំនាញ ស្ដីពីការរៀបចំសមាគមក្លឹបកីឡានៅតាមគ្រឹះស្ថានមធ្យមសិក្សានៅខេត្តសៀមរាប ស្ទឹងត្រែង មណ្ឌលគិរី និងឧត្ដរមានជ័យ មានអ្នកចូលរួម ២៤០ នាក់ ស្រី ៣០ នាក់
- បញ្ជូនមន្ត្រីបច្ចេកទេស ១៣ នាក់ ស្រី ២ នាក់ ទៅទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន
- បំប៉នសមត្ថភាពមន្ត្រីជំនាញ និងមន្ត្រីគ្រប់គ្រងកីឡាជូនមន្ត្រីទទួលបន្ទុកកីឡា ៣ មណ្ឌលភូមិភាគគឺកំពង់ឆ្នាំង រតនគិរី និងតាកែវ មានអ្នកចូលរួម ១៤០ នាក់ ស្រី ១៦ នាក់

- បំប៉នសមត្ថភាពគ្រូបង្វឹក គ្រូជំនួយ និងអនុរក្សស្តីពីផែនការហាត់ហ្វឹកហ្វឺនមុនយុទ្ធនាការហាត់ហ្វឹកហ្វឺន មានអ្នកចូលរួម ៨០ នាក់ ស្រី ១១ នាក់
- បំប៉នមន្ត្រីសហព័ន្ធ អនុរក្ស គ្រូបង្វឹក គ្រូជំនួយ និងកីឡាករ កីឡាការិនីស្តីពីការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា មានអ្នកចូលរួម ៣៧២ នាក់ ស្រី ៧៣ នាក់
- បំប៉នសមត្ថភាពដល់មន្ត្រីកីឡា និងគ្រូអប់រំកាយនិងកីឡាស្តីពីការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា មានអ្នកចូលរួម ២៩៩ នាក់ ស្រី ២០ នាក់
- បំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា នៅខេត្តកែប បាត់ដំបង ព្រៃវែង និងកណ្តាល មានអ្នកចូលរួម ៥០០ នាក់ ស្រី ៥៦ នាក់
- ទទួលប្រតិភូជប៉ុន និងនិស្សិតជប៉ុនមកទស្សនកិច្ចសិក្សា ៤ លើក មានអ្នកចូលរួម ១២៥ នាក់ ស្រី ៣៧ នាក់
- បញ្ជូនមន្ត្រី ១ នាក់ ចូលរួមប្រជុំពិភាក្សាលើការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍកីឡាអត្តពលកម្មប្រចាំតំបន់ នៅឥណ្ឌូនេស៊ី
- បញ្ជូនមន្ត្រី ១ នាក់ ចូលរួមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រីកីឡាអត្តពលកម្មប្រចាំតំបន់ នៅឥណ្ឌូនេស៊ី
- សហការរៀបចំប្រណាំងទូកក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ នៅមុខព្រះបរមរាជវាំង
- សហការជាមួយអង្គការជនពិការកម្ពុជារៀបចំប្រគំតន្ត្រីស្តីពីការដាក់បញ្ចូលពិការភាពក្នុងផែនការអភិវឌ្ឍន៍ នៅពហុកីឡដ្ឋានជាតិ ។

## ខ. លទ្ធផលសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | ការអប់រំកាយនិងកីឡា | ជាក់ស្តែង | ចំណុចដៅ | ជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|
| | | ២០១៣-១៤ | 2014-15 | 2014-15 | |
| ១ | ចំនួនគ្រូអប់រំកាយនិងកីឡាបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ១៥០ | ១៥០ | ១៥០ | ↑ |
| ២ | ទីលានកីឡាចំនួន៤ ត្រូវបានកែលម្អ៖ | | | | |
| | - ពហុកីឡដ្ឋានជាតិ | | ១០០% | ៨០% | → |
| | - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | | | ចាប់ផ្តើម | ↓ |
| | - វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | | | ចាប់ផ្តើម | ↓ |
| | - កីឡដ្ឋានខេត្តសៀមរាប | | | ចាប់ផ្តើម | ↓ |
| ៣ | គ្រឹះស្ថានមធ្យមសិក្សាមាន៖ | | | | |
| | - ទីលានបាល់ទាត់ ១០ | | ២ | ២ | ↑ |

| | | | | | |
|---|---|---|---|---|---|
| | - ទីលានបាល់បោះ ១៥<br>- ទីលានបាល់ទះ ២០ | | ៣<br>៤ | ៣<br>៤ | ↑<br>↑ |
| ៤ | ចំនួនមេដាយមាសក្នុងការប្រកួតកីឡាស៊ីហ្គេម | ៤ | ៨ | ៨ | ↑ |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ ➔អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការអនុវត្តសកម្មភាព និងការប្រើប្រាស់ម៉ោងអប់រំកាយ និងកីឡានៅតាមសាលារៀនពុំទាន់បានអនុវត្តពេញលេញ
- គ្រឹះស្ថានសិក្សាមួយចំនួនពុំទាន់មានទីលានកីឡាសម្រាប់អនុវត្តសកម្មភាពអប់រំកាយ និងកីឡា
- កង្វះសៀវភៅអប់រំកាយ និងកីឡាសម្រាប់សាលាបឋមសិក្សា
- សកម្មភាពហាត់ប្រាណរបស់មហាជនមិនទាន់មានស្តង់ដារ
- ការងារកីឡាប្រពៃណីមិនទាន់បានប្រមូលផ្តុំ និងចងក្រង
- សហព័ន្ធកីឡាជាតិមួយចំនួនពុំទាន់មានភាពជាម្ចាស់ក្នុងការរៀបចំផែនការហាត់ហ្វឹកហ្វឺនជាប្រចាំ
- សម្ភារៈហ្វឹកហាត់ទីលានហាត់ហ្វឹកហ្វឺន និងប្រកួតមិនទាន់គ្រប់គ្រាន់ និងមិនទាន់ឆ្លើយតបតាមនិយាមបច្ចេកទេស
- កីឡាករ កីឡាការិនីចូលរួមប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិ មានសិទ្ធិផលទាបនៅឡើយធៀបនឹងសិទ្ធិផលនៃការប្រកួតកីឡាស៊ីហ្គេម
- ធនធានមនុស្សមិនទាន់ឆ្លើយតបតាមតម្រូវការ
- ការរៀបចំលិខិតបទដ្ឋានគតិយុត្តពុំទាន់ឆ្លើយតបតាមផែនការ
- ការចូលរួមសកម្មភាពកីឡារបស់ស្ត្រីនៅមានកម្រិត
- កង្វះអគារសិក្សា និងអន្តេវាសិកដ្ឋាន។

## ៣. ទិសដៅឆ្នាំសិក្សា ២០១៤-២០១៥

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ទាំងបញ្ហាប្រឈមតាមអនុវិស័យ និងបញ្ហាប្រឈមជាលក្ខណៈអន្តរអនុវិស័យ និងផ្អែកលើបទពិសោធកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន តាមទិសដៅដូចខាងក្រោម ៖

### ៣.១ ទិសដៅកំណែទម្រង់សំខាន់ៗ

#### *៣.១.១. ការពង្រឹងប្រព័ន្ធផែនការ*

- ប្រមូលស្ថិតិអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការ រួមទាំងជំរុញការប្រមូលស្ថិតិពីគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង និងស្ថាប័នពាក់ព័ន្ធ
- គាំទ្រក្រុមការងារតាមអនុវិស័យនីមួយៗ លើការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងដំណើរការក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត
- ពង្រឹងការងារផែនការ ស្ថិតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគម្រោងនានា។

#### *៣.១.២. ការងារវិមជ្ឈការ និងវិសហមជ្ឈការ*

- រៀបចំក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តគាំទ្រការផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពក្រុមការងារអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បង្កើនការយល់ដឹងពីការគ្រប់គ្រងផ្អែកលើគោលការណ៍អភិបាលកិច្ច និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ
- បញ្ជ្រាបទស្សនាទាននៃការដឹកនាំ និងគ្រប់គ្រងតាមវិធីសាស្ត្រអភិក្រមនៃការដឹកនាំ និងគ្រប់គ្រង។

#### *៣.១.៣. ការគ្រប់គ្រងបុគ្គលិក*

- សហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តវិធានការកំណែទម្រង់ការងារគ្រប់គ្រងមន្ត្រីរាជការ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ
- អនុវត្តអនុក្រឹត្យលេខ ៩៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមសម្រាប់បម្រើការតាមគ្រឹះស្ថានឧត្តមសិក្សា

- កសាង និងកែសម្រួលលិខិតបទដ្ឋានមួយចំនួនដើម្បីអនុវត្តគោលនយោបាយស្តីពីធនធានមនុស្ស ក្នុងវិស័យអប់រំ
- ពង្រីកវិសាលភាពអនុវត្តនិយាមថ្មីស្តីពីការប្រើប្រាស់បុគ្គលិកអប់រំ
- ដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃលទ្ធផលបំពេញការងាររបស់បុគ្គលិកអប់រំ។

### ៣.១.៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- កែសម្រួលប្លង់គណនី និងទម្រង់របាយការណ៍សម្រាប់ផ្ទៃក្នុងក្រសួង
- ជំរុញយន្តការ និងនីតិវិធីក្នុងការកែសម្រួលប្រកាសអន្តរក្រសួង និងអនុក្រឹត្យដែលពាក់ព័ន្ធនឹង នីតិវិធីចំណាយ
- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការអនុវត្តថវិកាឆ្នាំ២០១៥
- រៀបចំផែនការចំណាយរយៈពេលមធ្យម និងរយៈពេលវែង ២០១៦-២០២៥ និងគម្រោងថវិកា ឆ្នាំ ២០១៦
- បន្តរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា
- បំប៉នមន្ត្រីជំនាញ នាយកសាលា និងធ្វើបច្ចុប្បន្នភាពទិន្នន័យទ្រព្យសម្បត្តិរដ្ឋ
- ចេញប្រកាសអន្តរក្រសួងស្តីពីការផ្តល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមិនគិតពីសោហ៊ុយសេវាសុរិយោដី
- លើកកម្ពស់សមត្ថភាពមន្ត្រីសវនកម្ម និងពង្រឹងស្តង់ដាររបាយការណ៍សវនកម្មផ្ទៃក្នុង
- កំណត់ស្តង់ដារអធិការកិច្ចដោយប្រើប្រាស់សៀវភៅណែនាំនីតិវិធីអធិការកិច្ច
- បំប៉នសមត្ថភាពស្តីពីការយល់ដឹងនីតិវិធីស្រាវជ្រាវ និងដោះស្រាយទំនាស់។

## ៣.២ ទិសដៅតាមអនុវិស័យ

### ៣.២.១ អនុវិស័យ ការអប់រំកុមារតូច

- បង្កើនអត្រាចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ ៤ឆ្នាំ និង ៣ឆ្នាំ ឱ្យឆ្លើយតបនឹងចំណុចដៅ
- ពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសេវាអប់រំកុមារតូចផ្តោតលើ ការកសាង ជួសជុលសំណង់ អគារសិក្សា និងកែលម្អបរិស្ថានសិក្សាឱ្យមានលក្ខណៈស្តង់ដារ និងស្របតាមនិយាមគរុកោសល្យ
- ពង្រីកកម្មវិធីអប់រំមាតាបិតាផ្តោតទៅលើសេវាអាហារូបត្ថម្ភ ការលើកកម្ពស់សុខភាព អនាម័យ ការ ថែទាំ និងការប្រើប្រាស់សេវាសុខាភិបាល
- ផ្តល់ថ្នាំទម្លាក់ព្រូន ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា ដោយសហការ ជាមួយក្រសួងសុខាភិបាល ផ្តល់ការអប់រំសុខភាព អនាម័យ សុខភាពមាត់-ធ្មេញ អាហារូបត្ថម្ភ និងសេវាសុខាភិបាលដទៃទៀត
- ផលិត និងផ្សព្វផ្សាយវីដេអូសម្រាប់កម្មវិធីអប់រំមាតាបិតា
- ពង្រឹងយន្តការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នា និងការអប់រំពហុភាសាផ្អែកមត្តេយ្យសិក្សា

- អភិវឌ្ឍកម្មវិធីសិក្សា ពង្រឹងសមត្ថភាពគ្រប់គ្រងដល់នាយក ឬនាយិកាមត្តេយ្យសិក្សា និងបំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ ព្រមទាំងគ្រូមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍
- ផ្តល់គ្រូបង្រៀនតាមឯកទេស និងក្របខណ្ឌជ្រើសរើសគ្រូមត្តេយ្យសិក្សា
- បង្កើនសមត្ថភាព និងគុណវុឌ្ឍិគ្រូឧទ្ទេស
- បំពាក់សម្ភារបរិក្ខារ ព័ត៌មានវិទ្យាជាបណ្តើរៗដល់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឱ្យទទួលបានក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បំប៉នសមត្ថភាព ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់នាយក នាយិកាសាលាមត្តេយ្យសិក្សា
- ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាព ការងារបណ្តុះបណ្តាលគ្រូបង្រៀន និងផ្សព្វផ្សាយកម្រងព្រឹត្តិបត្រវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀន
- បង្កើនគុណវុឌ្ឍិគ្រូមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទៅជាគ្រូកម្រិតអប់រំមូលដ្ឋាន
- ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលការសិក្សាស្រាវជ្រាវ និងវិភាគសម្រាប់អនុវិស័យអប់រំកុមារតូច
- កសាងលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រអនុវិស័យអប់រំកុមារតូច
- កសាងក្របខណ្ឌលទ្ធផល នៃផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១៤-២០១៨
- ជំរុញការអនុវត្តយន្តការគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច។

### *៣.២.២ អនុវិស័យ ការអប់រំបឋមសិក្សា*

- បង្កើនការប្រមូលកុមារចូលរៀននៅបឋមសិក្សា ជាពិសេសក្រុមកុមារបាត់បង់ឱកាស
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា
- កែលម្អកម្មវិធីសិក្សាសម្រាប់បឋមសិក្សា
- ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេសនៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត លើផ្នែកវិធីសាស្ត្របង្រៀន ជាពិសេសគណិតវិទ្យា និងវិទ្យាសាស្ត្រ
- ជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត
- ផ្គត់ផ្គង់គ្រូឧទ្ទេសដល់សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងទប់ស្កាត់គ្រូឧទ្ទេសផ្លាស់ចេញ តាមរយៈ ប្រព័ន្ធលើកទឹកចិត្តសមស្រប
- បំប៉នសមត្ថភាពបង្រៀនដល់គ្រូបឋមសិក្សា (ការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ការបង្រៀនសិស្សមានបញ្ហាស្តាប់ និងមើល)

- ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន និងផ្សព្វផ្សាយកម្រងព្រឹត្តិបត្រវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍឯកសារគតិយុត្តស្តីពីសុខភាពសិក្សា (ការពិនិត្យសុខភាព និងកាយសម្បទា សារាចរណែនាំស្តីពីរចនាសម្ព័ន្ធសុខភាពសិក្សានៅថ្នាក់ក្រោមជាតិ អនុក្រឹត្យស្តីពីសុខភាពសិក្សា)
- ផ្តល់ថ្នាំទម្លាក់ព្រូន ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា ពិសេសសិស្សថ្នាក់ទី១ នៅខេត្តកំពត និងកំពង់ឆ្នាំង ដោយសហការជាមួយក្រសួងសុខាភិបាល
- ផ្តល់ប្រអប់សង្គ្រោះបឋម និងបំប៉នពីវិធីប្រើប្រាស់នៅតាមគ្រឹះស្ថានសិក្សា
- ជំរុញការកសាងកន្លែងលាងសម្អាតដៃ ផ្គត់ផ្គង់ទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ
- ផ្តល់ការអប់រំសុខភាព អាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ សុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រុនចាញ់ គ្រុនឈាម ផ្តាសាយ ដង្កូវព្រូន សុខភាពភ្នែក សុខភាពមាត់-ធ្មេញ និងការបង្ការគ្រោះថ្នាក់នានា
- ពង្រឹងភាពជាអ្នកដឹកនាំនិងគ្រប់គ្រងនៅកម្រិតសាលារៀន។

### ៣.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

- ទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្ស
- ពង្រីកការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅសាលាមធ្យមសិក្សាបឋមភូមិ
- ជំរុញការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅសាលាមធ្យមសិក្សា
- អភិវឌ្ឍសមត្ថភាពគ្រូគណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី១២
- ធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាចិត្តគរុកោសល្យ
- ផ្គត់ផ្គង់គ្រូឧទ្ទេសតាមឯកទេសនិងបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន និងផ្សព្វផ្សាយកម្រងព្រឹត្តិបត្រវាយតម្លៃការងារបណ្តុះបណ្តាលគ្រូបង្រៀន
- ពង្រឹងការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន
- អភិវឌ្ឍគន្លងអាជីពគ្រូបង្រៀន
- ផលិត និងផ្សព្វផ្សាយវីដេអូស្តីពីការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ
- អភិវឌ្ឍសមត្ថភាពនាយកសាលាលើបំណិនដឹកនាំ គ្រប់គ្រង និងប្រាស្រ័យទាក់ទង
- អភិវឌ្ឍកម្មវិធីសិក្សា ស្តង់ដារ និងសៀវភៅសិក្សាគោលចំណេះទូទៅ
- អភិវឌ្ឍស្តង់ដារកម្មវិធីសិក្សាអប់រំបច្ចេកទេស ៥ជំនាញ រួមមាន មេកានិច អគ្គិសនី អេឡិចត្រូនិចកសិកម្ម និងគណនេយ្យហិរញ្ញវត្ថុ
- បន្តសហការជាមួយដៃគូអភិវឌ្ឍផ្នែកឯកជន និងអ្នកពាក់ព័ន្ធរៀបចំកម្មវិធីសិក្សាជំនាញផ្សេងៗបន្ថែមទៀត ដើម្បីឆ្លើយតបនឹងគោលដៅថ្មី និងទីផ្សារការងារក្នុងតំបន់
- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន

- ផ្តល់ថ្នាំទម្លាក់ព្រូនពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា
- ជំរុញការកសាងកន្លែងលាងសម្អាតដៃ ផ្គត់ផ្គង់ទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ
- ផ្តល់ការអប់រំសុខភាព អាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ សុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រុនចាញ់ គ្រុនឈាម ផ្តាសាយ ដង្កូវព្រូន សុខភាពភ្នែក និងការបង្ការគ្រោះថ្នាក់នានា
- សាងសង់ និងជួសជុលអគារសិក្សា ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់
- ពង្រាយគ្រូឯកទេស ដើម្បីឆ្លើយតបនឹងតម្រូវការជំនាញឯកទេស
- សាងសង់ផ្ទះគ្រូបង្រៀននៅតំបន់ជួបការលំបាក
- បង្កើតវិទ្យាស្ថានសម្រាប់បណ្តុះបណ្តាលគ្រូផ្នែកអប់រំបច្ចេកទេស។

### *៣.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា*

- កសាងអនុក្រឹត្យស្តីពីការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំស្តង់ដារ និងគោលការណ៍ណែនាំអំពីការធានាគុណភាពផ្ទៃក្នុង
- ជំរុញការសិក្សាស្តីពីលទ្ធភាពពង្រីកកម្មវិធីផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា
- ជំរុញការអប់រំសុខភាព ការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងសេវាសុខាភិបាលដទៃទៀត
- រៀបចំគោលនយោបាយស្តីពីអាហារូបករណ៍ ការឧបត្ថម្ភធន ប្រព័ន្ធប្រាក់កម្ចីដល់និស្សិតនៅឧត្តមសិក្សា
- រៀបចំគោលការណ៍ និងយន្តការលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវនៅឧត្តមសិក្សា
- ជំរុញការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា
- ជំរុញការអនុវត្តព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ
- ជំរុញការអនុវត្តស្តង់ដារជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- រៀបចំសៀវភៅណែនាំស្តីពីការទទួលស្គាល់គុណភាពអប់រំនៅឧត្តមសិក្សា
- បន្តចុះវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។

### *៣.២.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ*

- បើកយុទ្ធនាការអក្ខរកម្មជាតិ ឆ្នាំ ២០១៥
- ពង្រីកវិសាលភាពកម្មវិធីសមមូលបឋមសិក្សា
- ពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ ឱ្យឆ្លើយតបទៅនឹងតម្រូវការសង្គម

- រៀបចំលក្ខខណ្ឌតម្រូវក្នុងការបើកមជ្ឈមណ្ឌលសិក្សាសហគមន៍
- ផ្តល់ការអប់រំសុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រុនចាញ់ គ្រុនឈាម និងការបង្ការគ្រោះថ្នាក់នានា
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើនថវិកាឧបត្ថម្ភគ្រូកម្មវិធីអប់រំក្រៅប្រព័ន្ធ។

### ៣.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

- រៀបចំលិខិតបទដ្ឋានគតិយុត្តបង្កើតក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន និងអគ្គលេខាធិការដ្ឋាន
- រៀបចំបង្កើតផែនការជាតិដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន
- រៀបចំលិខិតបទដ្ឋានគតិយុត្តបង្កើតក្រុមប្រឹក្សាយុវជនក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ ឃុំ
- បង្កើតកម្មវិធីបណ្តុះបណ្តាល និងបំប៉នសមត្ថភាពរយៈពេលខ្លី និងមធ្យមដល់បុគ្គលិកមន្ត្រីយុវជន
- ផ្តល់វគ្គបណ្តុះបណ្តាលយុវជនស្ម័គ្រចិត្តថ្នាក់ស្រុក ៥០ ស្រុក
- ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌលយុវជនរាជធានី ខេត្តចំនួន២០
- ជំរុញការរៀបចំអភិវឌ្ឍមជ្ឈមណ្ឌលយុវជន
- ផ្តល់ការអប់រំសុខភាពបន្តពូជ សុខភាពផ្លូវភេទមេរោគអេដស៍ ជំងឺអេដស៍ គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់ គ្រុនចាញ់ គ្រុនឈាម និងការបង្ការគ្រោះថ្នាក់នានា
- បន្តសហការជាមួយដៃគូអភិវឌ្ឍលើការអភិវឌ្ឍយុវជន និងមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត លើការងារស្ម័គ្រចិត្ត ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញទន់ និងបំណិន
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សាយុវជនស្ម័គ្រចិត្តដើម្បីចែករំលែក និងផ្លាស់ប្តូរបទពិសោធលើការងារស្ម័គ្រចិត្ត និងស្វែងយល់ពីការថែរក្សាមរតកវប្បធម៌ខ្មែរ
- អភិវឌ្ឍឯកសារផែនការសកម្មភាព និងតារាងម៉ាទ្រិក សម្រាប់គោលដៅនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញទន់នៅតាមមជ្ឈមណ្ឌលយុវជន និងការបណ្តុះបណ្តាលយុវជនស្ម័គ្រចិត្ត
- រៀបចំវេទិកាជាតិស្តីពីការងារស្ម័គ្រចិត្តនៅកម្ពុជា និងរៀបចំទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត
- រៀបចំវេទិកាយុវជនស្តីពីភាពជាអ្នកដឹកនាំ និងយុវជន។

### ៣.២.៧ អនុវិស័យ ការអប់រំកាយ និងកីឡា

- បន្តរៀបចំប្រកាសស្តីពីការគ្រប់គ្រងកីឡាមហាជន និងកីឡាប្រពៃណី
- ជំរុញការអនុវត្តកម្មវិធីសិក្សាអប់រំកាយនិងកីឡានៅគ្រឹះស្ថានបឋម និងមធ្យមសិក្សាឱ្យបានពេញលេញ

- ជំរុញបង្កើតសមាគមកីឡានៅតាមគ្រឹះស្ថាសិក្សាសាធារណៈ និងឯកជន
- បន្តកែលម្អកម្មវិធីគោលបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- បន្តស្រាវជ្រាវ និងចងក្រងឯកសារកីឡាប្រពៃណីជាតិ
- រៀបចំសេចក្តីណែនាំកម្មវិធីប្រកួតកីឡា និងការប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេស និងថ្នាក់រាជធានី ខេត្ត នៅគ្រឹះស្ថានសិក្សាទាំង ៣ កម្រិត
- ជំរុញការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពកីឡា
- ពង្រឹងរចនាសម្ព័ន្ធសហព័ន្ធកីឡាសិស្ស និស្សិត និងសហព័ន្ធកីឡាជាតិ
- ជំរុញការបោះពុម្ពសៀវភៅអប់រំកាយ និងកីឡាសម្រាប់គ្រឹះស្ថានបឋមសិក្សា
- ផលិត និងចែកចាយទស្សនាវដ្តីកីឡាចំនួន ៦ លេខ
- បន្តការធ្វើតេស្តកាយសម្បទាកុមារអាយុ៦ ដល់ ១២ឆ្នាំ នៅរាជធានី ខេត្ត
- បំប៉នសមត្ថភាពមន្ត្រីជំនាញកីឡា មន្ត្រីគ្រប់គ្រងកីឡា និងគ្រូអប់រំកាយនិងកីឡាគ្រប់កម្រិត
- ប្រមូលផ្តុំក្រុមជម្រើសជាតិ ២៣ ប្រភេទកីឡា ចំនួន ៣៩២ នាក់ មកហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេម និងប្រកួតជាលក្ខណៈអន្តរជាតិនានា
- បន្តបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២៣ ជំនាន់ទី២៤ និងធ្វើការប្រឡងបញ្ចប់ការសិក្សាគរុសិស្សជំនាន់ទី២៣ និងប្រឡងជ្រើសរើសជំនាន់ទី២៥
- បំពាក់សម្ភារបរិក្ខារ កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធទីលានកីឡា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យស្របតាមនិយាមបច្ចេកទេស
- កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា និងអន្តេវាសិកដ្ឋានរបស់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា
- ផ្តល់ការអប់រំសុខភាពបន្តពូជ សុខភាពផ្លូវភេទ មេរោគអេដស៍ ជំងឺអេដស៍ គ្រឿងញៀន គ្រឿងស្រវឹង ថ្នាំជក់
- ជំរុញអភិបាលកិច្ចដល់សមាគមកីឡា និងសហព័ន្ធកីឡាជាតិ។

## ៣.៣ បញ្ហាប្រឈម និងទិសដៅឆ្លងអនុវិស័យ

### *៣.៣.១. ការងារអភិវឌ្ឍកម្មវិធីសិក្សា*

បញ្ហាប្រឈម

- កម្មវិធីសិក្សាមិនទាន់ឆ្លើយតបទៅនឹងទីផ្សារពលកម្ម
- បណ្ណាល័យសាលារៀនភាគច្រើនបើកដំណើរការតែមួយពេល និងមិនស្របតាមស្តង់ដារ
- ខ្វះឯកសារអានបន្ថែម សម្រាប់សកម្មភាពជំរុញការអានតាមសាលារៀន

ទិសដៅ

- រៀបចំព្រឹត្តិការណ៍ជំរុញការអានតាមសាលាបឋមសិក្សា

- ពិគ្រោះយោបល់លើក្របខណ្ឌកម្មវិធីសិក្សា និងកែលម្អកម្មវិធីសិក្សាលម្អិតកម្រិតអប់រំមូលដ្ឋាន គ្រប់មុខវិជ្ជា
- រៀបចំទិវាជាតិអំណាន និងបង្កើតបណ្ណាល័យឈានមុខតាមរាជធានី ខេត្ត។

### ៣.៣.២. ការងាររដ្ឋបាល

បញ្ហាប្រឈម

- ការគ្រប់គ្រងលិខិតរដ្ឋបាល ( ចរាចរលិខិត ) មិនទាន់រលូន
- ការផ្តល់គ្រឿងឥស្សរិយយសឆ្នាំ២០១២ ឆ្នាំ២០១៣ និងឆ្នាំ២០១៤ មានភាពយឺតយ៉ាវ។

ទិសដៅ

- ពង្រឹងការគ្រប់គ្រងលិខិតរដ្ឋបាល ពិសេសចរាចរលិខិត
- ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលអប់រំ និងបណ្ណសារ។

### ៣.៣.៣. ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍

បញ្ហាប្រឈម

- ការគ្រប់គ្រងតួលេខនិស្សិតចេញ និស្សិតកំពុងសិក្សា និងនិស្សិតបញ្ចប់ការសិក្សាពីបណ្តាស្ថានទូតបរទេសប្រចាំនៅកម្ពុជាមិនទាន់រលូន
- ការងារទាំងស្រុងដែលជាបន្ទុករបស់ទីប្រឹក្សាទទួលបន្ទុកកិច្ចការប្រេង់កូហ្វូនី ត្រូវបានរ៉ាប់រងដោយការិយាល័យ ដោយមិនមានការគាំទ្រនិងលើកទឹកចិត្តនៅក្នុងកិច្ចការទាំងនោះទេ
- កង្វះធនធានសម្រាប់រ៉ាប់រងការងារបណ្តុះបណ្តាល ធ្វើឱ្យមានការយឺតយ៉ាវចំពោះការអនុវត្តគម្រោងមួយចំនួនដែលឧបត្ថម្ភថវិកាដោយអង្គការអភិវឌ្ឍជាដៃគូ។

ទិសដៅ

- បន្តពង្រឹងការគ្រប់គ្រងនិស្សិតអាហារូបករណ៍ក្នុង និងក្រៅប្រទេសតាមប្រព័ន្ធព័ត៌មានវិទ្យា
- ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍលើការរៀន និងបង្រៀនភាសាបារាំងតាមរយៈការស្វែងរកអាហារូបករណ៍ និងសម្រាប់គ្រូបង្រៀន និងសិស្ស-និស្សិតដែលប្រើប្រាស់ភាសាបារាំង
- រៀបចំគោលនយោបាយសិក្សាភាសាបរទេសឱ្យបានច្បាស់លាស់។

### ៣.៣.៤.ការងារព័ត៌មាន និងកិច្ចការអាស៊ាន

បញ្ហាប្រឈម

- សេចក្តីព្រាងគោលនយោបាយសិក្សាពីចម្ងាយមិនទាន់បានសម្រេច ហើយការងារគ្រប់គ្រងការអប់រំមិនផ្លូវការនៅមិនទាន់បានអនុវត្តបានល្អនៅឡើយ

- ម៉ាស៊ីនថតនិងកាត់តរូបភាព វីដេអូព្រមទាំងសម្ភារសម្រាប់បម្រើឱ្យការងារផលិត និងផ្សព្វផ្សាយព័ត៌មានអប់រំយុវជន និងកីឡាមិនទាន់ឆ្លើយតបទៅនឹងបច្ចេកវិទ្យាទំនើបនៅឡើយ
- កិច្ចសហការចូលរួមដាក់ឯកសារ និងទិន្នន័យបញ្ចូលលើគេហទំព័រក្រសួងពីអង្គភាពពាក់ព័ន្ធនៅមានកម្រិតដែលជាហេតុធ្វើឱ្យក្រុមការងារជំនាញចំណាយពេលវេលាច្រើនដើម្បីជួយផ្នែកបច្ចេកទេស។

ទិសដៅ

- បន្តរៀបចំសេចក្តីព្រាងគោលនយោបាយសិក្សាពីចម្ងាយ និងពង្រឹងយន្តការគ្រប់គ្រងការអប់រំមិនផ្លូវការ
- ចុះសហការ និងសម្របសម្រួលបច្ចេកទេសក្នុងការប្រើប្រាស់អ៊ីនធឺណិត-អ៊ីមែលផ្លូវការក្រសួង និងការធ្វើបច្ចុប្បន្នភាពព័ត៌មានលើគេហទំព័រក្រសួងនៅថ្នាក់ក្រោមជាតិឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព
- ផ្តល់និងបំពាក់សម្ភារបរិក្ខាស្របតាមបច្ចេកវិទ្យាទំនើបសម្រាប់បំរើដល់ការផលិត និងផ្សព្វផ្សាយព័ត៌មានអប់រំ យុវជន និងកីឡា។

### ៣.៣.៥.ការងារសំណង់សិក្សា

បញ្ហាប្រឈម

- លទ្ធភាពជួសជុលអគារសិក្សាដែលមានសភាពទ្រុឌទ្រោម នៅមានកម្រិត
- ដំណោះស្រាយសំណើសុំសាងសង់និងជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំពុំទាន់បានគ្រប់នៅឡើយ
- ការគ្រប់គ្រងថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំតាមគ្រឹះស្ថានសិក្សានិងតាមអង្គភាពក្រោមឱវាទនៅមានកម្រិត។

ទិសដៅ

- បន្តជំរុញការងារសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំ តាមបណ្តា រាជធានី ខេត្ត
- បន្តលើកកម្ពស់សមត្ថភាព មន្ត្រីគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ តាមបណ្តាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន
- សិក្សាប្លង់ស្តង់ដាតាមអគារសិក្សតាមប្រភេទ (រឹងមាំយូរអង្វែង ជាមធ្យម បណ្តោះអាសន្ន បណ្តែតទឹក.......)។

### ៣.៣.៦. ការងារបោះពុម្ព និងចែកផ្សាយ

ទិសដៅ

- អភិវឌ្ឍសៀវភៅសិក្សាគោល ហ្វឹកហាត់ អំណានបន្ថែម និងសម្ភារឧបទេសផ្សេងៗ
- បោះពុម្ពសៀវភៅសិក្សាគោល ហ្វឹកហាត់ និងអំណានបន្ថែម
- ដឹកជញ្ជូនសៀវភៅសិក្សាគោលជូនសាលារៀនទូទាំងប្រទេស។

### ៣.៣.៧. ការងារធានាគុណភាពអប់រំ

បញ្ហាប្រឈម

- មន្ត្រីពុំទាន់ទទួលបានការបណ្តុះបណ្តាលឱ្យសមស្របតាមបន្ទុកការងារ
- បរិមាណមន្ត្រីជំនាញ និងអធិការនៅពុំទាន់គ្រប់គ្រាន់
- ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់ចុះបំពេញការងារ

ទិសដៅ

- ផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ លើមុខវិជ្ជា ភាសាខ្មែរ រូបវិទ្យា និងគណិតវិទ្យាដល់មន្ត្រីអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំង ២៥ រាជធានី ខេត្ត
- រៀបចំដំណើរការតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣
- ពង្រឹងការងារធានាគុណភាពអប់រំ និងអធិការកិច្ច តាមរាជធានី ខេត្ត។

## ៤. សេចក្តីសន្និដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡា សាទរនឹងសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃកំណែទម្រង់សំខាន់ៗ និងវឌ្ឍនភាពតាមអនុវិស័យទាំង ៧។

ក្រសួងបានយកចិត្តទុកដាក់ធ្វើកំណែទម្រង់ទូលំទូលាយ និងតាមអាទិភាពតាមរយៈការអនុវត្តសកម្មភាពគោលនយោបាយ ការផ្តោតលើការសម្រេចសូចនាករស្នូល ការឆ្លើយតបនឹងកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលដូចជា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសវឌ្ឍនភាពរបស់កំណែទម្រង់ ៨ ចំណុច ដែលក្រសួងបានដាក់ចេញក្នុងអាណត្តិទី៥។ ទោះយ៉ាងណា ក្រសួងនឹងបន្តយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានាក្នុងដំណាក់កាលកំណែទម្រង់ ដើម្បីធ្វើឱ្យសម្រេចលទ្ធផលនៅពេលខាងមុខ។

អនុវិស័យអប់រំកុមារតូចបានបង្ហាញពី វឌ្ឍនភាពក្នុងការពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពជាពិសេសមត្តេយ្យសិក្សាសហគមន៍ ការកសាងឯកសារគោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ ទោះយ៉ាងណា ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនក្របខណ្ឌគ្រូមត្តេយ្យសិក្សា និងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យបឋមសិក្សាបានបង្ហាញ ពីវឌ្ឍនភាពក្នុងការយកចិត្តទុកដាក់ប្រមូលកុមារជួបការលំបាកឱ្យបានចូលរៀនតាមកម្មវិធី និងអន្តរាគមន៍ពិសេស ការលើកកម្ពស់បំណិនអំណាននៅកម្រិតដំបូងនៃបឋមសិក្សា និងការទប់ស្កាត់ការបោះបង់ការសិក្សា។ ទោះយ៉ាងណា ការបន្តផ្តល់អន្តរាគមន៍ដល់ក្រុមកុមារជួបការលំបាក ការលើកកម្ពស់បំណិនអំណាន និងគណិតវិទ្យានៅកម្រិតដំបូងនៃបឋមសិក្សា និងការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅសាលារៀននឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសបានបង្ហាញពីវឌ្ឍនភាពក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សា ការពង្រឹងយន្តការវាយតម្លៃលទ្ធផលសិក្សា និងការប្រឡងថ្នាក់ជាតិ។ ទោះយ៉ាងណា ការពង្រីកសេវាមធ្យមសិក្សា ការអនុវត្តប្រព័ន្ធរំលឹកជាមុនដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ការរៀបចំសាលាមធ្យមសិក្សាគំរូ និងការពង្រឹងដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យអប់រំក្រៅប្រព័ន្ធបានបង្ហាញពី វឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធគ្រប់រូបភាព។ ទោះយ៉ាងណា ការបង្កើនថ្នាក់អក្ខរកម្មវិជ្ជាជីវៈ និងពង្រឹងដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍នឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យឧត្តមសិក្សាបានបង្ហាញពី វឌ្ឍនភាពក្នុងការអភិវឌ្ឍសមត្ថភាពឧត្តមសិក្សាដូចជា ការរៀបចំចក្ខុវិស័យឧត្តមសិក្សា ២០៣០ ការលើកកម្ពស់អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា និងសមត្ថភាពមន្ត្រីឧត្តមសិក្សា។ ទោះយ៉ាងណា ការបង្កើនចំនួននិស្សិតចូលរៀនមុខវិជ្ជាអាទិភាព ការធានាគុណភាពផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សានឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យអភិវឌ្ឍយុវជនបានបង្ហាញពី វឌ្ឍនភាពក្នុងការកែលម្អរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារ និងយុវជន ការបណ្តុះបណ្តាលជំនាញរឹងនិងជំនាញទន់។ ទោះយ៉ាងណា ការបណ្តុះបណ្តាលជំនាញទន់ដល់យុវជននឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

អនុវិស័យអប់រំកាយនិងកីឡាបានបង្ហាញពី វឌ្ឍនភាពនៃសិទ្ធិផលកីឡារបស់កម្ពុជានៅថ្នាក់តំបន់និងសកលលោក ការជំរុញសកម្មភាពអប់រំកាយនិងកីឡានៅតាមសាលារៀន និងកីឡាមហាជន។ ទោះយ៉ាងណា ការបន្តលើកកម្ពស់សិទ្ធិផលកីឡាកម្ពុជានៅថ្នាក់តំបន់និងសកលលោក ការកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមសាលារៀន នឹងត្រូវយកចិត្តទុកដាក់បន្ថែមទៀត។

ដំណើរការរៀបចំសន្និបាតបូកសរុបសមិទ្ធផលអប់រំ យុវជន និងកីឡា បានផ្តល់ជាបទពិសោធដល់ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលមានលក្ខណៈជាប្រព័ន្ធផ្តោតលើលទ្ធផល និងតាមបែបអនុវិស័យ។

ការធានាបាននូវសមធម៌ គុណភាព និងភាពឆ្លើយតបនៃការអប់រំ គឺជាតួនាទីដ៏មានសារៈសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រទេសជាតិក្រោមពាក្យស្លោក "មានធនធានមនុស្សទើបមានការអភិវឌ្ឍ"។ ដូច្នេះ សមិទ្ធផលដែលបានរៀបរាប់មកខាងលើ ពិតជាបានបញ្ជាក់យ៉ាងច្បាស់ថា យើងមានការទទួលខុសត្រូវខ្ពស់ចំពោះតួនាទី និងភារកិច្ចរបស់យើងទាំងអស់គ្នា គឺសំដៅធ្វើយ៉ាងណាឱ្យដំណើរការអភិវឌ្ឍវិស័យអប់រំមានភាពជោគជ័យ ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០១៨ និងស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ ការចូលរួមពីសំណាក់មន្ត្រីអប់រំគ្រប់

លំដាប់ថ្នាក់ ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ក្រោមការដឹកនាំប្រកបដោយភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបង្កើតជាក្តីសង្ឃឹម និង ជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា សម្រាប់អនាគតកុមារ និងយុវជនកម្ពុជា។

# ផ្នែកទី ២

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤

| ល.រ | នាយកដ្ឋាន | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនទាន់អនុវត្ត |
|---|---|---|---|---|---|
| ១ | នាយកដ្ឋានអប់រំកុមារតូច | ៧៩ | ៣៩ | ០ | ៤០ |
| ២ | នាយកដ្ឋានបឋមសិក្សា | ៧៥ | ៤៦ | ១៦ | ១៣ |
| ៣ | នាយកដ្ឋានមធ្យមសិក្សា | ២៨ | ២៥ | ១ | ២ |
| ៤ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | ៦ | ៦ | ០ | ០ |
| ៥ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១១ | ១១ | ០ | 0 |
| ៦ | នាយកដ្ឋានឧត្តមសិក្សា | ៣៨ | ២៨ | ៣ | ៧ |
| ៧ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ៩ | ៩ | ០ | ០ |
| ៨ | នាយកដ្ឋានយុវជន | ៥ | ៥ | ០ | ០ |
| ៩ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | ៩ | ៩ | ០ | ០ |
| ១០ | នា.អប់រំកាយនិងកីឡាសិស្ស និស្សិត | ៣ | ៣ | ០ | ០ |
| ១១ | នាយកដ្ឋានអប់រំកាយនិងកីឡា | ៣ | ៣ | ០ | ០ |
| ១២ | នាយកដ្ឋានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៨ | ៨ | ០ | ០ |
| ១៣ | វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | ៧ | ៧ | ០ | ០ |
| ១៤ | នាយកដ្ឋានផែនការ | ២៥ | ២៤ | ១ | ០ |
| ១៥ | នាយកដ្ឋានបុគ្គលិក | ៣០ | ២៨ | ០ | ២ |
| ១៦ | នាយកដ្ឋាននីតិកម្ម | ១៥ | ១០ | ០ | ៥ |
| ១៧ | នាយកដ្ឋានហិរញ្ញវត្ថុ | ១០ | ១០ | ០ | ០ |
| ១៨ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | ២៧ | ១៧ | ៣ | ៧ |
| ១៩ | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | ១៨ | ១៦ | ១ | ១ |
| ២០ | នាយកដ្ឋានសុខភាពសិក្សា | ៣៦ | ៣១ | ២ | ៣ |
| ២១ | នាយកដ្ឋានរដ្ឋបាល | ២ | ២ | ០ | ០ |
| ២២ | នា.ទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ | ៥ | ៥ | ០ | ០ |
| ២៣ | នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | ២០ | ១៥ | ០ | ៥ |
| ២៤ | នា. គ្រប់គ្រងសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ | ៦ | ៦ | ០ | ០ |
| ២៥ | នាយកដ្ឋានសំណង់ | ១៧ | ៦ | ៩ | ២ |
| ២៦ | គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | ៦ | ៦ | ០ | ០ |
| ២៧ | នាយកដ្ឋានធានាគុណភាពអប់រំ | ៨ | ៥ | ២ | ១ |
| ២៨ | អធិការដ្ឋានរដ្ឋបាលនិង ហិរញ្ញវត្ថុ | ៤ | ៤ | ០ | ០ |
| ២៩ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៦ | ២ | ០ | ៤ |
| | សរុប | ៥១៦ | ៣៨៦ | ៣៨ | ៩២ |

## ឧបសម្ព័ន្ធទី២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៣-២០១៤

| ល.រ | នាយកដ្ឋាន | សកម្មភាព សរុប | បាន បញ្ចប់ | កំពុង អនុវត្ត | មិនទាន់ អនុវត្ត |
|---|---|---|---|---|---|
| ១ | ការងារអប់រំកុមារតូច | ៦ | ២ | ៣ | ១ |
| ២ | ការងារបឋមសិក្សា | ៦ | ៣ | ៣ | ០ |
| ៣ | ការងារមធ្យមសិក្សា | ៧ | ២ | ៥ | ០ |
| ៤ | ការងារតម្រង់ទិសវិជ្ជាជីវៈ | ៦ | ៤ | ១ | ១ |
| ៥ | ការងារអប់រំក្រៅប្រព័ន្ធ | ៥ | ៣ | ១ | ១ |
| ៦ | ការងារឧត្តមសិក្សា | ១២ | ៦ | ៥ | ១ |
| ៧ | ការងារស្រាវជ្រាវវិទ្យាសាស្ត្រ | ៤ | ១ | ៣ | ០ |
| ៨ | ការងារយុវជន | ៥ | ០ | ៥ | ០ |
| ៩ | ការងារគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | ៤ | ៤ | ០ | ០ |
| ១០ | ការងារអប់រំកាយនិងកីឡាសិស្ស-និស្សិត | ១១ | ១០ | ១ | ០ |
| ១១ | ការងារអប់រំកាយនិងកីឡា | ៦ | ២ | ៤ | ០ |
| ១២ | ការងារមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា | ៣ | ៣ | ០ | ០ |
| ១៣ | ការងារវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | ៦ | ៤ | ២ | ០ |
| ១៤ | ការងារផែនការ | ៧ | ៧ | ០ | ០ |
| ១៥ | ការងារបុគ្គលិក | ៨ | ៧ | ០ | ១ |
| ១៦ | ការងារនីតិកម្ម | ៦ | ៥ | ១ | ០ |
| ១៧ | ការងារហិរញ្ញវត្ថុ | ៥ | ២ | ៣ | ០ |
| ១៨ | ការងារអភិវឌ្ឍកម្មវិធីសិក្សា | ៦ | ២ | ១ | ៣ |
| ១៩ | ការងារបណ្តុះបណ្តាលនិងវិក្រឹតការ | ៧ | ៧ | ០ | ០ |
| ២០ | ការងារសុខភាពសិក្សា | ៤ | ៣ | ១ | ០ |
| ២១ | ការងាររដ្ឋបាល | ៣ | ៣ | ០ | ០ |
| ២២ | ការងារទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ | ៣ | ០ | ២ | ១ |
| ២៣ | ការងារព័ត៌មាននិងកិច្ចការអាស៊ាន | ៦ | ៤ | ០ | ២ |
| ២៤ | ការងារគ្រប់គ្រងសម្ភារៈនិងទ្រព្យសម្បត្តិ | ៥ | ២ | ៣ | ០ |
| ២៥ | ការងារសំណង់សិក្សា | ៥ | ០ | ៥ | ០ |
| ២៦ | ការងារបោះពុម្ពនិងចែកផ្សាយ | ៦ | ៦ | ០ | ០ |
| ២៧ | ការងារធានាគុណភាពអប់រំ | ៥ | ៣ | ២ | ០ |
| ២៨ | ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ៤ | ៤ | ០ | ០ |
| ២៩ | ការងារសវនកម្មផ្ទៃក្នុង | ៣ | ១ | ០ | ២ |
| | **សរុប** | **១៦៤** | **១០០** | **៥១** | **១៣** |

## ឧបសម្ព័ន្ធទី៣ ៖ វឌ្ឍនភាពតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយឆ្នាំ២០១៤

| អនុវិស័យ ការអប់រំកុមារតូច | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - រៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅឆ្នាំ២០១៤។(អកត)<br>- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងដំណើរការសាលាមត្តេយ្យសិក្សាធនធាននៅឆ្នាំ ២០១៤។(អកត) | ១<br>២ | - បានផ្សព្វផ្សាយថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤។<br>- កំពុងស្នើសុំការអនុម័តដាក់ឱ្យអនុវត្តពីថ្នាក់ដឹកនាំក្រសួង។ |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - កែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ ខ្ទងផ្ទះ នៅឆ្នាំ២០១៤។(អកត)<br>- រៀបចំគោលការណ៍បង្កើនក្របខណ្ឌបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១៤។ (បវ,អកត)<br>- រៀបចំគោលការណ៍ណែនាំសម្រាប់អប់រំមាតាបិតា អ្នកអាណាព្យាបាលស្តីពីសេវាអាហារូបត្ថម្ភការគាំពារកិច្ចការពារកុមារនិងការប្រើប្រាស់សេវាសុខាភិបាល នៅឆ្នាំ ២០១៤។(សស) | ៣<br>១<br>២ | - ខ្វះធនធានថវិកា និងជំនួយការបច្ចេកទេសសម្រាប់គាំទ្រ។<br>- បានបង្កើនតួលេខជ្រើសរើសគ្រូមត្តេយ្យសិក្សា ២០០នាក់ នៅឆ្នាំ២០១៣ ទៅ ២៥០នាក់នៅឆ្នាំ២០១៤ យោងតាមលិខិត ២៣២២ អយក.បវ ចុះថ្ងៃទី១៦ ខែមិថុនាឆ្នាំ២០១៤។<br>- នាយកដ្ឋានសុខភាពសិក្សានិងនាយកដ្ឋានអប់រំកុមារតូចកំពុងសហការៀបចំសេចក្តីព្រាង។ |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - ដាក់ឱ្យអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច នៅឆ្នាំ២០១៤។ (អកត)<br>- កែសម្រួលភារកិច្ចនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអប់រំកុមារតូចឆ្លើយតបនឹងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ នៅឆ្នាំ ២០១៤។ (នក,អកត)<br>- កែសម្រួលតួនាទីភារកិច្ចនិងការប្រព្រឹត្តទៅរបស់ផ្នែកអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៤។ (នក,អកត) | ២<br>២<br>២ | - កំពុងស្នើសុំការអនុម័តដាក់ឱ្យអនុវត្តពីថ្នាក់ដឹកនាំក្រសួង។<br>- ក្រុមការងារបច្ចេកទេសកំពុងរៀបចំ និងស្នើសុំការអនុម័តដាក់ឱ្យអនុវត្តពីថ្នាក់ដឹកនាំក្រសួង។<br>- ក្រុមការងារបច្ចេកទេសកំពុងរៀបចំនិងស្នើសុំការអនុម័តដាក់ឱ្យអនុវត្តពីថ្នាក់ដឹកនាំក្រសួង។ |

| អនុវិស័យ ការអប់រំកុមារតូច | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
| --- | --- | --- | --- |
| | - រៀបចំគោលការណ៍អភិបាលកិច្ចល្អនៅគ្រឹះស្ថានមត្តេយ្យសិក្សានៅឆ្នាំ២០១៤។ (នក,អកត) | ១ | - ចំណារឯកភាពរបស់ថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២។ |

| អនុវិស័យ ការអប់រំបឋមសិក្សា | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
| --- | --- | --- | --- |
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - កែសម្រួលផែនការគោលក្នុងការជួយកុមារពិការចាប់ពីឆ្នាំ២០១៤។(បស) | ២ | - នឹងបញ្ចប់នៅដើមឆ្នាំ ២០១៥។ |
| | - ធ្វើវិសោធនកម្មអនុក្រឹត្យ ស្តីពីការផ្តល់អាហារូបករណ៍សម្រាប់បឋមសិក្សានៅឆ្នាំ ២០១៤។ (នក,ហវ) | ២ | - កំពុងដាក់ឆ្លងថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេច |
| | - កែសម្រួលលិខិតបទដ្ឋានគតិយុត្តិស្តីពីការប្រើប្រាស់ថវិកាដំណើរការសាលារៀនសម្រាប់បឋមសិក្សានៅឆ្នាំ២០១៤។(ហវ) | ១ | - ប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា។ |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - រៀបចំសេចក្តីណែនាំស្តីពីការប្រើប្រាស់កម្រងសំណួរពាក់ព័ន្ធការសិក្សារបស់សិស្សនៅឆ្នាំ ២០១៤។(បស) | ១ | |
| | - រៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីការបង្រៀនភាសាបរទេសសម្រាប់បឋមសិក្សាចាប់ពីថ្នាក់ទី៤ នៅឆ្នាំ២០១៤។(បស,អកស) | ១ | - សេចក្តីណែនាំស្តីពីការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅបឋមសិក្សា។ |
| | - រៀបចំក្របខណ្ឌធានាគុណភាពអប់រំកម្រិតសាលារៀន នៅឆ្នាំ២០១៤។(ធគអ) | ២ | - បានដាក់ជូនថ្នាក់ដឹកនាំក្រសួងសម្រេចជាបឋមនៅចុងខែធ្នូ ឆ្នាំ២០១៤ |
| | - សាកល្បងការបង្រៀននិងរៀនពេញមួយថ្ងៃចាប់ពីឆ្នាំ២០១៤។(បស) | ៣ | - ពុំទាន់មានធនធានគ្រប់គ្រាន់និងត្រៀមសិក្សាឆ្នាំ ២០១៥។ |
| | - ផ្សព្វផ្សាយនិងអនុវត្តប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀននៅឆ្នាំ២០១៤។ (បវ) | ៣ | - គម្រោង *EEQP-ADB*ដែលគាំទ្រការផ្សព្វផ្សាយ និងអនុវត្តត្រូវបានបញ្ចប់។ |
| | - ធ្វើវិសោធនកម្មនិយាមប្រើប្រាស់បុគ្គលិកអប់រំនៅឆ្នាំ២០១៤។(បល) | ១ | - ចេញនិយាមថ្មីលេខ ៣៣ អយក.សណន ដាក់ឱ្យអនុវត្តសាកល្បង ៥ រាជធានី ខេត្ត ឆ្នាំសិក្សា ២០១៤-២០១៥។ |

| អនុវិស័យ ការអប់រំបឋមសិក្សា | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - រៀបចំលិខិតបទដ្ឋានណែនាំអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា នៅឆ្នាំ២០១៤។(បស) | ១ | |
| | - រៀបចំតួនាទីភារកិច្ច និងផែនការសកម្មភាពរបស់គណៈកម្មការគ្រប់គ្រងសាលាកុមារមេត្រី នៅឆ្នាំ ២០១៤។ (បស) | ១ | |
| | - សាកល្បងអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកនៅឆ្នាំ ២០១៤ និងអនុវត្តជាផ្លូវការនៅឆ្នាំ ២០១៦។(បល) | ១ | |
| | - រៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានផ្អែកលើលទ្ធផលនៅឆ្នាំ ២០១៤។(បស) | ២ | |
| | - រៀបចំផែនការគោលអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ស្របតាមគោល-នយោបាយស្តីពីបច្ចេកវិទ្យាសារគមនា-គមន៍និងព័ត៌មានរបស់ក្រសួងនៅឆ្នាំ ២០១៤។(ផក) | ១ | - សៀវភៅផែនការគោលនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-២០១៨ (ចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៤) |

| អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - កសាងគោលនយោបាយជាតិស្តីពីអា-ហារូបករណ៍ឧបត្ថម្ភធននិងឥណទានអ្នកសិក្សានៅឆ្នាំ២០១៤។(មចទ) | ២ | - កំពុងសិក្សាប្តូរទៅជាគោលនយោបាយជាតិ វិញ។ |
| | - រៀបចំអនុក្រឹត្យស្តីពីការបង្កើនប្រាក់លើកទឹកចិត្តដល់គ្រូបម្រើការនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាលនៅឆ្នាំ ២០១៤។(បល) | ៣ | - នៅដើមឆ្នាំ២០១៥ រាជរដ្ឋាភិបាលមានផែនការបន្ថែមប្រាក់ឧបត្ថម្ភចាប់ពី ៦០០០០៛ ដល់ ៨០០០០៛ ។<br>- នាយកដ្ឋានបុគ្គលិកត្រៀមធ្វើការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យលក្ខណៈវិនិច្ឆ័យតំបន់ទាំងនេះឡើងវិញ។ |

| អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| | - រៀបចំផែនការគោលសម្រាប់អភិវឌ្ឍការអប់រំបច្ចេកទេស នៅឆ្នាំ២០១៤។ (តទវ) | ២ | - កំពុងសហការរៀបចំជាមួយ KOICA នឹងបញ្ចប់នៅខែមីនា ឆ្នាំ២០១៥។ |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - រៀបចំសេចក្តីណែនាំស្តីពីកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សានៅឆ្នាំ ២០១៤។(មចទ)<br>- រៀបចំសេចក្តីណែនាំស្តីពីការប្រឡងសិស្សផ្នែកអប់រំបច្ចេកទេសនៅឆ្នាំ ២០១៤។ (តទវ) | ២<br>២ | - កំពុងរៀបចំជាមួយអង្គការ UNECEF ។<br>- កំពុងរៀបចំសេចក្តីព្រាង នឹងបញ្ចប់នៅខែមករា។ |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - រៀបចំស្តង់ដារផ្គត់ផ្គង់សម្ភារបរិក្ខារបម្រើដល់រដ្ឋបាលសាលារៀននៅឆ្នាំ ២០១៤។(សទរ)<br>- រៀបចំប្រព័ន្ធកសាងផែនការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលនៅមធ្យមសិក្សា នៅឆ្នាំ ២០១៤។(មចទ)<br>- រៀបចំក្របខណ្ឌគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសបង្រៀននៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នៅឆ្នាំ ២០១៤។(បល,តទវ)<br>- រៀបចំលិខិតបទដ្ឋានស្តីពីការគ្រប់គ្រងគ្រឹះស្ថានអប់រំមធ្យមសិក្សាឯកជននៅឆ្នាំ២០១៤។(មចទ)<br>- រៀបចំសេចក្តីណែនាំស្តីពីស្វ័យភាពនិងការទទួលខុសត្រូវរបស់សាលាមធ្យមសិក្សានៅឆ្នាំ ២០១៤។(មចទ)<br>- រៀបចំគោលការណ៍ អភិបាលកិច្ចល្អនៅសាលាមធ្យមសិក្សាចំណេះទូទៅនិងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនៅឆ្នាំ២០១៤។(មចទ)<br>- ធ្វើបច្ចុប្បន្នភាពគោលនយោបាយបច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មានក្នុង វិស័យអប់រំនៅឆ្នាំ២០១៤។ (ពអស) | ២<br>២<br>៣<br>២<br>៣<br>៣<br>៣ | - កំពុងធ្វើពង្រាងដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំសម្រេច។<br>- លិខិតលេខ ៥៦៣៦ អយក.មចទ ស្តីពីការបើកវគ្គបំប៉ន។<br>- នឹងរៀបចំក្របខណ្ឌគ្រូបង្រៀនផ្នែកអប់រំបច្ចេទេសបន្ទាប់ពីផែនការគោលត្រូវបានរៀបចំ។<br>- បានបញ្ចប់សេចក្តីព្រាង<br>- រងចាំជំនួយការបច្ចេកទេសរបស់ធនាគារពិភពលោក។<br>- រងចាំជំនួយការបច្ចេកទេសរបស់ធនាគារពិភពលោក។<br>- ខ្វះជំនួយការបច្ចេកទេស ខ្វះប្រភពថវិកាទ្រទ្រង់។ |

| អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ២០១៤ | វឌ្ឍនភាព | សេចក្ដីបញ្ជាក់ |
|---|---|---|---|
| | - រៀបចំប្រកាសស្តីពីការកែសម្រួលភារកិច្ចនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៅឆ្នាំ ២០១៤។ (នក) | ៣ | - មិនទាន់អនុវត្ត |

| អនុវិស័យ ការអប់រំឧត្តមសិក្សា | ២០១៤ | វឌ្ឍនភាព | សេចក្ដីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - រៀបចំគោលនយោបាយស្តីពីអាហារូបករណ៍ការឧបត្ថម្ភធននិងឥណទានសម្រាប់អ្នកសិក្សានៅឧត្តមសិក្សានៅឆ្នាំ២០១៤។(ឧស) | ២ | - បានរៀបចំក្រុមការងារចុះទៅប្រទេសហ្វីលីពីន ដកស្រង់បទពិសោធ។ |
| | - រៀបចំផែនការបង្កើនចំនួននិស្សិតផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្មសិល្បៈ ច្នៃប្រឌិត និងគណិតសាស្ត្រនៅឆ្នាំ២០១៤។(ឧស) | ២ | - បានធ្វើសិក្ខាសាលាផ្លាស់ប្តូរយោបល់ជាមួយគ្រឹះស្ថានឧត្តមសិក្សា។ |
| | - រៀបចំសេចក្តីណែនាំស្តីពីការជ្រើសរើសនិស្សិតចូលរៀននិងការបញ្ចប់ការសិក្សា នៅឆ្នាំ ២០១៤។(ឧស) | ១ | - លិខិតលេខ ២៣៣១ អយក .ឧស ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៤ អំពីការស្នើសុំផែនការប្រឡងចូលជ្រើសរើស និង ប្រឡងបញ្ចប់ការសិក្សាសម្រាប់ឆ្នាំសិក្សានីមួយៗ |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - រៀបចំសេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅឆ្នាំ ២០១៤។(ឧស) | ២ | - បានធ្វើការបណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានជំនាញជាច្រើនលើក ចុះសិក្សាស្រាវជ្រាវ និងកំពុងរៀបចំរបាយការណ៍លទ្ធផលចុងក្រោយ។ |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - រៀបចំបង្កើតមហាវិទ្យាល័យអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ ២០១៤។(ឧស) | ១ | - លិខិតលេខ ២៤អយក.សស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ បង្កើតមហាវិទ្យាល័យអប់រំនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| | - រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបណ្ណាល័យ នៅឆ្នាំ ២០១៦។ (ឧស) | ៣ | - ពុំទាន់បានចាប់ផ្តើម នឹងអនុវត្តនៅឆ្នាំ២០១៥។ |

| អនុវិស័យ ការអប់រំឧត្តមសិក្សា | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| | - រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍នៅឆ្នាំ២០១៦។(ឧស) | ៣ | - ពុំទាន់បានចាប់ផ្តើម នឹងអនុវត្តនៅឆ្នាំ២០១៥។ |
| | - រៀបចំរចនាសម្ព័ន្ធនិងយន្តការអនុវត្តគោលនយោបាយស្តីពីការស្រាវជ្រាវនិងអភិវឌ្ឍ នៅឆ្នាំ២០១៤។(សវ) | ២ | - បានរៀបចំសេចក្តីព្រាងប្រកាសដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច |
| | - រៀបចំផែនការផ្តែកលើលទ្ធផលនៅឧត្តមសិក្សា ២០១៤-២០១៨ នៅឆ្នាំ២០១៤។(ឧស) | ២ | - បានរៀបចំសិក្ខាសាលាពន្យល់ណែនាំដល់គ្រឹះស្ថានឧត្តមសិក្សាឱ្យយល់គំនិតក្នុងការរៀបចំផែនការផ្តែកលើលទ្ធផល គ្រឹះស្ថានមួយចំនួនបានរៀបចំ។ |
| | - កែលម្អប្រព័ន្ធស្តីពីការទទួលស្គាល់និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១៤។(ឧស) | ២ | - បានរៀបចំសិក្ខាសាលាមួយលើកដើម្បីពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់និងវិភាគស្ថានភាពដើម្បី កែលម្អនិងខិតខំរៀបចំបន្តទៀតក្នុងឆ្នាំ២០១៥។ |
| | - រៀបចំលិខិតបទដ្ឋានស្តីពីការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ២០១៤។(ឧស) | ៣ | - ពុំទាន់បានអនុវត្តនឹងរៀបចំនៅឆ្នាំ២០១៥។ ប៉ុន្តែរង់ចាំលើ លទ្ធផលពិភាក្សាក្នុងសន្និបាតអប់រំខែមីនាឆ្នាំ២០១៥។ |

| អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - រៀបចំផែនការសកម្មភាពស្តីពីការពន្លឿនអក្ខរកម្ម នៅឆ្នាំ២០១៤។(អកប) | ១ | - បានអនុវត្តផែនការសកម្មភាពស្តីពីការពន្លឿនអក្ខរកម្មនៅឆ្នាំ២០១៤។ |
| | - កែសម្រួលសេចក្តីណែនាំ ស្តីពីការអនុវត្តកម្មវិធីចូលរៀនឡើងវិញ នៅឆ្នាំ២០១៤។(អកប) | ៣ | - រង់ចាំអនុក្រឹត្យថ្មីក្នុងការកំណត់ប្រាក់ឧបត្ថម្ភគ្រូបង្រៀនកម្មវិធីចូលរៀនឡើងវិញ។ |
| | - កែសម្រួលសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ នៅឆ្នាំ២០១៤។(អកប) | ១ | - ឯកសារលេខ ៣៨ អយក.សណន ចុះថ្ងៃទី០៣ ខែកក្កដាឆ្នាំ២០១៤។ |

| អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| | - រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ ២០១៤។(អកប)<br>- រៀបចំសេចក្តីណែនាំស្តីពីការផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាកម្មវិធីអប់រំក្រៅប្រព័ន្ធ។(អកប) | ១<br>៣ | - ឯកសារលេខ ៧០ អយក.សណន ចុះថ្ងៃទី៣០ ខែតុលាឆ្នាំ ២០១៣។<br>- រង់ចាំអនុក្រឹត្យថ្មីក្នុងការផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាកម្មវិធីអប់រំក្រៅប្រព័ន្ធ។ |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាព និងភាពឆ្លើយតប | | | |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - កែសម្រួលសេចក្តីណែនាំស្តីពីការដឹកនាំនិងគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍នៅឆ្នាំ២០១៤។ (អកប)<br>- កែសម្រួលសេចក្តីណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ ២០១៤។ (អកប)<br>- ផែនការការងាររបស់អនុក្រុមការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធត្រូវបានអនុម័តរៀងរាល់ឆ្នាំ។(អកប)<br>- កែសម្រួលសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសាលាឯកជន។(អកប) | ១<br>១<br>១<br>៣ | - ឯកសារលេខ ៩០ អយក.សណន ចុះថ្ងៃទី២២ ខែកក្កដាឆ្នាំ ២០១៤។<br>- ឯកសារលេខ ៣៧ អយក.សណន ចុះ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤។<br>- បានប្រជុំវាយតម្លៃសកម្មភាពការងាររបស់នាយកដ្ឋានជំនាញរយៈពេល ៣ខែម្តង និងអនុម័តនូវផែនការការងារបន្តជារៀងរាល់ឆ្នាំ។<br>- នាយកដ្ឋាននីតិកម្មនិងសម្របសម្រួលលើផ្នែកច្រកចេញចូលតែមួយ ក្នុងការគ្រប់គ្រងសាលាឯកជន ផ្អែកតាម អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៣។ |

| អនុវិស័យ ការអភិវឌ្ឍយុវជន | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - រៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០១៤។ (អយវ)<br>- រៀបចំក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជននិងក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌនៅឆ្នាំ២០១៤។ (អយវ) | ១<br>១ | |

| អនុវិស័យ ការអភិវឌ្ឍយុវជន | ២០១៤ | វឌ្ឍនភាព | សេចក្ដីបញ្ជាក់ |
|---|---|---|---|
| | - រៀបចំផែនការយុទ្ធសាស្រ្តសម្រាប់ក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជននៅឆ្នាំ២០១៤។(អយវ)<br>- រៀបចំសេវាតម្រង់ទិសវិជ្ជាជីវៈនិងតម្រង់ទិសការសិក្សានៅឆ្នាំ២០១៤។(យវ)<br>- រៀបចំផែនការស្ដីពីការចូលរួមរបស់យុវជនក្នុងសកម្មភាពស្ម័គ្រចិត្តនៅឆ្នាំ២០១៤។(យវ)<br>- រៀបចំផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍចលនាកាយរឹទ្ធិជាតិកម្ពុជានៅឆ្នាំ២០១៤។(យវ) | ១<br>១<br>៣<br>៣ | |
| **គោលនយោបាយទី២៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - រៀបចំលិខិតបទដ្ឋានស្ដីពីការពង្រឹងយន្តការក្រុមប្រឹក្សាកុមារនិងយុវជន និងរៀបចំឯកសារពាក់ព័ន្ធនៅឆ្នាំ២០១៤។(យវ) | ២ | - ត្រូវការរៀបចំការវាយតម្លៃជាថ្មី។ |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | - រៀបចំយន្តការសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តនៅឆ្នាំ២០១៤។(យវ)<br>- រៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលយុវជននៅឆ្នាំ២០១៤។(គមយវ)<br>- កែសម្រួលសេចក្ដីណែនាំស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលយុវជននៅឆ្នាំ២០១៤។(យវ) | ២<br>២<br>១ | - ត្រូវការរយៈពេលប្រហែល ២ខែទៀត។<br>- ដាក់ចូលក្នុងការប្រជុំរួមថ្នាក់ជាតិដើម្បីសុំធាតុចូល។ |

| អនុវិស័យ អប់រំកាយ និងកីឡា | ២០១៤ | វឌ្ឍនភាព | សេចក្ដីបញ្ជាក់ |
|---|---|---|---|
| **គោលនយោបាយទី១៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | - រៀបចំសេចក្ដីណែនាំស្ដីពី ការរៀបចំទីធ្លាសម្រាប់ការងារអប់រំកាយ និងកីឡា នៅឆ្នាំ ២០១៤។(អកឡសស)<br>- សេចក្ដីណែនាំស្ដីពីការងារបច្ចេកទេសអប់រំកាយនិងកីឡានៅឆ្នាំ២០១៤។(អកឡ)<br>- រៀបចំសេចក្ដីណែនាំស្ដីពី ការហាត់អប់រំកាយនិងកីឡានៅក្នុងម៉ោងសិក្សា | ១<br>២<br>១ | - បាននិងកំពុងធ្វើវិមជ្ឈការការងារបច្ចេកទេសជូនទៅសហព័ន្ធកីឡាជាតិ។ |

| អនុវិស័យ អប់រំកាយ និងកីឡា | ២០១៤ | វឌ្ឍនភាព | សេចក្តីបញ្ជាក់ |
|---|---|---|---|
| | និងក្រៅម៉ោងសិក្សា នៅឆ្នាំ២០១៤។ (អកឡសស) | | |
| **គោលនយោបាយទី២៖**លើកកម្ពស់គុណភាពនិងភាពឆ្លើយតប | - រៀបចំគោលនយោបាយកីឡាជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា នៅឆ្នាំ២០១៤។(អកឡ) | ២ | - កំពុងពិគ្រោះយោបល់ជាមួយអ្នកច្បាប់។ |
| | - រៀបចំផែនការគោលស្តីពីការអភិវឌ្ឍកីឡាឆ្ពោះទៅឆ្នាំ ២០២៣ នៅឆ្នាំ ២០១៤។(អគកឡ) | ២ | - កំពុងរៀបចំនិងពិភាក្សា។ |
| | - រៀបចំសេចក្តីណែនាំស្តីពី ការប្រកួតកីឡានៅតាមគ្រឹះស្ថានសិក្សា នៅឆ្នាំ ២០១៤។(អកឡសស) | ១ | - បានរៀបចំរួចរាល់ |
| **គោលនយោបាយទី៣៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | |

**បញ្ជាក់ :** ១- អនុវត្តរួចរាល់ ២- កំពុងអនុវត្ត ៣- មិនទាន់បានចាប់ផ្តើមអនុវត្ត

| | | | |
|---|---|---|---|
| នាយកដ្ឋានអប់រំកុមារតូច | អកត | នាយកដ្ឋានហិរញ្ញវត្ថុ | ហរ |
| នាយកដ្ឋានបឋមសិក្សា | បស | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | សផក |
| នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | មចទ | អធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អរហ |
| នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | អកប | នាយកដ្ឋានសំណង់សិក្សា | សណ |
| នាយកដ្ឋានសុខភាពសិក្សា | សស | នាយកដ្ឋាននីតិកម្ម | ន.ក |
| នាយកដ្ឋានឧត្តមសិក្សា | ឧស | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | សទរ |
| នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ស.វ | នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | ពអស៊ |
| អគ្គនាយកដ្ឋានកីឡា | អកឡ | នាយកដ្ឋានរដ្ឋបាល | របេ |
| អគ្គនាយកដ្ឋានយុវជន | អយជ | នាយកដ្ឋានផែនការ | ផក |
| នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | បវ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | តទវ |
| នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | អកស | នាយកដ្ឋានធានាគុណភាពអប់រំ | ធគអ |
| នាយកដ្ឋានបុគ្គលិក | បល | | |

## ឧបសម្ព័ន្ធទី៤ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| **១. ការងារអប់រំកុមារតូច** | | | | | |
| ១ .ការអភិវឌ្ឍផែនការសកម្មភាពជាតិ និង អនុវត្តគោលនយោបាយ | ២/២ | ១.ការផ្សព្វផ្សាយគោលនយោបាយជាតិ និង ផែនការសកម្មភាពជាតិស្តីពីការគាំពារ និង អភិវឌ្ឍន៍កុមារតូច | ✓ | | |
| | | ២.រៀបចំគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍ កុមារតូច (ប្រជុំ សិក្ខាសាលា បំប៉ន) | ✓ | | |
| ២. ការកសាងសមត្ថភាពលើការងារអប់រំ កុមារតូច | ២៧/៤៧ | ១. កម្មវិធីគាំទ្រកុមារអាយុ៥ឆ្នាំ | ✓ | | |
| | | **ការពង្រីកមត្តេយ្យសិក្សារដ្ឋ** | | | |
| | | ២.កញ្ចប់សម្ភារៈអនាម័យសម្រាប់មត្តេយ្យសិក្សា រដ្ឋ | | | ✓ |
| | | ៣.កញ្ចប់សម្ភារៈរៀននិងបង្រៀនសម្រាប់មត្តេយ្យ សិក្សារដ្ឋ | | | ✓ |
| | | ៤.វគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីកម្មវិធីសិក្សា មត្តេយ្យរដ្ឋថ្មី ៥ថ្ងៃ | | | ✓ |
| | | ៥.វគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ក្រោមជាតិស្តីពីកម្មវិធី សិក្សាមត្តេយ្យរដ្ឋថ្មី ៥ថ្ងៃ | | | ✓ |
| | | ៦.វគ្គបំប៉នគ្រូមត្តេយ្យសិក្សារដ្ឋ ១៩៤០នាក់ ស្តីពី កម្មវិធីសិក្សាថ្មី (១៥ថ្ងៃ) | | | ✓ |
| | | ៧. វគ្គបំប៉នគ្រូបឋមសិក្សា គ្រូកិច្ចសន្យាបង្រៀន ថ្នាក់មត្តេយ្យសិក្សារដ្ឋ ១០០០នាក់ ស្តីពីកម្មវិធី សិក្សាថ្មី (៣០ថ្ងៃ) | | | ✓ |
| | | ៨.ការកែលំអស្តង់ដារកម្មវិធីសិក្សាថ្មី | | | ✓ |
| | | ៩. ការរៀបចំឯកសារម៉ូឌុលសម្រាប់វគ្គបំប៉នគ្រូ មត្តេយ្យសិក្សារដ្ឋ គ្រូបឋម គ្រូកិច្ចសន្យាបង្រៀន ថ្នាក់មត្តេយ្យ | | | ✓ |
| | | **កម្មវិធីមត្តេយ្យសិក្សាធនធាន** | | | |
| | | ១០.ការរៀបចំឯកសារម៉ូឌុល និងសម្ភារឧបទ្ទេស សម្រាប់បំប៉នកម្មវិធីមត្តេយ្យសិក្សាធនធាន | ✓ | | |
| | | ១១.វគ្គបំប៉នថ្នាក់តំបន់ដល់មន្ត្រីថ្នាក់ខេត្ត ស្រុក ស្តីពីកម្មវិធីមត្តេយ្យសិក្សាធនធាន | | | ✓ |
| | | ១២.ការបំប៉នក្រុមបណ្តាញការងារមត្តេយ្យសិក្សា ធនធានរាល់បីខែម្តង | | | ✓ |
| | | ១៣.ការចុះពិនិត្យតាមដានបែបគាំទ្រពីថ្នាក់ជាតិ លើកម្មវិធីមត្តេយ្យសិក្សាធនធាន | | | ✓ |

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| | | ១៤.ថវិកាសម្រាប់អភិវឌ្ឍមត្តេយ្យសិក្សាធនធាន | | | ✓ |
| | | ១៥.អ្នកជំនួយការបច្ចេកទេសសម្រាប់មត្តេយ្យសិក្សាធនធាន | | | ✓ |
| | | ១៦.បញ្ចប់ការរៀបចំឯកសារគោលការណ៍ណែនាំអនុវត្តមត្តេយ្យសិក្សាធនធាន | ✓ | | |
| | | **កម្មវិធីសិក្សាមត្តេយ្យសិក្សាសហគមន៍** | | | |
| | | ១៧.ចុះពិនិត្យទីតាំងដើម្បីរៀបចំបង្កើតមត្តេយ្យសិក្សាសហគមន៍ថ្មី | ✓ | | |
| | | ១៨.វគ្គតម្រង់ទិសសម្រាប់បណ្តាញក្រុមការងារកម្ម វិធីមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ | ✓ | | |
| | | ១៩.វគ្គបំប៉នស្តីពីដំណើរការ និងបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ដល់គ្រូឧទ្ទេសថ្នាក់ជាតិ | ✓ | | |
| | | ២០.វគ្គបំប៉នស្តីពីដំណើរការ និងបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ដល់គ្រូឧទ្ទេសថ្នាក់ក្រោមជាតិ | ✓ | | |
| | | ២១.វគ្គបំប៉នដំបូងស្តីពីដំណើរការ និងបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ថ្មី | ✓ | | |
| | | ២២.វគ្គបំប៉នបន្តស្តីពីដំណើរការ និងបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ចាស់ (១៥៨នាក់) | ✓ | | |
| | | ២៣.វគ្គបំប៉នបន្តស្តីពីដំណើរការ និងបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ចាស់ ៦៣នាក់ | ✓ | | |
| | | ២៤.ប្រជុំបច្ចេកទេសប្រចាំខែសម្រាប់មត្តេយ្យសិក្សាសហគមន៍ ជាមួយមន្ត្រីអប់រំកុមារតូចថ្នាក់ស្រុក | | | ✓ |
| | | ២៥.កញ្ចប់សម្ភារៈសម្រាប់មត្តេយ្យសិក្សាសហគមន៍ចាស់ និងថ្មីក្នុងគម្រោង GPE | | | ✓ |
| | | ២៦.ទីប្រឹក្សាបច្ចេកទេសក្នុងស្រុកសម្រាប់មត្តេយ្យសិក្សាសហគមន៍ | | | ✓ |
| | | ២៧.រៀបចំឯកសារ និងសម្ភារៈសម្រាប់បំប៉នដំបូង និងបំប៉នបន្តសម្រាប់មត្តេយ្យសិក្សាសហគមន៍ | ✓ | | |
| | | កម្មវិធីអប់រំកុមារតូចតាមផ្ទះ និងអប់រំឪពុកម្តាយ | ✓ | | |

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| | | ២៨.បំប៉នគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងកម្មវិធីអប់រំឪពុកម្តាយ | ✓ | | |
| | | ២៩.វគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ក្រោមជាតិស្តីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងកម្មវិធីអប់រំឪពុកម្តាយ | ✓ | | |
| | | ៣០.វគ្គបំប៉នដំបូងដល់ម្តាយបង្គោលស្តីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ | ✓ | | |
| | | ៣១.វគ្គបំប៉នបន្តដល់ម្តាយបង្គោលស្តីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ | ✓ | | |
| | | ៣២.កញ្ចប់សម្ភារៈសម្រាប់កម្មវិធីអប់រំកុមារតូចតាមផ្ទះ | | | ✓ |
| | | ៣៣.កម្មវិធីប្រជុំប្រចាំខែស្តីពីការថែទាំអាហារូបត្ថម្ភបន្ថែមតាមស្តង់ដារ និងការប្រើប្រាស់សេវាសុខាភិបាលសម្រាប់កម្មវិធីអប់រំកុមារតូចតាមផ្ទះ | | | ✓ |
| | | ៣៤.ទីប្រឹក្សាបច្ចេកទេសក្នុងស្រុកសម្រាប់កម្មវិធីអប់រំកុមារតូចតាមផ្ទះ (១សម្រាប់ប្រឹក្សាកម្មវិធី និង១ សម្រាប់ផ្នែកសុខាភិបាល) | | | ✓ |
| | | កម្មវិធីអប់រំឪពុកម្តាយផ្សារភ្ជាប់ជាមួយមត្តេយ្យសិក្សាសហគមន៍ | | | ✓ |
| | | ៣៥.វគ្គបំប៉នស្តីពីការអប់រំឪពុកម្តាយផ្សារភ្ជាប់ជាមួយកម្មវិធីមត្តេយ្យសិក្សាសហគមន៍ក្នុងទីតាំងថ្នាក់គោលដៅ | | | ✓ |
| | | ៣៦.ការប្រជុំប្រចាំខែស្តីពីការថែទាំ អាហារូបត្ថម្ភបន្ថែមតាមស្តង់ដារ និងការប្រើប្រាស់សេវាសុខាភិបាលសម្រាប់កម្មវិធីមត្តេយ្យសិក្សាសហគមន៍ | | | ✓ |
| | | កម្មវិធីអប់រំឪពុកម្តាយផ្សារភ្ជាប់ជាមួយមត្តេយ្យសិក្សារដ្ឋ | | | ✓ |
| | | ៣៧.វគ្គបំប៉នស្តីពីការអប់រំឪពុកម្តាយផ្សារភ្ជាប់ជាមួយកម្មវិធីមត្តេយ្យសិក្សារដ្ឋក្នុងទីតាំងថ្នាក់គោលដៅ | | | ✓ |
| | | ៣៨.ប្រជុំប្រចាំខែស្តីពីការថែទាំ អាហារូបត្ថម្ភបន្ថែមតាមស្តង់ដារ និងការប្រើប្រាស់សេវាសុខាភិបាលសម្រាប់កម្មវិធីមេត្តេយ្យសិក្សារដ្ឋ | | | ✓ |
| | | កម្មវិធីអន្តរាគមន៍ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលមានកូនក្រោមអាយុ ២ឆ្នាំ | | | ✓ |

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| | | ៣៩.វគ្គបំប៉នស្តីពីការអប់រំស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូនអាយុក្រោម ២ឆ្នាំនៅក្នុងកម្មវិធីអប់រំកុមារតូចតាមផ្ទះ | | | ✓ |
| | | ៤០.ការប្រជុំប្រចាំខែស្តីពីការថែទាំ អាហារូបត្ថម្ភបន្ថែមតាមស្តង់ដារ និងការប្រើប្រាស់សេវាសុខាភិបាលសម្រាប់កម្មវិធីអប់រំកុមារតូចតាមផ្ទះគោលដៅ | | | ✓ |
| | | **ការគាំទ្រការងារអប់រំកុមារតូចដោយដៃគូ** | | | |
| | | ៤១.អនុវត្តការងារអប់រំកុមារតូចថ្នាក់ក្រោមជាតិ (UNICEF) | ✓ | | |
| | | ៤២.គាំទ្រការងារអប់រំកុមារតូចនៅថ្នាក់កណ្តាល (Plan) | ✓ | | |
| | | ៤៣.គាំទ្រការងារអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិនៅខេត្តសៀមរាប រតនគិរី និងកំពង់ចាម (Plan) | ✓ | | |
| | | ៤៤.គាំទ្រការងារអប់រំកុមារតូចនៅថ្នាក់កណ្តាល (SC) | ✓ | | |
| | | ៤៥.គាំទ្រការងារអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិសៀមរាប កំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ កោះកុង ក្រចេះ និងព្រៃវែង (SC) | ✓ | | |
| | | ៤៦.ការគាំទ្រការងារអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិ (CYK) | ✓ | | |
| | | ៤៧.អភិវឌ្ឍការងារអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិ (បណ្តុះកុមារ) | ✓ | | |
| ៣. ការពិនិត្យតាមដាន និងវាយតម្លៃ | ៦/៦ | ១. ពិនិត្យតាមដានផ្នែកអប់រំកុមារតូច (PB) | ✓ | | |
| | | ២. ពិនិត្យតាមដានកម្មវិធីអប់រំកុមារតូចរបស់ថ្នាក់ជាតិ | ✓ | | |
| | | ៣. ពនិត្យតាមដានផ្នែកអប់រំកុមារតូចរបស់ថ្នាក់ខេត្ត | ✓ | | |
| | | ៤. ពិនិត្យតាមដានផ្នែកអប់រំកុមារតូចរបស់ថ្នាក់ស្រុក | ✓ | | |
| | | ៥. ប្រជុំបូកសរុបការងារអប់រំកុមារតូចពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ | ✓ | | |
| | | ៦. ពិនិត្យតាមដាន សិក្សាស្រាវជ្រាវការងារអប់រំកុមារតូច | ✓ | | |

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| ៤. ការងារផ្សព្វផ្សាយ និងផ្គត់ផ្គង់ | ០/១៤ | ១. កុំព្យូទ័រយួរដៃចំនួន ៨ | | | ✓ |
| | | ២. ម៉ាស៊ីន LCD ចំនួន ២ | | | ✓ |
| | | ៣. ក្បាល DVD ចំនួន ១០ | | | ✓ |
| | | ៤. ប្រដាប់បំពងសម្លេងចំនួន ១០ | | | ✓ |
| | | ៥. ម៉ាស៊ីនថតរូបចំនួន ៥ | | | ✓ |
| | | ៦. ម៉ាស៊ីនថតវីដេអូចំនួន ១ | | | ✓ |
| | | ៧. កុំព្យូទ័រលើតុចំនួន ១៤ | | | ✓ |
| | | ៨. សម្ភារៈការិយាល័យ និងការចំណាយលើការទំនាក់ទំនង | | | ✓ |
| | | ៩. រថយន្តដឹកអាប់ចំនួន ២ គ្រឿង | | | ✓ |
| | | ១០. រថយន្តវ៉ែនចំនួន ១ គ្រឿង | | | ✓ |
| | | ១១. ប្រាក់បៀវត្សអ្នកបើកបរ | | | ✓ |
| | | ១២. ប្រេងឥន្ធនៈសម្រាប់រថយន្តប្រចាំខែ | | | ✓ |
| | | ១៣. ការបោះពុម្ពឯកសារ | | | ✓ |
| | | ១៤. សម្ភារៈសម្រាប់នា.ដ្ឋានអប់រំកុមារតូច | | | ✓ |
| ៥. អភិវឌ្ឍសមត្ថភាព គ្រប់គ្រង និងក្របខណ្ឌ ការងារអប់រំកុមារតូច | ៤/១០ | ១. ជួយអភិវឌ្ឍសមត្ថភាពមន្ត្រីនៅថ្នាក់ជាតិ និងក្រោមជាតិស្តីពីការប្រើប្រាស់ថវិកាជំនួយអភិវឌ្ឍសាលារៀន | ✓ | | |
| | | ២.បង្កើនសមត្ថភាពតាមរយៈការបំប៉ន សិក្ខាសាលា ទស្សនកិច្ចសិក្សា | ✓ | | |
| | | **ការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្អែកលើផលសម្រេច** | | | |
| | | ៣.បង្កើនសមត្ថភាពមន្ត្រីថ្នាក់ជាតិស្តីពីប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់អនុវិស័យអប់រំកុមារតូច | ✓ | | |
| | | ៤.វគ្គបំប៉នស្តីពីការប្រមូលព័ត៌មានទិន្នន័យសម្រាប់អនុវិស័យអប់រំកុមារតូច | | | ✓ |
| | | ៥.រៀបចំប្រព័ន្ធតេស្តស្តង់ដារទៀងទាត់នៅថ្នាក់រៀនសម្រាប់អនុវិស័យអប់រំកុមារតូច | | | ✓ |
| | | ៦.វគ្គបំប៉នស្តីពីការរៀបចំផែនការពិនិត្យតាមដានការតាមដាន និងវាយតម្លៃ ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ និងការរៀបចំរបាយការណ៍ | | | ✓ |
| | | ៧.សិក្សា និងទស្សនកិច្ចសិក្សាសម្រាប់កម្មវិធីអប់រំកុមារតូចតាមផ្ទះ និងមត្តេយ្យសិក្សាសហគមន៍ | | | ✓ |
| | | ៨.សិក្សា និងទស្សនកិច្ចសិក្សាសម្រាប់កម្មវិធីអប់រំ | | | ✓ |

| សកម្មភាពគោល | លទ្ធផល | សកម្មភាពរង | ស្ថានភាព | | |
|---|---|---|---|---|---|
| | | | ១ | ២ | ៣ |
| | | កុមារតូចតាមផ្ទះ ក្នុង និងក្រៅប្រទេស | | | |
| | | ៩.បង្កើនសមត្ថភាពក្នុងប្រទេសស្តីពីការវិភាគ ទិន្នន័យ និងការរៀបចំរបាយការណ៍ | | | ✓ |
| | | ១០.វគ្គបំប៉នស្តីពីការរៀបចំផែនការផ្អែកលើផលសម្រេចសម្រាប់អនុវិស័យអប់រំកុមារតូច | ✓ | | |
| **២. ការអប់រំបឋមសិក្សា** | | | | | |
